កិត្តាវតា បន ភន្តេ ឧបាសកោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។ យតោ ខោ មហានាម ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ នោ បរំ សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ នោ បរំ ចាគសម្បទាយ សមាទបេតិ អត្តនា ច កិក្ខុំ ឧបសង្កមិតា ហោតិ នោ បរំ កិក្ខុំ ឧបសង្កមេ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ នោ បរំ សទ្ធម្មស្សវនេ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ បរំ ធម្មធារណាយ សមាទបេតិ អត្តនា ច សុតានំ(១) ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ បរំ អត្ថុបបរិក្ខាយ សមាទបេតិ អត្តនា ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ បរំ ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ

---

១ ម. អត្តនា គពាធំ ។

បពិត្រព្រះអង្គដ៏ចំរើន ចុះទុកាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃទេ តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ទុកាសកអ្នកបរិបូណ៌ ដោយសទ្ធា ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់ធម៌តាំងទុកជាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌តាំងទុកជាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា

ឯត្តាវតា ខោ មហានាម ឧបាសកោ អត្ថហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ អត្ថហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។ យតោ ខោ មហានាម ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ បរញ្ច សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ បរញ្ច សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ បរញ្ច ចាគសម្បទាយ សមាទបេតិ អត្តនា ច កិក្ខុំ ឧបសង្កមិតា ហោតិ បរញ្ច កិក្ខុំ ឧបសង្កមនាយ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ បរញ្ច សទ្ធម្មស្សវនេ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ បរញ្ច ធម្ម-ធារណាយ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ អត្ថូបបរិក្ខី ហោតិ បរញ្ច អត្ថូបបរិក្ខាយ សមាទបេតិ

បណ្ណាសក គហបតិវគ្គ

បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ បពិត្រព្រះអង្គដ៏ចំរើន ចុះឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ដួបប្រទះពួកភិក្ខុដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបានដួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់នូវធម៌តាំងឡាយដែលបានស្តាប់ហើយដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌តាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១

អត្តនា ច អត្តមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្ម-
ប្បដិបន្នោ ហោតិ បរញ្ច ធម្មានុធម្មប្បដិបត្តិយា
សមាទបេតិ ឯត្តាវតា ខោ មហានាម ឧបាសកោ
អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។

(២៦) ឯកំ សមយំ ភគវា រាជគហេ វិហរតិ
ជីវកម្ពវនេ ។ អថខោ ជីវកោ កោមារភច្চោ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ កោមារភច្চោ
ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ឧបាសកោ
ហោតីតិ ។ យតោ ខោ ជីវក ពុទ្ធំ សរណំ គតោ
ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ
ហោតិ ឯត្តាវតា ខោ ជីវក ឧបាសកោ ហោតីតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ សីលវា
ហោតីតិ ។ យតោ ខោ ជីវក ឧបាសកោ បាណាតិ-
បាតា បដិវិរតោ ហោតិ ។បេ។ សុរាមេរយមជ្ជប្ប-
មាទដ្ឋានា បដិវិរតោ ហោតិ ឯត្តាវតា ខោ ជីវក
ឧបាសកោ សីលវា ហោតីតិ ។

អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយហេតុណា បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណេះ ។

[២៦] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដីវកម្មវនជិតក្រុងពារាណសី ។ គ្រានោះ ដីវកគោមារកត្យ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះដីវកគោមារកត្យ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។ ម្នាលដីវក បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា ម្នាលដីវក បុគ្គលនោះ បានជាឧបាសក ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

បពិត្រព្រះអង្គដ៏ចំរើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។ ម្នាលដីវក ឧបាសកជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា ម្នាលដីវក ឧបាសកជាអ្នកមានសីល ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

កិត្តាវតា បន កន្តេ ឧបាសកោ អត្តមនាយ បដិបន្នោ ហោតិ នោ បរមនាយាតិ ។ យតោ ខោ ជីវក ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ នោ បរំ សទ្ធាសម្បទាយ សមាទបេតិ ។បេ។ អត្តនា ច អត្តមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ បរំ ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ ឯត្តាវតា ខោ ជីវក ឧបាសកោ អត្តមនាយ បដិបន្នោ ហោតិ នោ បរមនាយាតិ ។

កិត្តាវតា បន កន្តេ ឧបាសកោ អត្តមនាយ ច បដិបន្នោ ហោតិ បរមនាយ ចាតិ ។ យតោ ខោ ជីវក ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ បរញ្ច សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ បរញ្ច សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ បរញ្ច ចាគសម្បទាយ សមាទបេតិ អត្តនា ច កិញ្ចនំ ទស្សនកាមោ ហោតិ បរញ្ច កិញ្ចនំ ទស្សនេ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ

បណ្ណាសក ឆហេតុវិត្ត

បពិត្រព្រះអង្គដ៏ចំរើន ចុះទុបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ តើដោយហេតុដូចម្តេច ។ ម្នាលជីវក ទុបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង តែមិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ ដោយសទ្ធា ១ ។ បេ ។ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង តែមិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ទុបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

បពិត្រព្រះអង្គដ៏ចំរើន ចុះទុបាសកអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។ ម្នាលជីវក ទុបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង តាំងបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង

ปรญฺจ สนฺธฺยสฺสเน สมาธเปตึ อตฺตนา จ สุตานํ ธมฺมานํ ธารกชาติกตา โหติ ปรญฺจ ธมฺมธารณาย สมาธเปตึ อตฺตนา จ สุตานํ ธมฺมานํ อตฺถูปปริกฺขึ โหติ ปรญฺจ อตฺถูปปริกฺขาย สมาธเปตึ อตฺตนา จ อตฺถูปปญฺญาย ธมฺมูปปญฺญาย ธมฺมานุธมฺมปฺปฏิปนฺโน โหติ ปรญฺจ ธมฺมานุธมฺมปฺปฏิปตฺติยา สมาธเปตึ ฯเปฯ ขตฺติยกุลูปโก อตฺตมนตาย จ ปฏิปนฺโน โหติ ปรมนตาย จาติ ฯ

(๒๗) อฏฺฐงฺคิโก กมฺมปโถ ๆลฯ กตมานิ อฏฺฐ ฯ ปาณาติปาตา เวรมณี กมฺมปโถ จารกา โกจิ ปาณาติปาตา มาตุปฏฺฐาคา อารุปฺปา ปาณาติปาตา ปรมา ๔ สปฺปุริสา ปาณาติปาตา ภยา ๒ ปฏิปตฺติ ปาณาติปาตา ปฏิปตฺติ ปณฺฑิตา ปฏิสนฺถารา พหุสฺสุตา ๑ ปฏิปตฺติ สมณ-พฺราหฺมณา ฯ ๔ มคฺคา โข กมฺมปโถ อฏฺฐ ปาณาติปาตา ฯ

ចាំឆបបួលបុគ្គលដទៃ ឲ្យបានស្តាប់នូវព្រះសទ្ធម្ម ១ ជាអ្នកទ្រទ្រង់នូវធម៌ចាំឆឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ចាំឆបបួលបុគ្គលដទៃឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ចាំឆឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង ចាំឆបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ចាំឆបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ។បា។ សក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្លូវខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

(៤៧) ម្នាលភិក្ខុចាំឆឡាយ កំឡាំងនេះមាន ៨ យ៉ាង ។ កំឡាំង ៨ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុចាំឆឡាយ ពួកក្មេងមានការយំជាកំឡាំង ១ ពួកមាតុគ្រាមមានសេចក្តីក្រោធ ជាកំឡាំង ១ ពួកចោរមានគ្រឿងអាវុធ ជាកំឡាំង ១ ពួកព្រះរាជាមានឥស្សរិយៈ ជាកំឡាំង ១ ពួកជនពាលមានការលើកទោស ជាកំឡាំង ១ ពួកបណ្ឌិតមានការពិចារណាជាកំឡាំង ១ ពួកពហុស្សុតមានការពិចារណាជាកំឡាំង ១ ពួកសមណព្រាហ្មណ៍មានការអត់ធន់ ជាកំឡាំង ១ ។ ម្នាលភិក្ខុចាំឆឡាយ កំឡាំងមាន ៨ យ៉ាងនេះឯង ។

(២៨) អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច កតិ នុ ខោ សារីបុត្ត ឥណាសវាសច្ច កិត្តិយោ ពលានិ យេហិ ពលេហិ សមន្នាគតោ ឥណាសវោ កិត្តិ អាសវានំ ខយំ បដិជានាតិ ឥណា មេ អាសវាតិ ។ អដ្ឋ ភន្តេ ឥណាសវាសច្ច កិត្តិយោ ពលានិ យេហិ ពលេហិ សមន្នាគតោ ឥណាសវោ កិត្តិ អាសវានំ ខយំ បដិជានាតិ ឥណា មេ អាសវាតិ ។ កតមានិ អដ្ឋ ។ ឥធ ភន្តេ ឥណាសវាសច្ច កិត្តិយោ អនិច្ចតោ សព្ពេ សង្ខារ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្បិ ភន្តេ ឥណាសវាសច្ច កិត្តិយោ អនិច្ចតោ សព្ពេ សង្ខារ យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ

(២៨) គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលសារីបុត្ត កិក្ខុជាខីណាស្រព ប្រកបដោយកំឡាំងពាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈពាំងឡាយថា អាសវៈពាំងឡាយ របស់អាត្មាអញអស់ហើយ កំឡាំងពាំងនោះ របស់កិក្ខុជាខីណាស្រព តើមានប៉ុន្មានយ៉ាង ។ បពិត្រព្រះអង្គដ៏ចំរើន កិក្ខុជាខីណាស្រព ប្រកបដោយកំឡាំងពាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈពាំងឡាយថា អាសវៈពាំងឡាយ របស់អាត្មាអញអស់ហើយ កំឡាំងពាំងនោះ របស់កិក្ខុជាខីណាស្រពមាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន កិក្ខុជាខីណាស្រព ក្នុងសាសនានេះ ឃើញច្បាស់នូវសង្ខារពាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ។ បពិត្រព្រះអង្គដ៏ចំរើន កិក្ខុជាខីណាស្រព ឃើញច្បាស់នូវសង្ខារពាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ដោយកំឡាំងណា

ឥធម្ម កន្តេ ខីណាសវស្ស កិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ កិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ កន្តេ ខីណាសវស្ស កិក្ខុនោ អដ្ឋារសាស្ស បមា ការមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្ប កន្តេ ខីណាសវស្ស កិក្ខុនោ អដ្ឋារសាស្ស បមា ការមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥធម្ប កន្តេ ខីណាសវស្ស កិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ កិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ កន្តេ ខីណាសវស្ស កិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកចោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ ។

បពិត្រព្រះអង្គដ៏ចំរើន (ម្យ៉ាងទៀត) កិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកំឡាំងណា កំឡាំងនេះ ជាកំឡាំងរបស់កិក្ខុជាខីណាស្រព។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កិក្ខុជាខីណាស្រព ឃើញច្បាស់នូវតាមពាំងឡាយ មានឧបមាដូចជារណ្តៅ ដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត។ បពិត្រព្រះអង្គដ៏ចំរើន កិក្ខុជាខីណាស្រពឃើញច្បាស់នូវតាមពាំងឡាយ ដែលមានឧបមាដូចជារណ្តៅដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ដោយកំឡាំងណា បពិត្រព្រះអង្គដ៏ចំរើន (ម្យ៉ាងទៀត) កិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកំឡាំងណា កំឡាំងនេះ ជាកំឡាំងរបស់កិក្ខុជាខីណាស្រព។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ចិត្តរបស់កិក្ខុជាខីណាស្រព តែងនៅទៅរកវិវេក ឈានទៅរកវិវេក ចៃរទៅរកវិវេក ដំកល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង។

យម្បិ ភន្តេ ខីណាសវស្សបិ តិក្ខិន្ទោ វិវេកនិន្នំ ចិត្តំ
ហោតិ វិវេកដ្ឋំ វិវេកបញ្ហារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ
ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ ឥទម្បិ
ភន្តេ ខីណាសវស្សបិ តិក្ខិន្ទោ ពលំ ហោតិ យំ ពលំ
អាគម្ម ខីណាសវោ តិក្ខិ អាសវានំ ខយំ បដិជានាតិ
ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស
តិក្ខិន្ទោ ចត្តារោ សតិបដ្ឋានា ភាវិតា ហោន្តិ សុភា-
វិតា ។ យម្បិ ភន្តេ ខីណាសវស្សបិ តិក្ខិន្ទោ ចត្តារោ
សតិបដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ឥទម្បិ ភន្តេ
ខីណាសវស្សបិ តិក្ខិន្ទោ ពលំ ហោតិ យំ ពលំ អាគម្ម
ខីណាសវោ តិក្ខិ អាសវានំ ខយំ បដិជានាតិ ខីណា
មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស
តិក្ខិន្ទោ ចត្តារោ ឥទ្ធិបាទា ភាវិតា ហោន្តិ សុភាវិតា
។ បេ ។ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ

បឋមាសក ឥរហបតីវគ្គ

បពិត្រព្រះអង្គដ៏ចំរើន ចិត្តរបស់កិក្ខុ ជាខីណាស្រព តែងតែនៅរកវិវេក ឈានៅរកវិវេក បៃរៅរកវិវេក ជំកល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងពួយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ដោយកំឡាំងណា បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់នៃអាសវៈទាំងពួយថា អាសវៈទាំងពួយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកំឡាំងណា កំឡាំងនេះ ជាកំឡាំងរបស់កិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កិក្ខុជាខីណាស្រព ចានចំរើន អប់រំល្អហើយ នូវសតិប្បដ្ឋានទាំង ៤ ។ បពិត្រព្រះអង្គដ៏ចំរើន កិក្ខុជាខីណាស្រព ចានចំរើន អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ដោយកំឡាំងណា បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់នៃអាសវៈទាំងពួយថា អាសវៈទាំងពួយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកំឡាំងណា កំឡាំងនេះ ជាកំឡាំងរបស់កិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត កិក្ខុជាខីណាស្រព ចានចំរើនអប់រំល្អហើយ នូវឥទ្ធិបាទ ៤ ។ បេ ។ ចានចំរើន អប់រំល្អហើយ នូវឥន្ទ្រិយ ៥

សត្ត ពោជ្ឈង្គា ភាវិតា ហោន្តិ សុភាវិតា អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ។ យម្បិ កន្តេ ខីណាសវស្ស កិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ឥទម្បិ កន្តេ ខីណាសវស្ស កិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ កិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ ឥមានិ ខោ កន្តេ អដ្ឋ ខីណាសវស្ស កិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ កិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

(២៩) ខណាតីតោ លោកោតិ កិក្ខវេ អស្សុតវា បុថុជ្ជនោ ភាសតិ នោ ច ខោ សោ ជានាតិ ខណំ វា អក្ខណំ វា ។ អដ្ឋមេ កិក្ខវេ អក្ខណា អសមយា ព្រហ្មចរិយវាសាយ ។ កតមេ អដ្ឋ ។

បានចំពោះ អប់រំល្អហើយនូវពោជ្ឈង្គ ៧ បានចំពោះ អប់រំល្អហើយនូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ បពិត្រព្រះអង្គដ៏ចំរើន កិកុជាឱណាស្រេច បានចំពោះ អប់រំល្អហើយនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយកំឡាំងណា បពិត្រព្រះអង្គដ៏ចំរើន (ម្ល៉ាងទៀត) កិកុជាឱណាស្រេច ប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកំឡាំងណា កំឡាំងនេះ ជាកំឡាំងរបស់កិកុជាឱណាស្រេច ។ បពិត្រព្រះអង្គដ៏ចំរើន កិកុជាឱណាស្រេចប្រកបដោយកំឡាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កំឡាំងទាំងនោះ របស់កិកុជាឱណាស្រេច មាន ៨ យ៉ាងនេះឯង ។

(២៩) ម្នាលកិកុទាំងឡាយ ឫឫដ្ឋនមិនមានការចេះដឹង រមែងនិយាយថា សត្វលោកមានកិច្ចកង្ខាណៈ សត្វលោកមានកិច្ចកង្ខាណៈ តែឫឫដ្ឋននោះ មិនដឹងនូវខណៈឬអក្ខណៈទេ ។ ម្នាលកិកុទាំងឡាយ អក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យនេះមាន ៨ យ៉ាង ។ ៨ យ៉ាងតើអ្វីខ្លះ ។

๙๘ តិក្ខវេ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ឥមញ្ច ទេសិយតិ ឧបសមិតោ បរិនិព្ពានិតោ សម្ពោធគាមី សុគត-ប្បវេទិតោ អយញ្ច បុគ្គលោ និរយំ ឧបបន្នោ ហោតិ ។ អយំ តិក្ខវេ បឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ តិក្ខវេ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ឥមញ្ច ទេសិយតិ ឧបសមិតោ បរិនិព្ពានិតោ សម្ពោធគាមី សុគត-ប្បវេទិតោ អយញ្ច បុគ្គលោ តិរច្ឆានយោនិំ ឧបបន្នោ ហោតិ ។ បេ ។ អយញ្ច បុគ្គលោ

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់ នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ដូចនាយសារថី ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរាយសច្ច ទ្រង់មានដំណើរទៅកាន់ត្រែកពន្លាក់ចេលហើយ បានកើតឡើង ក្នុងលោកនេះ ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងួតរម្ងាប់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏បានសំដែងហើយ តែទាស់បុគ្គលនេះទៅកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចរ្យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរាយសច្ច ទ្រង់មានដំណើរទៅកាន់ត្រែកពន្លាក់ចេលហើយ រមែងកើតឡើងក្នុងលោក ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងួតរម្ងាប់ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គបានសំដែងហើយ តែទាស់បុគ្គលនេះ ទៅកើតក្នុងកំណើតតិរច្ឆាន ។ បេ ។ តែទាស់បុគ្គលនេះ

បដិវិសយំ ឧបបន្នោ ហោតិ ។បេ។ អយញ្ច បុគ្គលោ អញ្ញតរំ ទីឃាយុកំ ទេវនិកាយំ ឧបបន្នោ ហោតិ ។បេ។ អយញ្ច បុគ្គលោ បច្ចន្តិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ អវិញ្ញាតារេសុ មិលក្ខេសុ(๑) យត្ថ នត្ថិ កតំ កិញ្ចនំ កិញ្ចនីនំ ឧចាសកានំ ឧចាសិកានំ ។បេ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឧបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។បេ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ ទុប្បញ្ញោ ជឡោ

---

๑ ម. មិលក្ខេសុ ។

ទៅកើតក្នុងបិត្តិវិស័យ ។បេ។ តែថាស់បុគ្គលនេះ ទៅកើតក្នុងពួកទេវតា
ណាមួយមានអាយុវែង ។ បេ ។តែថាស់បុគ្គលនេះ ជាអ្នកមកកើតក្នុងពួក-
បច្ចន្តិមជនបទ ទាំងជាអ្នកបានទៅកើតក្នុងពួកមិលក្ខជន ដែលមិនដឹងការ
ខុសត្រូវច្បាស់លាស់ ដែលជាប្រទេសគ្មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា
ទៅដល់ ។ បេ ។ បុគ្គលនេះ បានមកកើត ក្នុងពួកមជ្ឈិមជនបទហើយ
ថាស់តែបុគ្គលនោះ ជាមិច្ឆាទិដ្ឋិ មានសេចក្តីឃើញវិបរិតថា ទានដែល
បុគ្គលឲ្យហើយគ្មានផល ការបូជាធំគ្មានផល ការបូជាតូចគ្មានផល ផល
នឹងវិបាករបស់កម្ម ដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មិនមាន លោកនេះ
ក៏មិនមាន លោកដទៃ ក៏មិនមាន មាតាក៏មិនមាន បិតាក៏មិនមាន
ពួកសត្វជាឧបបាតិក:ក៏មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នក
ព្រមព្រៀងគ្នា ប្រតិបត្តិដោយល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ នឹង
លោកខាងមុខ ព្រោះដឹងច្បាស់ដោយខ្លួនឯង ហើយញុំាងអ្នកដទៃឲ្យ
ត្រាស់ដឹងផង ក៏មិនមាន ។ បេ ។ បុគ្គលនេះ បានមកកើតក្នុងពួក
មជ្ឈិមជនបទហើយ ថាស់តែបុគ្គលនោះ ជាអ្នកអប្បឥតប្រាជ្ញា លង់ខ្លៅ

ฝឧ្បម្ងតោ ឆ បដិ៣លោ សុភាសិតទុព្ភាសិតស្ស អត្តមញ្ញាតុំ ។ អយំ កិក្ខវេ សត្តមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ កិក្ខវេ តថាគតោ ច លោកេ អនុប្បន្នោ ហោតិ អរហំ សម្មា-សម្ពុទ្ធោ ។បេ។ សត្តា ឌេវមនុស្សាឆំ ពុទ្ធោ ភគវា ឆម្មោ ច ឆ ឌេសិយតិ ឧបសមិតោ បរិនិព្ពានិតោ សម្ពោឆគាមី សុភតប្បវេឌិតោ អយញ្ច បុក្ខលោ មជ្ឈិមេសុ ឆនបឌេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ បញ្ញវា អឆឌ្ឍោ អឌេឧ្បម្ងតោ បដិ៣លោ សុភាសិតទុព្ភាសិតស្ស អត្តមញ្ញាតុំ ។ អយំ កិក្ខវេ អដ្ឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ ឥមេ ខោ កិក្ខវេ អដ្ឋ អក្ខណា អសមយា ព្រហ្ម-ចរិយវាសាយ ។ ឯកោ ច ខោ កិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ ។ កតមោ ឯកោ ។

ជាមនុស្សគ្រ មិនអង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិតនឹងទុញ្ញសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្ម-
ចារ្យទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ឆ្ងាយ
ចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គ ។បេ។
ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច
មានដំណើរទៅកាន់ត្រែកពង្គាក់ចោលហើយ មិនកើតឡើងក្នុងលោក
ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីព្រះនិញ្វន ជា
ដំណើរ ដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគត ទ្រង់ប្រកាសទុក
ព្រះអង្គក៏មិនបានសំដែង បុគ្គលនេះ បានកើតក្នុងមជ្ឈិមជនបទ ក៏ឯបុគ្គល
នោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ្រ អង់អាច
ដើម្បីដឹងសេចក្តីនៃសុភាសិត នឹងទុញ្ញសិតបាន ។ ម្នាលភិក្ខុទាំងឡាយ
នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ៨ ។ ម្នាល
ភិក្ខុទាំងឡាយ អក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យមាន
៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ខណៈ នឹងសម័យ
នៃការនៅប្រព្រឹត្តព្រហ្មចារ្យ មានតែមួយ ។ មួយតើដូចម្តេច ។

៥ ឆ កិត្តាវេ តថាគតោ លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ឆឡេ ច ឆេសិយតិ ឧបសមិតោ បរិនិព្ពានិតោ សម្ពោធគាមី សុគតប្បវេទិតោ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ បញ្ញវា អជឆេឡ អនេឡមូគោ បដិពលោ សុភាសិតទុព្ភាសិតស្ស អត្ថមញ្ញាតុំ ។ អយំ កិត្តាវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយាតិ ។

មនុស្សលោកំ លទ្ធាន សទ្ធម្មេ សុប្បវេទិតេ
យេ ខណំ នាតិក្កន្តិ អតិនាមេន្តិ តេ ខណំ
ពហូហិ អក្ខណា រិត្តា បុគ្គលស្សប្បភាយិកា

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវ
ញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិង
ចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរដោយ
សីលាទិគុណឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានដូច
នាយសារថី ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវ
ចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រែកពន្លាក់ចោលហើយ ឋានកើត
ឡើងក្នុងលោកនេះ ទាំងធម៌ ដែលធ្វើកិលេសឲ្យស្ងួតរម្ងាប់ ប្រព្រឹត្តទៅ
ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រ-
កាសទុក ព្រះអង្គក៏បានសំដែងហើយ ទាំងបុគ្គលនេះបានកើតក្នុងពួកមនុស្ស-
ជនបទ ថែមទាំងបុគ្គលនោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ
អន់អាប ដើម្បីដឹងសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន ។ ម្នាលភិក្ខុ
ទាំងឡាយ នេះជាខណៈនិងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ។

ពួកជនណា បានទូរមនុស្សលោកហើយ (បានកើតជាមនុស្ស)
តែមិនចួបប្រទះនូវខណៈ ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគត
ទ្រង់សំដែងដោយល្អ ជនទាំងនោះ ឈ្មោះថាកន្ទងបង់នូវ
ខណៈ អក្ខណៈទាំងឡាយ ដែលអ្នកប្រាជ្ញទាំងឡាយជា
ច្រើន បានពោលហើយថា ធ្វើនូវសេចក្តីអន្តរាយដល់បុគ្គល

បណ្ណាសកោ ឧហរបតិវត្ថោ

កកជាចំ ករហាចំ លោកេ ឧបប្បជ្ជន្តិ តថាគតា

តយិទំ សម្មុខីភូតំ យំ លោកស្មឹ សុទុល្លភំ

មនុស្សប្បដិលាភោ ច សទ្ធម្មស្ស ច ទេសនា

អលំ ភាយមិតុំ តត្ត អត្តកាមេន ជន្តុនា ។

កថំ វិជញ្ញា សទ្ធម្មំ ខណោ ភវោ ឧបច្ឆគា

ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។

ឥធ ចេ ន វិកាឆេតិ សទ្ធម្មស្ស និយាមិតំ

ភណាជាវ អតីតត្តោ ចិរត្តទុតមិស្សតិ

អវិជ្ជានិព្ភុតោ ចោសោ សទ្ធម្មំ អបរាជិតោ

ជាតិមរណសំសារំ ចិរំ បច្ឆានុភោស្សតិ

បណ្ណាសក គហបតិវគ្គ

ព្រះតថាគតទាំងឡាយ ទ្រង់កើតឡើង ក្នុងលោកម្ដង ។ ការកើតឡើង នៃព្រះតថាគតទាំងឡាយណា ដែលសត្វបានដោយកម្រក្នែរពេក ក្នុងលោក ការកើតឡើងនៃព្រះតថាគតទាំងឡាយនោះ ក៏កើតចំពោះមុខហើយ ការបានអត្តភាពជាមនុស្សផង ការសំដែងនូវព្រះសទ្ធម្មផង (ក៏បានកើតចំពោះមុខហើយ) ជនអ្នកមានសេចក្ដីប្រាថ្នានូវប្រយោជន៍គួរពន្យាយកក្នុងព្រះសទ្ធម្មនោះ ។ បុគ្គលគប្បីដឹងច្បាស់ នូវព្រះសទ្ធម្មដោយហេតុដូចម្ដេច ខណៈកុំកន្ធងនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្ធងហើយ រមែងសង្រេងសង្រែកក្នុងនរកត្រៀបត្រា ។ បើបុគ្គលណា ក្នុងលោកនេះ ញុំាងសេចក្ដីកំណត់នូវព្រះសទ្ធម្ម គឺអរិយមគ្គ មិនឲ្យសម្រេចទេ បុគ្គលនោះជាអ្នកកន្ធងបង់នូវប្រយោជន៍ រមែងសង្រេងសង្រែក អស់កាត្រីយូរ ដូចជាពាណិជ ដែលកន្ធងបង់នូវប្រយោជន៍ ដូច្នោះដែរ សត្វដែលអវិជ្ជា រួបរឹតហើយ មិនញុំាងព្រះសទ្ធម្ម ឲ្យសម្រេចបាន គង់នឹងត្រឡប់មកកាន់សង្សារ គឺការកើតនឹងការស្លាប់ អស់កាលជ័យូរ

យេ ច លទ្ធា មនុស្សត្តំ, សទ្ធម្មេ សុប្បវេទិតេ
អកំសុ សត្ថុ វចនំ ការំសច្ឆិ ការកេឆិ វ
ទ្វេឈំ បច្ចវិតុំ(១) លោកេ ព្រហ្មចរិយំ អនុត្តរំ
យេ មក្កំ បដិបជ្ជិំសុ តថាគតប្បវេទិតំ
យេ សំវរា ចក្ខុមតា នេសិតា ធិច្ចពន្ធុនា
តេសុ ភុត្តោ សទា សតោ វិហរេថ អនាសវោ
សព្ពេ អនុសយេ ឆេត្វា មារឆេយ្យសភានុកេ
តេវ ជារគតា លោកេ យេ បត្តា អាសវក្ខយន្តិ ។

(៣០) ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន អាយស្មា អនុរុទ្ធោ ចេតីសុ វិហរតិ ចាចីនវំសទាយេ ។ អថខោ អាយស្មតោ អនុរុទ្ធស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អប្បិច្ឆស្សាយំ ធម្មោ

---

១. បច្ចវិទ្ធុំ បដិវិជ្ឈិតុំ អដ្ឋកថាយំ ទិស្សតិ ។

មួយទៀត ពួកជនណា ឱនទូរអត្តភាពជាមនុស្ស ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគត សំដែងល្អហើយ ឱនធ្លុះហើយ ទំងធ្លុះ ឬកំពុងធ្លុះ តាមពាក្យនៃព្រះសាស្តា ពួកជនណា ដើរទៅកាន់ផ្លូវ ដែលព្រះតថាគត សំដែងទុកហើយ ពួកជននោះ ឈ្មោះថា ត្រាស់ដឹងនូវខណៈ ទំងព្រហ្មចារ្យដ៏ប្រសើរក្នុងលោក សេចក្តីសង្រ្គមណា ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានចក្ខុ ឱនសំដែងហើយ បុគ្គលមានចិត្តមិនទទឹកដោយកិលេស ជាអ្នកមានស្មារតីគ្រប់កាល គប្បីគ្រប់គ្រងក្នុងសេចក្តីសង្រ្គមទំងនោះ ពួកជនណា ឱនដល់នូវការអស់ទៅនៃអាសវៈ ជនទំងនោះ ឱនកាត់នូវអនុស័យទំងពួង ដែលទៅកាន់សង្សារ ជាលំនៅនៃមារហើយ ដល់នូវត្រើយ គឺព្រះនិព្វាន ក្នុងលោក ។

(៣០) សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកេសកម្ពលវន ជាទីឲ្យនូវអភ័យដល់សត្វទ្រឹគ ដ៏តក្រូងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ ក្នុងសម័យនោះ ព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្នុងចាបីនវន្រ្តាយវន ក្នុងដែនចេតី ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា នេះជាធម៌របស់អ្នកប្រាថ្នាតិច

ឆាយំ ឆម្ភោ មហិច្ឆស្ស, សន្តុដ្ឋស្សាយំ ឆម្ភោ ឆាយំ
ឆម្ភោ អសន្តុដ្ឋស្ស បវិវត្តស្សាយំ ឆម្ភោ ឆាយំ ឆម្ភោ
សង្គណិការាមស្ស អារទ្ធវិរិយស្សាយំ ឆម្ភោ ឆាយំ
ឆម្ភោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ ឆម្ភោ ឆាយំ
ឆម្ភោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ ឆម្ភោ ឆាយំ
ឆម្ភោ អសមាហិតស្ស បញ្ញាតោ អយំ ឆម្ភោ ឆាយំ
ឆម្ភោ ឧប្បញ្ញស្សាតិ ។ អថខោ ភគវា អាយស្មតោ
អនុរុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ
ឆាម ពលវា បុរិសោ សង្ខិញ្ជិតំ វា ពាហំ បសារេយ្យ
បសារិតំ វា ពាហំ សង្ខិញ្ជេយ្យ ឯវមេវ ភគ្គេសុ
សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ អន្តរហិតោ
ចេតីសុ ចាចីនវំសទាយេ អាយស្មតោ អនុរុទ្ធស្ស សម្មុខេ
ចាតុរហោសិ ឯសីធិ ភគវា បញ្ញត្តេ អាសនេ ។

នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន នេះជាធម៌របស់អ្នកសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនសន្តោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ក្នុងការច្របូកច្របល់ដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះអនុរុទ្ធដ៏មានអាយុ ដោយព្រះហឫទ័យនៃព្រះអង្គហើយ ក៏ប្រាត់អំពីកេសកម្ពលវន ជាទីឲ្យនូវអភ័យដល់សត្វម្ចឹគជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ស្រាប់តែមកប្រាកដ ក្នុងទីចំពោះមុខនៃព្រះអនុរុទ្ធដ៏មានអាយុ ក្នុងប្បាចីនវំសទាយវន ក្នុងវែនចេតី ព្រះអង្គទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ដូចជាបុរសមានកំឡាំង លាននូវដៃដែលខ្ជួនបត់ចូល ឬបត់ចូលនូវដៃ ដែលខ្ជួនលាចេញ ដូច្នោះឯង ។

អាយស្មាបិ ខោ អនុរុទ្ធោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច សាធុ សាធុ អនុរុទ្ធ សាធុ ខោ តុំ អនុរុទ្ធ យន្តំ មហាបុរិសវិតក្កំ(១) វិតក្កេសិ អប្បិច្ឆ-សប្បាយំ ឆម្ភោ នាយំ ឆម្ភោ មហិច្ឆស្ស សន្តុដ្ឋសប្បាយំ ឆម្ភោ នាយំ ឆម្ភោ អសន្តុដ្ឋស្ស បវិវិត្តសប្បាយំ ឆម្ភោ នាយំ ឆម្ភោ សង្គណិការាមស្ស អារទ្ធវិរិយសប្បាយំ ឆម្ភោ នាយំ ឆម្ភោ កុសីតស្ស ឧបដ្ឋិតសតិសប្បាយំ ឆម្ភោ នាយំ ឆម្ភោ មុដ្ឋសតិស្ស សមាហិតសប្បាយំ ឆម្ភោ នាយំ ឆម្ភោ អសមាហិតស្ស បញ្ញវតោ អយំ ឆម្ភោ នាយំ ឆម្ភោ ទុប្បញ្ញស្សាតិ ។ តេនហិ តុំ អនុរុទ្ធ ឥមំ អដ្ឋមំ មហាបុរិសវិតក្កំ វិតក្កេសិ ឯកប្បមញ្ញារាមស្ស ឆម្ភោ ឯកប្បមញ្ញរតិនោ នាយំ ឆម្ភោ បមញ្ញារាមស្ស បមញ្ញរតិនោតិ ។

---

១ ម. សត្ត មហាបុរិសវិតក្កេ ។

ព្រះអនុរុទ្ធដ៏មានអាយុ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលអនុរុទ្ធ ប្រពៃហើយ ។ ម្នាលអនុរុទ្ធ អ្នកបានត្រិះរិះ នូវមហាបុរិសវិតក្កៈប្រពៃហើយថា នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន នេះជាធម៌របស់អ្នកសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនសន្តោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ក្នុងការនៅប្រកបព្រមព្រៀងដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ។ ម្នាលអនុរុទ្ធ បើដូច្នោះ អ្នកត្រិះរិះនូវមហាបុរិសវិតក្កៈ ទី ៨ នេះថា នេះជាធម៌របស់អ្នកមានន័យប្រពៃធម៌គឺព្រះនិព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងន័យប្រពៃធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌(១) ជាទីត្រេកអរ អ្នកត្រេកអរក្នុងបបញ្ចធម៌ ។

១- តណ្ហា ទិដ្ឋិ មានៈ ។ អដ្ឋកថា ។

យតោ ខោ តុំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ តុំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។ យតោ ខោ តុំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ តុំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។ យតោ ខោ តុំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ តុំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរិស្សសិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេស្សសិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងច្រឡាំងថាជរាបណា អ្នកនឹងស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈ នឹងវិចារៈ មានបីតិនឹងសុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ជាបនោះ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងច្រឡាំងថាជរាបណា ព្រោះរម្ងាប់នូវវិតក្កៈ នឹងវិចារៈ អ្នកនឹងដល់នូវទុតិយជ្ឈាន ជាធម្មជាត កើតមានកងសន្ដាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធាមានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនឹងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន (ជរាបនោះ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកត្រិះរិះនូវមហាបុរិសវិតក្កៈទាំង៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងច្រឡាំង ជរាបណា អ្នកនឹងប្រកបដោយឧបេក្ខា ព្រោះមានចិត្តនឿយណាយចាកបីតិ មានស្មារតីដឹងខ្លួន សោយនូវសេចក្តីសុខ ដោយនាមកាយ ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គល ដែលកន្លងតតិយជ្ឈាននោះថា បុគ្គលនេះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈាណា អ្នកនឹងដល់នូវតតិយជ្ឈាននោះ (ជរាបនោះ) ។

យតោ ខោ តុំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ តុំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្ពេវ សោមនស្សទោមនស្សានំ អដ្ឋង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធិំ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។ យតោ ខោ តុំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម កុមារស្ស វា កុមារិយា វា ជាតស្ស វា ជាតារត្តានំ ទុស្សានំ ទុស្សករណ្ឌោ ឯវមេវ តេ បំសុកូលចីវរំ ខាយិស្សតិ សន្តដ្ឋស្ស វិហារតោ រតិយា អបរិតស្សាយ ជាសុរិយាភាយ ទុក្កមជាយ និព្ពានស្ស ។ យតោ ខោ តុំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នា ដរាបណា អ្នកនឹងដល់នូវចតុត្ថជ្ឈាន ជាធម្មជាត មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺឧបេក្ខា មានសតិជ័ម្រះដោយឧបេក្ខា ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង អស់ទៅនៃសោមនស្សនឹងទោមនស្សផង (ដរាបនោះ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាទូសម្រាប់ជាក់សំពត់ដ៏ពេញដោយសំពត់ទាំងឡាយ ដែលគេជ្រលក់ដោយពណ៌ផ្សេងៗ របស់គហបតី ឬ គហបតិបុត្ត យ៉ាងណាមិញ បំសុកូលចីវរ ក៏នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីប្រកាន់ព្រះនិព្វាន កាលនោះក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង

ឥមេសញ្ច ចតុន្នំ ឈានានំ អាកិញ្ចញ្ញាយតនសមាបត្តិយា ឯកន្តបដិ-
ច្ចសុខវិហារានំ ឯកាមលាភី ភវិស្សសិ អកិញ្ចលាភី
អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម
ឧបាសកានំ ឧបាសកបុត្តានញ្ច សាលីនំ ឱទនោ
វិចិត្តកាឡកោ អនេកសូបោ អនេកព្យញ្ជនោ ឯវមេវ
តេ បដិសល្លីយតោ លោបភោជនំ ខាយិស្សតិ សន្តុដ្ឋស្ស
វិហារតោ រតិយា អបរិតស្សាយ ជាសុរិយាកាយ ឧក្កម-
ជាយ ឯញ្ជានស្ស ។ យតោ ខោ តំ អនុរុទ្ធ ឥមេ ច
អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ
ឈានានំ អាកិញ្ចញ្ញាយតនសមាបត្តិយា ឯកន្តបដិច្ចសុខវិហារានំ
ឯកាមលាភី ភវិស្សសិ អកិញ្ចលាភី អកសិរលាភី
តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម ឧបាសកានំ ឧបាសក-
បុត្តានញ្ច ក្ខជ្ជការំ ឧល្លិត្តាវលិត្តំ ឯវមេវំ
ឥមស្មិំ ធម្មវិនយេ បដិបជ្ជិស្សតិ ឯវមេវ តេ រុក្ខមូល-
សេនាសនំ ខាយិស្សតិ សន្តុដ្ឋស្ស វិហារតោ រតិយា
អបរិតស្សាយ ជាសុរិយាកាយ ឧក្កមជាយ ឯញ្ជានស្ស ។

ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅកាន់ចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបាយនៃស្រូវសាលីរបស់គហបតី ឬ គហបតិបុត្ត ដែលប្រាសចាកពណ៌ខ្មៅ មានសម្លប្រៃនមុខ មានម្ហូបក្រៀមប្រៃនមុខ យ៉ាងណាមិញ កោជន ជាដុំ ជាពំនូត ទំនប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីបុះកាន់ព្រះនិព្វាន ក្នុងកាលនោះយ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះដែលប្រព្រឹត្តទៅកាន់ចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាផ្ទះកំពូល របស់គហបតី ឬគហបតិបុត្ត ដែលគេលាបខាងក្នុង នឹងខាងក្រៅ មិនមានខ្យល់ (ចេញចូល) មានគន្ធៈដ៏ជិតស្និទ្ធ មានបង្អួចបិទហើយ យ៉ាងណាមិញ រុក្ខមូលសេនាសនៈ ក៏នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីបុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។

យតោ ខោ តំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កា វិតក្កេស្សសិ ឥមេសញ្ច បតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា បល្លង្កោ តោលកតូតោ បដិកតូតោ បដលិកតូតោ កទលិមិគបវរបច្চុត្ថរណោ សឧត្តរច្ឆទោ ឧភតោលោហិតកូបធានោ ឯវមេវ តេ តិណាសន្ថរកសយនាសនំ ខាយិស្សតិ សន្ថដ្ឋស្ស វិហារតោ រតិយា អវិតក្កស្សុយ្យ ជាសុវិហារាយ ឧក្កមនាយ និព្ពានស្ស ។

យតោ ខោ តំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កា វិតក្កេស្សសិ ឥមេសញ្ច បតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អកិច្ឆលាភី អកសិរលាភី

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅកនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបល្ល័ង្ក (គ្រែដែលមានជើងខ្ពស់រិចត្រដោយរូបសត្វសាហាវ) របស់គហបតី ឬ គហបតិបុត្ត ដែលក្រាលដោយព្រំ មានពេមវែងជាន ៤ ជាន់ ដែលក្រាលដោយកម្រាលមានពណ៌ស ដែលធ្វើដោយពេមសត្វ ដែលក្រាលដោយកម្រាលធ្វើដោយពេមសត្វ ជាផ្ទាប់ក្រាមមានកម្រាលដ៏ទត្តម ដែលគេធ្វើដោយស្បែកសត្វឈ្មុស មានខ្នើយមានពណ៌ក្រហម ទាំងពីរខាង គឺខ្នើយក្បាលនឹងខ្នើយជើង ព្រមទាំងពិតាន មានពណ៌ក្រហមពីខាងលើ យ៉ាងណាមិញ ទីដេកនឹងទីអង្គុយដែលធ្វើដោយកម្រាលស្មៅ ក៏នឹងប្រាកដ ដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅកនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង

តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា នានាភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ឱវស្សេយ្យ តេ ឫតិមុត្តភេសជ្ជំ ខាយិស្សតិ សន្តដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឧក្កមនាយ និព្ពានស្ស ។ តេនហិ តុំ អនុរុទ្ធ អាយតិកម្បិ វស្សាវាសំ ឥធេវ ចេតីសុ ចាតីន-រំសនាយេ វិហរេយ្យាសីតិ ។ ឯវំ កន្តេតិ ខោ អាយស្មា អនុរុទ្ធោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មន្តំ អនុរុទ្ធំ ឥមិនា ឱវាទេន ឱវទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឱវមេវ ចេតីសុ ចាតីន-រំសនាយេ អន្តរហិតោ ភគ្គេសុ សុំសុមារគិរេ ភេស-កឡាវនេ មិគទាយេ ចាតុរហោសិ ឯសីឯ ភគវា បញ្ចត្តេ អាសនេ ។ ឯសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ អជ្ជ ភិក្ខវេ មហាបុរិសវិតក្កោ នេសំ សប្បុរិសានំ តំ សុណាថ ។ បេ ។ តតមេ ច ភិក្ខវេ អជ្ជ មហាបុរិសវិតក្កា ។

បណ្ណាសក ឆហបតិវគ្គ

ម្នាលអនុរុទ្ធ ដូចជាកេសដ្ឋៈផ្សេងៗគឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ របស់គហបតី ឬគហបតិបុត្ត យ៉ាងណាមិញ ថ្នាំដែលត្រាំដោយទឹកមូតស្អុយ នឹងធ្វើកដល់អ្នកដែលសន្លោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ បើដូច្នោះ អ្នកគប្បីនៅចាំវស្សាតទៅទៀត ក្នុងចាបីនវិសាយវន ជិតដែនចេតីនេះចុះ ។ ព្រះអនុរុទ្ធដ៏មានអាយុ ទទួលស្តាប់ព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានព្រះអនុរុទ្ធដ៏មានអាយុ ដោយឧបាទាននេះ ហើយក៏ចាត់អំពីចាបីនវិសាយវន ក្នុងដែនចេតី មកធ្វើកដក្នុងកេសកម្ពលវន ជាទីឲ្យនូវអភ័យដល់ពួកសត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ព្រះអង្គគង់លើអាសនៈ ដែលគេក្រាលថ្វាយ ដូចជាបុរសមានកំឡាំង លាដៃដែលខ្ជួចបត់ចូលឬបត់ចូលនូវដៃ ដែលខ្ជួចលាចេញដូច្នោះឯង ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវមហាបុរិសវិតក្កៈ ៨ យ៉ាងដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្តាប់នូវពាក្យនោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាបុរិសវិតក្កៈ ៨ យ៉ាង តើអ្វីខ្លះ ។

អប្បិច្ឆស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ មហិច្ឆស្ស សន្តុដ្ឋស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ អសន្តុដ្ឋស្ស បវិវិត្តស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ សង្គណិ-ការាមស្ស អារទ្ធវីរិយស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ អសមាហិតស្ស បញ្ញវតោ អយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ ទុប្បញ្ញស្ស និប្បបញ្ចារា-មស្សាយំ កិក្ខវេ ធម្មោ និប្បបញ្ចរតិនោ ធាយំ ធម្មោ បបញ្ចារាមស្ស បបញ្ចរតិនោ ។

អប្បិច្ឆស្សាយំ កិក្ខវេ ធម្មោ ធាយំ ធម្មោ មហិច្ឆស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ កិក្ខវេ កិក្ខុ អប្បិច្ឆោ សមានោ

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌
របស់អ្នកប្រាថ្នាច្រើន ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាន
សេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោស ១
ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នក
ត្រេកអរដោយពួក ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធ
សេចក្តីព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស ១ ម្នាលភិក្ខុទាំង
ឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់
អ្នកភ្លេចស្មារតី ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំង
មាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ ១ ម្នាលភិក្ខុទាំង
ឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥត
ប្រាជ្ញា ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ គឺព្រះ
និព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌
របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ ១ ។

ឯពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច
នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើនដូច្នេះនេះ ដែលតថាគតពោល
ហើយ ពាក្យនុ៎ះដែលតថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូច
ម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាតិច

អប្បិច្ឆោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ សន្តុដ្ឋោ សមានោ
សន្តុដ្ឋោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ បវិវិត្តោ សមានោ
បវិវិត្តោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ អារទ្ធវីរិយោ សមានោ
អារទ្ធវីរិយោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ ឧបដ្ឋិតស្សតិ
សមានោ ឧបដ្ឋិតស្សតីតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ សមា-
ហិតោ សមានោ សមាហិតោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ
បញ្ញវា សមានោ បញ្ញវាតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ
និប្បបញ្ចារាមោ សមានោ និប្បបញ្ចារាមោតិ មំ ជានេ-
យ្យុន្តិ ន ឥច្ឆតិ ។ អប្បិច្ឆស្សាយំ ភិក្ខវេ ធម្មោ ឆាយំ
ធម្មោ មហិច្ឆស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកប្រាថ្នាតិចដូច្នេះ ជាអ្នកមានសេចក្តីសន្តោស វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានសេចក្តីសន្តោសដូច្នេះ ជាអ្នកស្ងាត់ វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកស្ងាត់ដូច្នេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកប្រារព្ធសេចក្តីព្យាយាម ដូច្នេះ ជាអ្នកមានស្មារតីខ្ជាប់ខ្ជួន វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានស្មារតីខ្ជាប់ខ្ជួនដូច្នេះ ជាអ្នកមានចិត្តតាំងមាំ វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានចិត្តតាំងមាំ ដូច្នេះ ជាអ្នកមានប្រាជ្ញា វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានប្រាជ្ញា ដូច្នេះ ជាអ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ វមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរដូច្នេះ ។ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើនដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

សន្តុដ្ឋស្សាយំ ភិក្ខវេ ឆម្ភោ ឆាយំ ឆម្ភោ អសន្តុដ្ឋស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន សន្តុដ្ឋស្សាយំ ភិក្ខវេ ឆម្ភោ ឆាយំ ឆម្ភោ អសន្តុដ្ឋស្សាតិ ឥតិ យទំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

បវិវិត្តស្សាយំ ភិក្ខវេ ឆម្ភោ ឆាយំ ឆម្ភោ សង្គណិការាមស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហារតោ ភវន្តិ ឧបសង្កមិតារោ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ រាជានោ រាជមហាមត្តា តិត្ថិយា តិត្ថិយសាវកា ។ តត្រ ភិក្ខុ វិវេកនិន្នេន ចិត្តេន វិវេកោណេន វិវេកបព្ភារេន វិវេកដ្ឋេន នេក្ខម្មាភិរតេន

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោសដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារតាមមាន តាមបាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោសដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌ របស់អ្នកត្រេកអរ ដោយពួកដូច្នេះនេះ ដែលតថាគតពោលហើយពាក្យនុ៎ះតថាគត ពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់នៅ មានពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា មហាមាត្យរបស់ព្រះរាជា តិរ្ថិយ និងសាវករបស់តិរ្ថិយ រមែងចូលទៅរកភិក្ខុនោះ ។ ក្នុងកាលនោះ ភិក្ខុមានចិត្តខ្ពុនទៅរកវិវេក ឈានទៅរកវិវេក ចៃរទៅរកវិវេក ជំពប់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម

អញ្ញទត្ថុ ឧយ្យោជនិកបដិសំយុត្តំយេវ កថំ កត្តា ហោតិ បរិវិត្តសច្ឆាយំ តិក្ខវ ឆម្នោ ឆាយំ ឆម្នោ សច្ចំណាកោរមសច្ចតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

អារទ្ធវិរិយសច្ឆាយំ តិក្ខវ ឆម្នោ ឆាយំ ឆម្នោ កុសីតសច្ចតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ តិក្ខវ តិក្ខ អារទ្ធវិរិយោ វិហរតិ អកុសលានំ ឆម្នានំ បហានាយ កុសលានំ ឆម្នានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តឆុរោ កុសលេសុ ធម្មេសុ អារទ្ធវិរិយសច្ឆាយំ តិក្ខវ ឆម្នោ ឆាយំ ឆម្នោ កុសីត-សច្ចតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ឧបដ្ឋិតសតិសច្ឆាយំ តិក្ខវ ឆម្នោ ឆាយំ ឆម្នោ មុដ្ឋ-សតិសច្ចតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ជាអ្នកធ្វើតាមនូវពាក្យ ដែលប្រកបចំពោះដោយពាក្យ ដែលគួរបញ្ជូនទៅ ដោយពិត ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរដោយពួកជូរច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូសដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ ដើម្បីញុំាងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកំឡាំង មានសេចក្តីប្រឹងប្រែងមាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូសដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតីដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

៨ឆ កិត្តាវ កិត្តា សតិមា ហោតិ បរមេន សតិនេបក្កេន
សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា
ឧបដ្ឋិតសតិសម្ពោជ្ឈង្គំ កិត្តាវ ឆម្ភោ ឆាយំ ឆម្ភោ
មុដ្ឋសតិសម្ពោជ្ឈង្គំ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

សមាហិតសម្ពោជ្ឈង្គំ កិត្តាវ ឆម្ភោ ឆាយំ ឆម្ភោ
អសមាហិតសម្ពោជ្ឈង្គំ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ
បដិច្ច វុត្តំ ។ ៨ឆ កិត្តាវ កិត្តា ភិយ្យោ កាមេហិ ។ បេ ។
ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ សមាហិតសម្ពោជ្ឈង្គំ
កិត្តាវ ឆម្ភោ ឆាយំ ឆម្ភោ អសមាហិតសម្ពោជ្ឈង្គំ ឥតិ
យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

បញ្ចវតោ អយំ កិត្តាវ ឆម្ភោ ឆាយំ ឆម្ភោ ឧបេក្ខា-
ញ្ញសម្ពោជ្ឈង្គំ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី ទំនាក់ទំនងជាអ្នកមានប្រាជ្ញាថ្លាឆ្លាតក្លាដ៏ខ្ពង់ខ្ពស់ ទំកឃើញ រឭកបានរឿយ ។ នូវអំពើដែលធ្វើរួចយូរហើយផង នូវសំដីដែលនិយាយរួចយូរហើយផង ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្លាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកក្ងេចស្មារតីដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌ របស់អ្នកមានចិត្តមិនតាំងមាំដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ សូម្បីស្ងាត់ចាកកាមទាំងឡាយ ។ បេ ។ ដល់នូវចតុត្ថជ្ឈាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌ របស់អ្នកឥតប្រាជ្ញាដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

๙๘ ភិក្ខវេ ភិក្ខុ បញ្ចហ ភោគេ ខុទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា បញ្ញាយ អយំ ភិក្ខវេ ឆម្ហោ ឆាយំ ឆម្ហោ ទុប្បញ្ញស្សាតិ ๙តិ យត្ថំ វុត្តំ ๙ឆមេតំ បដិច្ច វុត្តំ ។

និប្បបញ្ចាភសប្បាយំ ភិក្ខវេ ឆម្ហោ និប្បបញ្ចាតោ ឆាយំ ឆម្ហោ បបញ្ចាភសប្ប បបញ្ចាតោតិ ๙តិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ๙ឆ ភិក្ខវេ ភិក្ខុនោ បបញ្ចនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ និប្បបញ្ចាភសប្បាយំ ភិក្ខវេ ឆម្ហោ និប្បបញ្ចាតោ ឆាយំ ឆម្ហោ បបញ្ចាភសប្ប បប-ញ្ចាតោតិ ๙តិ យត្ថំ វុត្តំ ๙ឆមេតំ បដិច្ច វុត្តន្តិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុកងឹសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាដំណើរទៅកាន់សេចក្តីចំរើន នឹងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងត្រាស់ដឹង ជាដំណើរទៅកាន់ការអស់ទៅនៃទុក្ខដោយប្រពៃ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញាដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់ភិក្ខុកងឹសាសនានេះ រមែងស្ទុះទៅ រមែងជ្រះថ្លា រមែងតាំងនៅ រមែងបង្អោនទៅក្នុងកិរិយារលត់នៃបបញ្ចធម៌ គឺព្រះនិព្វាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

អដ្ឋខោ អាយស្មា អនុរុទ្ធោ អាយតិកម្បិ វិស្សជ្ជាសិ តត្ថេវ ចេតីសុ ចាចីនវំសទាយេ វិហាសិ ។ អដ្ឋខោ អាយស្មា អនុរុទ្ធោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្ភជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ អញ្ញតរោ ច បនាយស្មា អនុរុទ្ធោ អរហតំ អហោសិ ។ អដ្ឋខោ អាយស្មា អនុរុទ្ធោ អរហត្តប្បត្តោ តាយំ វេលាយំ ឥមា គាថាយោ អភាសិ

មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
មនោមយេន កាយេន ឥទ្ធិយា ឧបសង្កមិ

គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ កំនៅចាំវស្សាតទៅ ក្នុងជាចីនវាសៈ-
ភាយវន ក្នុងដែនចេតីនោះឯង ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុតែម្នាក់
ឯង ចៀសចេញចាកពួក មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកំដៅ
កិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះចូល
កាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន
លោកក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុត
នោះ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់ថា ជាតិអស់
ហើយ ព្រហ្មចរិយធម៌ បាននៅរួចហើយ សោឡសកិច្ច បានធ្វើរួច
ហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ មិនមាន
ទៀតឡើយ មានសេចក្តីសរសើរថា បណ្តាព្រះអរហន្តទាំងឡាយ ព្រះអ-
នុរុទ្ធដ៏មានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។ លុះព្រះអនុរុទ្ធដ៏មាន
អាយុ បានដល់ព្រះអរហត្តហើយ បានពោលគាថាទាំងឡាយនេះ
ក្នុងវេលានោះថា

ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គទ្រង់
ជ្រាបច្បាស់នូវសេចក្តីត្រិះរិះ របស់អាត្មាអញ ទ្រង់មាន
កាយសម្រេចដោយចិត្ត ទ្រង់ស្តេចចូលមក ដោយឫទ្ធិ

បណ្ណាសកេ ឆហបតិវគ្គោ

យថា មេ អហុ សង្កប្បោ តតោ ឧត្តរិ នេសយិ
និប្បបញ្ចរតោ ពុទ្ធោ និប្បបញ្ចំ អនេសយិ
តស្សហំ ធម្មមញ្ញាយ វិហាសឹ សាសនេ រតោ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

ឆហបតិវគ្គោ តតិយោ ។

តស្សុទ្ទានំ ភវតិ

ទ្វេ ឧក្កា ទ្វេ ច ហត្ថកា មហានាមេន ជីវកោ
ទ្វេ ពលា អក្ខណា វុត្តា អនុរុទ្ធេន តេ ឧសាតិ ។

បណ្ណាសក ធម្មបតវគ្គ

តម្រិះរបស់អាត្មាអញ កើតមានយ៉ាងណា ព្រះអង្គក៏ទ្រង់សំដែងនូវធម៌ដ៏លើសលុបយ៉ាងនោះ ព្រះពុទ្ធទ្រង់ត្រេកអរក្នុងនិប្បបញ្ចធម៌ ក៏ទ្រង់សំដែងនូវនិប្បបញ្ចធម៌ អាត្មាអញបានដឹងច្បាស់នូវធម៌របស់ព្រះអង្គ ក៏ត្រេកអរ ក្នុងសាសនាវិជ្ជាទាំង ៣ អាត្មាអញក៏ប្រាសចេញហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញ ក៏បានធ្វើហើយ ។

ចប់ ធម្មបតវគ្គ ទី ៣ ។

ទុកានដែលគម្ពីរគូសោះគឺ

និយាយអំពីទុគ្គតិ ពីរលើក ហត្ថកអាឡវកៈពីរលើក សក្កមហានាម ១ ជីវកកោមារភច្ច ១ កុមារកស្សបៈពីរលើក អក្ខណៈ ១ ជាតំរប់ ១០ នឹងព្រះអនុរុទ្ធ ។

ទានវគ្គោ

(៣១) អដ្ឋិមានិ កិត្តកវេ ទានានិ ។ កតមានិ អដ្ឋ ។ អាសជ្ជ ទានំ ទេតិ ភយា ទានំ ទេតិ អទាសិ មេតិ ទានំ ទេតិ ទស្សតិ មេតិ ទានំ ទេតិ សាធុ ទានន្តិ ទានំ ទេតិ អហំ បចាមិ ឥមេ ន បចន្តិ ឆារហាមិ បចន្តោ អបចន្តានំ ទានំ ន ទាតុន្តិ(១) ទានំ ទេតិ ឥមំ មេ ទានំ ទទតោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតីតិ ទានំ ទេតិ ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ ។ ឥមានិ ខោ កិត្តកវេ អដ្ឋ ទានានីតិ ។

(៣២) សទ្ធា ហិរិយំ កុសលញ្ច ទានំ
ធម្មា ឯតេ សប្បុរិសានុយាតា
ឯតញ្ហិ មគ្គំ ធិរិយំ វទន្តិ
ឯតេន ហិ គច្ឆតិ ទេវលោកន្តិ ។

(៣៣) អដ្ឋិមានិ កិត្តកវេ ទានវត្ថូនិ ។ កតមានិ អដ្ឋ ។ ធម្មោ ទានំ ទេតិ ធោសា ទានំ ទេតិ មោហា ទានំ ទេតិ ភយា ទានំ ទេតិ

---

១ ម. អទាតុន្តិ ។

ទានវត្ថុ

(៣១) ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ៨ យ៉ាង ។ ទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះបានចាត់ចែងទុកស្រេច ១ ឲ្យទាន ព្រោះភ័យ ១ ឲ្យទានដោយគិតថា គេបានឲ្យដល់អញ ១ ឲ្យទានដោយគិតថា គេនឹងឲ្យដល់អញវិញ ១ ឲ្យទានដោយគិតថា ទានជាការប្រពៃ ១ ឲ្យទានដោយគិតថា អញចំអិន បុគ្គលទាំងឡាយនេះ មិនទាន់ចំអិន អញកាលចំអិន មិនគួរ ដើម្បីមិនឲ្យទានដល់បុគ្គលមិនទាន់ចំអិន ១ ឲ្យទានដោយគិតថា កាលបើអញឲ្យនូវទាននេះ កិត្តិស័ព្ទដ៏ពីរោះរមែងខ្ចរខ្ចាយ ៧ ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត នឹងជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទានមាន ៨ យ៉ាងនេះឯង ។

(៣២) សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះ

ជាធម៌តាំងនៅក្នុងពួកសប្បុរស សប្បុរសទាំងឡាយ តែង

ពោលនូវធម៌នេះថាជាផ្លូវទៅកាន់ទេវលោក ព្រោះថាបុគ្គល

តែងទៅកាន់ទេវលោកបានដោយធម៌នេះ ។

(៣៣) ម្នាលភិក្ខុទាំងឡាយ ទានវត្ថុនេះមាន ៨ យ៉ាង ។ ទានវត្ថុ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះសេចក្តីស្រឡាញ់ ១ ឲ្យទានព្រោះសេចក្តីឯង ១ ឲ្យទានព្រោះសេចក្តីល្ងង់ ១ ឲ្យទានព្រោះសេចក្តីភ័យ ១

និន្នបុព្ពំ កតបុព្ពំ បិតុបិតាមហោហិ ជារហាសិ ភោគណ្ហំ
កុលវំសំ ហាបេតុន្តិ ទានំ ទេតិ ឥមាហំ ទានំ ទត្វា
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបជ្ជិស្សាមីតិ ទានំ ទេតិ ឥមំ មេ ទានំ ទទតោ
ចិត្តំ បសីទតិ អត្តមនតា សោមនស្សំ ឧបជាយតីតិ
ទានំ ទេតិ ចិត្តាលង្ការចិត្តបរិក្ខារត្តំ ទានំ ទេតិ ។
ឥមានិ ខោ ភិក្ខវេ អដ្ឋ ទានវត្ថូនីតិ ។

(៣៤) អដ្ឋង្គសមន្នាគតេ ភិក្ខវេ ខេត្តេ ពីជំ វុត្តំ ឧ
បហរច្ចលំ ហោតិ ឧ មហាសច្ចំ ឧ ជាតិសេយ្យន្តិ ។ កតំ
អដ្ឋង្គសមន្នាគតេ ។ ឥធ ភិក្ខវេ ខេត្តំ ឧច្ចមិនិច្ចាមិ ច
ហោតិ ទាសាណាសក្ខរិល្យញ្ច ហោតិ ឧសរញ្ច ហោតិ ឧ
ច កម្ពីរសិតំ ហោតិ ឧ អាយសម្បន្នំ ហោតិ ឧ អទាយ-
សម្បន្នំ ហោតិ ឧ មាតិកាសម្បន្នំ ហោតិ ឧ មរិយាទស-
ម្បន្នំ ហោតិ ។ ឯវំ អដ្ឋង្គសមន្នាគតេ ភិក្ខវេ ខេត្តេ ពីជំ
វុត្តំ ឧ មហប្ផលំ ហោតិ ឧ មហាសច្ចំ ឧ ជាតិសេយ្យន្តិ ។

ឲ្យទានព្រោះគិតថា ជីដូនជីតាទាំង៦ឆ្ងាយ (របស់អញ) ធ្លាប់ឲ្យ ធ្លាប់ធ្វើមក អញមិនគួរញុំាងវង្សត្រកូល ពីបូពាណ៌ុះឲ្យវិនាស ១ ឲ្យទានព្រោះគិតថា អញបានឲ្យទាននេះ លុះបែកធ្លាយពាង៥កាយ ស្ងាប់ទៅ ទើបទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ឲ្យទានព្រោះគិតថា កាលអញឲ្យទាននេះ ចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្តទើបសោមនស្ស កំរមែងកើតឡើង ១ ឲ្យទាន ដើម្បីជាគ្រឿងប្រដាប់នៃចិត្តទើបជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំង៦ឆ្ងាយ ទានវត្ថុមាន ៨ យ៉ាងនេះឯង ។

(៣៤) ម្នាលភិក្ខុទាំង៦ឆ្ងាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ ជាពូជមិនមានផលច្រើន មិនមានសេចក្តីត្រេកអរច្រើន មិនចំរើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលភិក្ខុទាំង៦ឆ្ងាយ ស្រែក្នុងលោកនេះ ជាស្រែមានទីលូខ្វះ ទីទំនាបខ្វះ ១ មានថ្មទឹងក្រួស ១ មានទំកប្រៃ ១ គន្ធង៨ន្លឹមិនជ្រៅ ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចូល ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចេញ ១ មិនបរិបូណ៌ដោយប្រឡាយទឹក ១ មិនបរិបូណ៌ដោយភ្ជឺ ១ ។ ម្នាលភិក្ខុទាំង៦ឆ្ងាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពូជមិនមានផលច្រើន មិនមានសេចក្តីត្រេកអរច្រើន មិនចំរើនទេ ។

ឃរមេវ ខោ តិក្ខវេ អដ្ឋង្គសមន្នាគតេសុ សមណ-ព្រាហ្មណេសុ ទានំ ទិន្នំ ន មហប្ផលំ ហោតិ ន មហានិសំសំ ន មហាជុតិកំ ន មហាវិប្ផារំ ។ កថំ អដ្ឋង្គសមន្នាគតេសុ ។ ឥធ តិក្ខវេ សមណព្រាហ្មណា មិច្ឆាទិដ្ឋិកា ហោន្តិ មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆា-កម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតិនោ មិច្ឆាសមាធិនោ ។ ឃរំ អដ្ឋង្គសមន្នាគតេសុ តិក្ខវេ សមណព្រាហ្មណេសុ ទានំ ទិន្នំ ន មហប្ផលំ ហោតិ ន មហានិសំសំ ន មហាជុតិកំ ន មហាវិប្ផារំ ។

អដ្ឋង្គសមន្នាគតេ ច តិក្ខវេ ខេត្តេ ពីជំ រុត្តំ មហប្ផលំ ហោតិ មហាវិប្ផារំ ជាតិសេយ្យន្តិ ។ កថំ អដ្ឋង្គសមន្នាគតេ ។ ឥធ តិក្ខវេ ខេត្តំ អនុទ្ធមិនិច្ចាមិច ហោតិ អចាសាណាសក្ខរិល្ឡញ្ច ហោតិ អន្ធសរញ្ច ហោតិ កម្ពីរសិតំ ហោតិ អាយសម្បន្នំ ហោតិ អចាយសម្បន្នំ ហោតិ មាតិកាសម្បន្នំ ហោតិ បរិយាទសម្បន្នំ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យ ចំពោះពួកសមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកយល់ឃើញខុស ១ ត្រិះរិះខុស ១ និយាយខុស ១ ធ្វើការងារខុស ១ ចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ នឹករលឹកខុស ១ តាំងចិត្តខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ។

ម្នាលភិក្ខុទាំងឡាយ ចំណែកខាងពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ ទើបជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចំរើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្រែក្នុងលោកនេះ មិនមានទីទួលខ្ទះប្តូទីទំនាបខ្ទះ ១ មិនមានថ្មទឹងក្រួស ១ មិនមានទឹកប្រៃ ១ មានគន្លងនង្គ័លជ្រៅ ១ បរិបូណ៌ដោយផ្លូវទឹក សម្រាប់បញ្ចូល ១ បរិបូណ៌ដោយផ្លូវទឹក សម្រាប់បញ្ចេញ ១ បរិបូណ៌ដោយប្រឡាយទឹក ១ បរិបូណ៌ដោយភ្ជឹ ១ ។

ឯវំ អដ្ឋង្គសមន្នាគតេ កិក្ខវេ ខេត្តេ ពីជំ វុត្តំ មហាផលំ ហោតិ មហានិសំសំ ជាតិសេយ្យន្តិ ។ ឯវមេវ ខោ កិក្ខវេ អដ្ឋង្គសមន្នាគតេសុ សមណព្រាហ្មណេសុ ទានំ ទិន្នំ មហាផលំ ហោតិ មហានិសំសំ មហាជុតិកំ មហាវិប្ផារំ ។ កតមំ អដ្ឋង្គសមន្នាគតេសុ ។ ឥធ កិក្ខវេ សមណព្រាហ្មណា សម្មាទិដ្ឋិកា ហោន្តិ សម្មាសង្កប្បា សម្មាវាចា សម្មាកម្មន្តា សម្មាអាជីវា សម្មាវាយាមា សម្មាសតិនោ សម្មាសមាធិនោ ។ ឯវំ អដ្ឋង្គសមន្នាគតេសុ កិក្ខវេ សមណព្រាហ្មណេសុ ទានំ ទិន្នំ មហាផលំ ហោតិ មហានិសំសំ មហាជុតិកំ មហាវិប្ផារន្តិ ។

យថាបិ ខេត្តេ សម្បន្នេ បវុត្តា ពីជសម្បទា
ទេវេ សម្មាធយន្តម្ហិ ហោតិ ឆញ្ញាយ សម្បទា
អនីតិសម្បទា ហោតិ រិទ្ធិ ភវតិ សម្បទា
វិបុលំ សម្បទា ហោតិ ផលំ ហោតិ សម្បទា ។

បណ្ណាសក ទានវគ្គ

ម្នាលភិក្ខុទាំងឡាយ ពួជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពួជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចំរើន ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យហើយ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ ជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សុយសៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ ប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ ក្នុងលោកនេះ ជាអ្នកយល់ឃើញត្រូវ ១ ត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ នឹកឃើញត្រូវ ១ តាំងចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យហើយ ចំពោះពួកសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ទើបជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សុយសៅច្រើន ។

ពួជដ៏បរិបូណ៌ ដែលគេសាបព្រោះ ក្នុងស្រែដ៏ល្អ កាលបើមានភ្លៀងស្រួល ការបរិបូណ៌ ដោយគ្រាប់ស្រូវ ក៏រមែងមាន គឺបរិបូណ៌ ដោយការមិនអន្តរាយ ១ ការចំរើនទ្បើង បរិបូណ៌ ១ ការលូតលាស់ បរិបូណ៌ ១ ផ្លែហ្មឹងឯង បរិបូណ៌ ១ មានឧបមាយ៉ាងណាមិញ ។

ឯវំ សម្បន្នសីលេសុ និដ្ឋា ភោជនសម្បទា

សម្បទានំ ឧបនេតិ សម្បន្នំ ហិស្ស តំ កតំ

តស្មា សម្បន្នមាកង្ខី សម្បន្នត្តញ បុក្កលោ(១)

សម្បន្នបញ្ញោ សេវេថ ឯវំ ឥជ្ឈន្តិ សម្បទា ។

វិជ្ជាចរណសម្បន្នោ លទ្ធា ចិត្តស្ស សម្បទា

ករោតិ កម្មសម្បន្នំ លភតិ ចត្តសម្បន្នំ ។

លោកំ ញត្វា យថាភូតំ បបញ្ចយ្យ និដ្ឋិសម្បន្នំ

បក្កសម្បន្នមាកម្ម យាតិ សម្បន្នមានសោ ។

ខុជ្ជនិត្វា មលំ សព្ពំ បត្វា និព្ពានសម្បទំ

មុច្ចតិ សព្ពទុក្ខេហិ សា ហោតិ សព្ពសម្បទាតិ ។

(៣៩) អដ្ឋិមា កិក្ខវេ ធាត្វូបបត្តិយោ ។ កតមា អដ្ឋ ។

---

១ ម. សម្បន្នត្តោធ បុគ្គលោ ។

កោដនដ៏បរិបូណ៌ ដែលបុគ្គលឲ្យហើយ ចំពោះពួកបុគ្គលមានសីលបរិបូណ៌ រមែងញុំាងចំណែកកុសលឲ្យកើតឡើង កុសលកម្មដែលបុគ្គលនោះធ្វើហើយ ឈ្មោះថាកម្មដ៏បរិបូណ៌ មានទុបមេយ្យយ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលកន្លងលោកនេះ ជាអ្នកបរិបូណ៌ មានប្រាថ្នាន្លួសេចក្តីបរិបូណ៌ គួរសេពគប់នូវបុគ្គលដែលមានបញ្ញាដ៏បរិបូណ៌ ការបរិបូណ៌ រមែងសម្រេចយ៉ាងនេះឯង ។ បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជា និងចរណៈ បាននូវសេចក្តីបរិបូណ៌នៃចិត្ត រមែងធ្វើនូវកម្ម ដ៏បរិបូណ៌ផង បាននូវប្រយោជន៍ក៏បរិបូណ៌ ។ បុគ្គលដឹងច្បាស់នូវសត្វលោក តាមសេចក្តីពិត រមែងសម្រេចនូវវិមុត្តិសម្ញាដ៏ដ៏បរិបូណ៌ បុគ្គលអាស្រ័យនូវមគ្គដ៏បរិបូណ៌ មានចិត្តដ៏បរិបូណ៌ រមែងដល់នូវ (ព្រះអរហត្ត) ។ បុគ្គលកំចាត់បង់នូវមន្ទិលទាំងពួង ដល់នូវព្រះនិព្វាន ដ៏បរិបូណ៌ រមែងរួចចាកទុក្ខទាំងពួង ការរួចចាកទុក្ខនោះឯង ទើបឈ្មោះថា សេចក្តីបរិបូណ៌ត្រង់យ៉ាង ។

(៣៩) ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទាននេះ មាន ៨ យ៉ាង ។ ការកើតឡើងនៃទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។

៩ឆ កិត្តាវេ ឯកច្ចោ ទានំ ទេតិ សមណាសប្ប ឯ ព្រាហ្មណាសប្ប ឯ អន្ធំ ទានំ វត្តំ យានំ មាលាគន្ធ-វិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសីសតិ សោ បស្សតិ ខត្តិយមហាសាលេ ឯ ព្រាហ្មណមហាសាលេ ឯ គហបតិមហាសាលេ ឯ បញ្ចហិ កាមគុណេហិ សមប្បិតេ សមង្គីភូតេ បរិចារយមានេ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ ឯ ព្រាហ្មណមហាសាលានំ ឯ គហបតិមហាសាលានំ ឯ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ បឋមតំ តំ ចិត្តំ អនុដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេនិមុត្តំ ឧត្តរិ អភាវិតំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ ឯ ព្រាហ្មណមហាសាលានំ ឯ គហបតិមហាសាលានំ ឯ សហព្យតំ ឧបបជ្ជតិ តញ្ហិ ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស ។ ឆជ្ឈតិ កិត្តាវេ សីលវតោ ចេតោបណិធិ សុទ្ធត្តា[1] ។

---

១ ខ. វិសុទ្ធត្តា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានដំនិះ កំរងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យ នៅ គ្រឿងប្រដាប់ ប្រទីប ជាទាន ដល់សមណៈឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ ទេវតាទាំងនោះ ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ ដែលកំពុងដឹងច្បាស់ស្គាល់ មូលមត្រ បំពេញដោយគុណទាំង ៥ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឥហ អញលុះបែកធ្លាយរាងកាយ ស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ ដែលជាមួយនឹងទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ បុគ្គលនោះ ក៏ដំកល់ចិត្តនោះ អធិដ្ឋានចិត្តនោះ បំពេនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងតាមគុណដ៏ថោកទាប មិនបានចំពេនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ ដែលជាមួយនឹងពួកទេវតាថ្នាក់ចាតុម្មហារាជិកា ត្រៃត្តឹង្សា យាមា តុសិតា និម្មានរតី បរនិម្មិតវសវត្តី ព្រហ្មកាយិកា ព្រហ្មបុរោហិតា មហាព្រហ្មា បរិត្តាភា អប្បមាណាភា អាភស្សរា បរិត្តសុភា អប្បមាណសុភា សុភកិណ្ហា វេហប្ផលា អសញ្ញសត្តា អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា អាកាសានញ្ចាយតនូបគ វិញ្ញាណញ្ចាយតនូបគ អាកិញ្ចញ្ញាយតនូបគ នេវសញ្ញានាសញ្ញាយតនូបគ ដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ១ ។

៩ឆ បន ភិក្ខវេ ឯកច្ចេ ធានំ នេតិ សមណស្ស
វា ព្រាហ្មណស្ស វា អន្នំ ធានំ វត្ថំ យានំ មាលា-
គន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ យំ នេតិ
តំ បច្ចាសីសតិ តស្ស សុតំ ហោតិ ចាតុម្មហារ-
ជិកា នេវ ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ
តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា
បរម្មរណា ចាតុម្មហារជិកានំ នេវនំ សហព្យតំ
ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ បឧហតិ តំ ចិត្តំ អធិដ្ឋាតិ
តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេធិមុត្តំ ឧត្តរឹ អភា-
វិតំ កាយស្ស ភេទា បរម្មរណា ចាតុម្មហារជិកានំ
នេវនំ សហព្យតំ ឧបបជ្ជតិ តញ្ច ខោ សីលវតោ
វាធម៌ នោ ឧុស្សីលស្ស ឥជ្ឈតិ ភិក្ខវេ សីលវតោ
ចេតោបណិធិ សុទ្ធត្តា ។ ៩ឆ បន ភិក្ខវេ ឯកច្ចេ
ធានំ នេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ ធានំ
វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានដំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ ឮគេថា ពួកទេវតាចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរស្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះបែកធ្លាយពងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ បុគ្គលនោះ ដម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចំរើនចិត្តនោះ ចិត្តរបស់បុគ្គលនោះក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចំរើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយពងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីលរមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានដំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍

សោ យំ នេតំ តំ បច្ចាសីសតិ តស្ស សុតំ ហោតំ តាវត្តឹសា នេវ ។ បេ ។ យាមា នេវ... តុសិតា នេវ... និម្មានរតី នេវ... បរនិម្មិតវសវត្តី នេវ ធីយា-យុកោ វណ្ណវន្តោ សុខពហុលាតំ តស្ស វាំ ហោតំ អហោ វតាមំ កាយស្ស ភេទា បរម្មរណា បរនិ-ម្មិតវសវត្តីនំ នេវនំ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ បទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេនិម្មុត្តំ ឧត្តរឹ អភាវិតំ កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ នេវនំ សហព្យតំ ឧបបជ្ជតិ តញ្ហ ខោ សីលវតោ វទាមិ នោ ទុស្សី-លស្ស ឥជ្ឈតិ កិក្ខវេ សីលវតោ ចេតោបណិធិ សុទ្ធត្តា ។ ឥធ បន កិក្ខវេ ឯកច្ចោ ឆានំ នេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ ឆានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ

បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតា តាវត្តិង្ស ។ បេ ។ ពួកទេវតាយាមៈ ... ពួកទេវតាតុសិត ... ពួកទេវតានិម្មានតី ... ពួកទេវតា បរនិម្មិតវសវត្តី មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី បុគ្គលនោះ ដម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចំរើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចំរើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានដំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍

សោ យំ នេតំ តំ បច្ចាសីសតិ តស្ស សុតំ ហោតិ ព្រហ្មកាយិកា នេវ ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ តស្ស ឯវំ ហោតិ អហោ វតាមំ កាយស្ស ភេទា បរម្មរណា ព្រហ្មកាយិកានំ នេវនំ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ បនេហិតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេនិមុត្តំ ឧត្តរិំ អភាវិតំ កាយស្ស ភេទា បរម្មរណា ព្រហ្មកាយិកានំ នេវនំ សហព្យតំ ឧបបជ្ជតិ តញ្ហេ សីលវាតោ វទាមិ នោ ឧស្សីលស្ស វីតរាគស្ស នោ សរាគស្ស ឥជ្ឈតិ ភិក្ខវេ សីលវាតោ នេតោមណិនិ វីតរាគត្តា ។ ឥមា ខោ ភិក្ខវេ អដ្ឋ ទានូបបត្តិយោតិ ។

(៣៦) តីណិមានិ ភិក្ខវេ បុញ្ញកិរិយាវត្ថូនិ ។ កតមានិ តីណិ ។ ទានមយំ បុញ្ញកិរិយាវត្ថុ(១)

---

១ ម. បុញ្ញកិរិយវត្ថុំ ។

បុគ្គលនោះឲ្យវត្ថុណា ក៏ឲ្យថាវត្ថុនោះ បុគ្គលនោះ ឈានឲ្យថា ពួកទេវតា ព្រហ្មកាយិក: មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះបែកធ្លាយពង់កាយ ស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតា ព្រហ្មកាយិក: បុគ្គលនោះ ដម្កល់ចិត្តនោះ តាំងចិត្តនោះ ចំរើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចំរើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយពង់កាយស្លាប់ទៅរមែងទៅកើត ជាមួយនឹងពួកទេវតា ព្រហ្មកាយិក: តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលទេ ទានចំពោះបុគ្គលប្រាសចាកពាគ: មិនចំពោះបុគ្គល ប្រកបដោយពាគ:ទេ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះប្រាសចាកពាគ: ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទានមាន ៨ ប្រការនេះឯង ។

[៣៦] ម្នាលភិក្ខុទាំងឡាយ បុញ្ញាភិសង្ខារនេះមាន ៣ យ៉ាង ។ បុញ្ញាភិសង្ខារ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺទានមយបុញ្ញាភិសង្ខារ (ត្រង់ថាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការឲ្យ) ១

សីលមយំ បុញ្ញកិរិយាវត្ថុ ភាវនាមយំ បុញ្ញកិរិយាវត្ថុ ។ ឥធ ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ បរិត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ បរិត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា មនុស្សុនោកកូរំ(១) ឧបបជ្ជតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ មត្តសោ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ មត្តសោ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា មនុស្សុសោកកូរំ(២) ឧបបជ្ជតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

---

១ ម. មនុស្សុភោកកូរំ ។ ២ ម. មនុស្សុសោកកូរំ ។

សីលមយបុញ្ញកិរិយាវត្ថុ (វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការរក្សាសីល) ១ ភាវនាមយបុញ្ញកិរិយាវត្ថុ (វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការចំរើន) ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ធ្វើសីលមយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ប៉ុន្តែ ភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងត្រកូលមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ ល្មមប្រមាណ ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ក៏ល្មមប្រមាណ ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងត្រកូលមនុស្សជ័្ឍន់ខ្ពស់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ។

តត្រ កតមេ ចត្តារោ មហារាជានោ ទានមយំ បុញ្ញ-
កិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ
អតិរេកំ ករិត្វា ចាតុម្មហារាជិកេ ទេវេ ឧសហិ
ហានេហិ អធិក្កណ្ហាន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន
ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន
ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ
ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥធ បន
ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ
កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ
កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ ន កិ-
ញ្ចិទេវ ។ សោ កាយស្ស ភេទា បរម្មរណា
តាវត្តឹសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ ភិក្ខវេ
សក្កោ ទេវានមិន្ទោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ
ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា
តាវត្តឹសេ ទេវេ ឧសហិ ហានេហិ អធិក្កណ្ហាតិ
ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។

ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ មហាឥសីទាំង ៤ អង្គ ឋានមយបុញ្ញកិរិយាវត្ថុ ច្រើនប្រៃពេក ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនប្រៃពេក រមែងខ្ពង់ខ្ពស់កន្ទុងនូវពួកទេវតាចាតុម្មហារាជិកៈ ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្យ ១ ពណ៌ជាទិព្យ ១ សុខជាទិព្យ ១ យសជាទិព្យ ១ អធិបតីជាទិព្យ ១ រូបជាទិព្យ ១ សំឡេងជាទិព្យ ១ ក្លិនជាទិព្យ ១ រសជាទិព្យ ១ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើឋានមយបុញ្ញកិរិយាវត្ថុច្រើនប្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនប្រៃលែងប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនឋានសម្រេចនៅឡើយ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាតាវត្តឹង្ស ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សក្កទេវរាជជាធំជាងទេវតា ឋានធ្វើឋានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រៃពេក ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រៃពេក រមែងខ្ពង់ខ្ពស់កន្ទុងទេវតាជាន់តាវត្តឹង្ស ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្យ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្យ ១ ។

៥ បន កិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ
អធិមត្តំ ភវតិ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ
អធិមត្តំ ភវតិ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ
ន កិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា
យាមានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ
កិក្ខវេ សុយាមោ ទេវបុត្តោ ទានមយំ បុញ្ញកិរិយាវត្ថុំ
អតិរេកំ ភវត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ
ភវត្វា យាមេ ទេវេ ឧសហិ ឋានេហិ អធិភុញ្ជតិ
ទិព្វេន អាយុនា ។បេ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ ៥
បន កិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ
អធិមត្តំ ភវតិ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ
អធិមត្តំ ភវតិ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ
ន កិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា
តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ
កិក្ខវេ សន្តុសិតោ ទេវបុត្តោ ទានមយំ បុញ្ញកិរិយាវត្ថុំ
អតិរេកំ ភវត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ
ភវត្វា តុសិតេ ទេវេ ឧសហិ ឋានេហិ អធិភុញ្ជតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនប្រការ ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនប្រការ ប៉ុន្តែការនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សុយាមទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការពេក រមែងឱនទន់ក្នុងទីនៃពួកទេវតាជាន់យាមៈ ដោយស្មាន ១០ យ៉ាងគឺ អាយុជាទិព្យ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនប្រការ ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនប្រការ ប៉ុន្តែការនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សន្តុសិតទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការពេក រមែងឱនទន់ក្នុងទីនៃពួកទេវតា ជាន់តុសិតដោយស្មាន ១០ យ៉ាងគឺ

និព្ពេន អាយុនា ។ បេ ។ និព្ពេហិ ដោដ្ឋព្ពេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញ-
កិរិយាវត្ថុ អតិវេកំ កតំ ហោតិ សីលមយំ បុញ្ញ-
កិរិយាវត្ថុ អតិវេកំ កតំ ហោតិ ភាវនាមយំ បុញ្ញ-
កិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា
បរម្មរណា និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។
តត្រ ភិក្ខវេ សុនិម្មិតោ ទេវបុត្តោ ទានមយំ បុញ្ញ-
កិរិយាវត្ថុំ អតិវេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ
អតិវេកំ ករិត្វា និម្មានរតី ទេវេ ឧសហា ឋានេហិ
អធិក្កណ្ហាតិ និព្ពេន អាយុនា ។ បេ ។ និព្ពេហិ
ដោដ្ឋព្ពេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ
បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញ-
កិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញ-
កិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្ម-
រណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

អាយុជាទិព្យ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនប្រការ ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនប្រការ ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនសម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយពីកាយ ស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតា និម្មានរតី ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សុនិមិតទេវបុត្រ ជាន ធ្វើទានមយបុញ្ញកិរិ-យាវត្ថុដ៏ច្រើនប្រការ ជាន ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការ រមែងគ្គន់គ្គស់កង្វល់ពួកទេវតានិម្មានរតី ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្យ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនប្រការ ធ្វើសីលមយ-បុញ្ញកិរិយាវត្ថុ ដ៏ច្រើនប្រការ ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយពីកាយ ស្លាប់ទៅ ក៏រមែងទៅកើត ជាមួយនឹងពួកទេវតា បរនិម្មិតវសវត្តី ។

តត្រ កិក្ខវេ បរនិម្មិតវសវត្តី ទេវបុត្តោ(១) ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា បរនិម្មិតវសវត្តី ទេវេ ទសហិ ឋានេហិ អធិក្កណ្ហាតិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥមានិ ខោ កិក្ខវេ តីណិ បុញ្ញកិរិយាវត្ថូនីតិ ។

(៣៧) អដ្ឋិមានិ កិក្ខវេ សប្បុរិសទានានិ ។ កតមានិ អដ្ឋ ។ សុចឹ ទេតិ បណីតំ ទេតិ កាលេន ទេតិ កប្បិយំ ទេតិ រាចេយ្យ ទេតិ អគិល្លោ ទេតិ ទនំ ចិត្តំ បសាទេតិ ទត្វា អត្តមនោ ហោតិ ។ ឥមានិ ខោ កិក្ខវេ អដ្ឋ សប្បុរិសទានានីតិ ។

សុចឹ បណីតំ កាលេន កប្បិយំ ទានភោជនំ
អគិល្លោ ទនាតិ ទានានិ សុខេត្តេសុ(២) ព្រហ្មចារីសុ
ទេវ វិប្បដិសារិយំ(៣) ចជិត្វា អាមិសំ ឥមំ
ឋវំ និដ្ឋានំ ទានានិ វណ្ណយន្តិ វិបស្សិនោ

---

១ ម. សវត្ថិ ទេវបុត្តោ ។ ២ ម. សុខេត្តេ ។ ៣ ម. ន ច វិប្បដិសារិស្ស ។

ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ បរនិម្មិតវសវត្តីទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុ ដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុ ដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្ទុយជាងពួកទេវតាបរនិម្មិតវសវត្តី ដោយស្តាន ១០ យ៉ាង គឺ អាយុជាទិព្យ ១ ពណ៌ជាទិព្យ ១ សុខជាទិព្យ ១ យសជាទិព្យ ១ អធិបតីជាទិព្យ ១ រូបជាទិព្យ ១ សំឡេងជាទិព្យ ១ ក្លិនជាទិព្យ ១ រសជាទិព្យ ១ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុ មាន ៣ យ៉ាងនេះឯង ។

[៣៧] ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះមាន ៨ យ៉ាង ។ សប្បុរិសទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យវត្ថុស្អាត ១ ឲ្យវត្ថុថ្លា ១ ឲ្យតាមកាល ១ ឲ្យវត្ថុគួរ ១ ជ្រើសរើសហើយទើបឲ្យ ១ ឲ្យទានរឿយៗ ១ កំពុងឲ្យញុំាងចិត្តឲ្យជ្រះថ្លា ១ លុះឲ្យផុតហើយ រមែងមានសេចក្តីពេញចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាន ៨ យ៉ាងនេះឯង ។

បុគ្គល រមែងឲ្យនូវទានទាំងឡាយគឺ ទឹកនឹងកោជន ដ៏ស្អាត ថ្លៃថ្លា តាមកាល វត្ថុដ៏គួរ រឿយ ។ ចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ដូចជាស្រែដ៏ល្អ ពួកអ្នកប្រាជ្ញ រមែងសរសើរនូវទានទាំងឡាយ ដែលបុគ្គលលះបង់នូវអាមិសៈជាច្រើន ដែលមិនគួរឲ្យកើតសេចក្តីក្តៅក្រហាយ ហើយឲ្យយ៉ាងនេះ

ឯវំ យដិត្ថា មេ ជាវី សទ្ធោ មុត្តេន ចេតសា
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

[๓๘] សប្បុរិសោ កិត្តេវ កុលេ ជាយមានោ
ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ
មាតាបិតូនំ អត្ថាយ ហិតាយ សុខាយ ហោតិ
បុត្តទារស្ស អត្ថាយ ហិតាយ សុខាយ ហោតិ
ទាសកម្មករោចិស្ស អត្ថាយ ហិតាយ សុខាយ
ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ សុខាយ
ហោតិ បុព្វបេតានំ អត្ថាយ ហិតាយ សុខាយ
ហោតិ រញ្ញោ អត្ថាយ ហិតាយ សុខាយ ហោតិ
ទេវតានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណ-
ព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតិ ។

អ្នកប្រាជ្ញមានបញ្ញា ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះ
ហើយ មានចិត្តរួចស្រឡះ រមែងចូលទៅកាន់ទេវលោក
ដែលមិនមានសេចក្តីទុក្ខ មានតែសេចក្តីសុខ ។

(៣៨) ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ដល់មាតាបិតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់បុត្តភរិយា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ដល់មិត្តនិងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ពួកញាតិ ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ។

សេយ្យថាបិ កិកូវេ មហាមេឃោ សព្ពសស្សានិ
សម្បាទេត្វោ ពហុនោ ជនស្ស អត្ថាយ ហិតាយ
។បេ។ ហោតិ ឯវមេវ ខោ កិកូវេ សប្បុរិសោ
កុលេ ជាយមានោ ពហុនោ ជនស្ស អត្ថាយ ហិតាយ
សុខាយ ហោតិ មាតាបិតូនំ អត្ថាយ ហិតាយ
សុខាយ ហោតិ បុត្តទារស្ស អត្ថាយ ហិតាយ
សុខាយ ហោតិ ទាសកម្មករោរិស្ស អត្ថាយ
ហិតាយ សុខាយ ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ
សុខាយ ហោតិ បុព្វបេតានំ អត្ថាយ ហិតាយ សុខាយ
ហោតិ រញ្ញោ អត្ថាយ ហិតាយ សុខាយ ហោតិ
ទេវតានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណ-
ព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតីតិ ។

ម្នាលភិក្ខុទាំងឡាយ មហាមេឃ កាលញាំងសំទូងទាំងអស់ ឲ្យស្រេចព្រម រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើនដល់ជនច្រើន ។បេ។ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដើម្បីសេចក្តីចំរើនដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើនដើម្បីសេចក្តីសុខ ដល់មាតាឪពុកទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់បុត្តភរិយា ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់មិត្តនឹងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ពួកញាតិ ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ក៏មានឧបមេយ្យដូច្នោះដែរ។

ពហូនំ វត អត្ថាយ សប្បញ្ញោ ឃរមាវសំ
មាតរំ បិតរំ បុព្ពេ រត្តិន្ទិវមតន្ទិតោ
ប្បវេតំ សហធម្មេន បុព្ពេ កតមន្តុសព្ពំ
អជាតាវេ បព្ពជិតេ អថាបេ ព្រហ្មចារិនោ(๑)
និវិដ្ឋសទ្ធោ ប្បវេតំ ញត្វា ធម្មេ បសាទលោ
រញ្ញោ ហិតោ នេវហិតោ ញាតីនំ សខិនំ ហិតោ
សព្ពេសំ សហិតោ ហោតិ សទ្ធម្មេ សុបតិដ្ឋិតោ
វិនេយ្យ មច្ឆេរមលំ សលោភំ ភជតេ សិវន្តិ ។

[๓๙] អដ្ឋិមេ ភិក្ខវេ បុញ្ញភិសន្ទា កុសលាភិសន្ទា សុខសញ្ញាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ អដ្ឋ ។

---

๑ ម. អថបេ ព្រហ្មចារយោ ។

បុគ្គលប្រកបដោយបញ្ញា កាលនៅគ្រប់គ្រងផ្ទះ រមែងប្រព្រឹត្ត
ទៅ ដើម្បីប្រយោជន៍ដល់ពួកជនច្រើន ជាអ្នកមិនខ្ជិលច្រអូស
កន្លងវេលាយប់ទំាងថ្ងៃ កាលនឹកឃើញដល់បុព្វការគុណដែល
មាតាទំាងបិតាធ្វើហើយ រមែងបូជាមាតាបិតាជាមុន ដោយ
ហេតុប្រកបដោយធម៌ រមែងកោតក្រែងចំពោះបព្វជិតជាអនា-
គារិកបុគ្គល ជាព្រហ្មចារីបុគ្គលមានសទ្ធាដម្កល់មំាមានសីល
ជាទីស្រឡាញ់ លុះដឹងច្បាស់នូវធម៌ទំាងឡាយហើយ រមែង
បូជា បុគ្គលណាដែលមានប្រយោជន៍ដល់ព្រះរាជា មានប្រ-
យោជន៍ដល់ទេវតា មានប្រយោជន៍ដល់ពួកញាតិ ដល់មិត្ត
សំឡាញ់ ដម្កល់ស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះឈ្មោះថាមាន
ប្រយោជន៍ដល់បុគ្គលទំាងអស់ បុគ្គលណាកំចាត់បង់នូវមន្ទិល
គឺសេចក្តីកំណាញ់ បុគ្គលនោះ រមែងដួបប្រទះនូវលោកកម្រមក្បាន្តៗ

(៣៩) ម្នាលភិក្ខុទំាងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល
ជាអាហារនៃសេចក្តីសុខ ជាធម៌ទ្រទ្រង់នូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តី
សុខ ប្រព្រឹត្តទៅដើម្បីស្ងួតនូវ៨យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេក
អរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បី
សេចក្តីសុខៗ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល៨ យ៉ាងដូចម្តេចខ្លះ។

បណ្ណាសកេ ទានវគ្គោ

៨ ឆ ភិក្ខវេ អរិយសាវកោ ពុទ្ធំ សរណំ គតោ
ហោតិ អយំ ភិក្ខវេ បឋមោ បុញ្ញាភិសន្ទោ
កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខ-
វិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ
ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ
អរិយសាវកោ ធម្មំ សរណំ គតោ ហោតិ អយំ
ភិក្ខវេ ទុតិយោ បុញ្ញាភិសន្ទោ ។ បេ ។ សំវត្តតិ ។
បុន ចបរំ ភិក្ខវេ អរិយសាវកោ សង្ឃំ សរណំ
គតោ ហោតិ អយំ ភិក្ខវេ តតិយោ បុញ្ញាភិសន្ទោ
កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខ-
វិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ
ហិតាយ សុខាយ សំវត្តតិ ។ បញ្ចិមានិ ភិក្ខវេ
ទានានិ មហាទានានិ អគ្គញ្ញានិ រត្នញ្ញានិ វំសញ្ញានិ

ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ១ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក ជាអ្នកដល់នូវព្រះធម៌ជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យទី ២ ។ បេ ។ រមែងប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក ជាអ្នកដល់នូវព្រះសង្ឃជាទីពឹង នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៣ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ទាន ទាំង ៥ យ៉ាងនេះ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថាជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់កាលយូរ ដឹងថាជាវង្សនៃ (កល្យាណជន)

ចោរកណានំ អសន្តិណ្ហានំ អសន្តិណ្ហាបុព្ពានំ ន សន្តិយន្តិ ន សន្តិយិស្សន្តិ អប្បដិកុដ្ឋានំ សមណោហិ ព្រាហ្មណោហិ វិញ្ញូហិ ។ កតមានំ បញ្ច ។ ឥធ ភិក្ខវេ អរិយសាវកោ ចាគវាតិចាតំ បហាយ ចាគវាតិចាតា បដិវិរតោ ហោតិ ចាគវាតិចាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ។ ឥទំ ភិក្ខវេ បឋមំ ទានំ មហាទានំ អក្ខញ្ញំ អត្តញ្ញំ វំសញ្ញំ ចោរកណំ អសន្តិណ្ហំ អសន្តិណ្ហាបុព្ពំ ន សន្តិយតិ ន សន្តិយិស្សតិ អប្បដិកុដ្ឋំ សមណោហិ ព្រាហ្មណោហិ វិញ្ញូហិ

ជារបស់មានមកកន្លងកាលមុន ជារបស់មិនពេយរាយ ជារបស់មិនធ្លាប់ពេយ
រាយហើយ រមែងមិនខ្ជាត់ខ្ជាយ (ក្នុងកាលឥឡូវនេះ) នឹងមិនខ្ជាត់ខ្ជាយ
(ក្នុងអនាគត) ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដៀលតិះដៀល
ឡើយ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់ចោណតិចោត រៀរចាកចោណាតិចោត ម្នាល
ភិក្ខុទាំងឡាយ អរិយសាវក ជាអ្នករៀរចាកចោណាតិចោត ឈ្មោះថាឲ្យនូវ
អភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ
មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើ
មិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នក
មានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មាន
ប្រមាណមិនបានវិញ។ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ១ ចាត់ជាមហា-
ទាន ដែលអ្នកប្រាជ្ញដ៏ធំថាជារបស់ប្រសើរ ដ៏ធំថាជារបស់ប្រព្រឹត្តទៅតាមស
ប្បុរិសធម៌ ដ៏ធំថាជាវង្សនៃ (កល្យាណជន) ជារបស់មានមកកន្លងកាលមុន
ជារបស់មិនពេយរាយ មិនធ្លាប់ពេយរាយហើយ រមែងមិនខ្ជាត់ខ្ជាយ នឹងមិន
ខ្ជាត់ខ្ជាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដៀលតិះដៀលឡើយ

បណ្ណាសកេ ទានវត្តេ

អយំ កិក្ខវេ ចតុន្នោ បុញ្ញកិរិយវត្ថូនំ ភុសលាកិរិយវត្ថូនំ សុខសញ្ញាភាគេ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ កិក្ខវេ អរិយសាវកោ អនិដ្ឋានំ បហាយ អនិដ្ឋានាយ បដិបន្នោ ហោតិ ។បេ។ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។បេ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ ។បេ។ សុរាមេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ កិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណាសុ អភយសុ អវេរសុ អព្យាបជ្ឈសុ ភាគី ហោតិ ឥទំ កិក្ខវេ បញ្ចមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ រំសញ្ញំ

ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ទ្បើនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៤ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ។ បេ ។ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ។ បេ ។ លះបង់មុសាវាទ វៀរចាកមុសាវាទ ។ បេ ។ លះបង់សុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលភិក្ខុទាំងឡាយ អរិយសាវក វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ឈ្មោះថា ទ្បើនូវអភ័យ ទ្បើនូវអំពើមិនមានពៀរ ទ្បើនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះទ្បើនូវអភ័យ ទ្បើនូវអំពើមិនមានពៀរ ទ្បើនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នក មានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ៥ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដំណាលថាជារបស់ប្រសើរ ដំណាលថាជារបស់ប្រព្រឹត្តទៅអស់កាលយូរ ដំណាលថាជាវង្សនៃ (កល្យាណជន)

เจวาณิ อสงฺกิณฺณา อสงฺกิณฺณปุพฺพา น สงฺกิยติ น สงฺกิยิสฺสติ อปฺปฏิกุฏฺฐา สมณพฺราหฺมณาหิ วิญฺญูหิ อยํ กิกฺขาย อฏฺฐเม ปุญฺญกิริยวตฺถุ กุสลากิริยวตฺถุ สุขสฺสาหารเก สาวชฺชเก สุขวิปากเก สคฺคสังวตฺตนิเก ฐปฺปาย กปฺปาย มหาจาย หิตาย สุขาย สังวตฺตติ ฯ ฐเม เจ กิกฺขาย อฏฺฐ ปุญฺญกิริยวตฺถุ กุสลากิริยวตฺถุ สุขสฺสาหารเก สาวชฺชเก สุขวิปากเก สคฺคสังวตฺตนิเก ฐปฺปาย กปฺปาย มหาจาย หิตาย สุขาย สังวตฺตนฺติ ฯ

[๔๐] จาณกิตาจาเร กิกฺขาย อาเสวิเต ภาวิเต พหุลีกเต ยาวชีวสังวตฺตนิเก ตาวชฺชนเยน สังวตฺตนิเก ปิตฺติวิสเย สังวตฺตนิเก ฯ เย สงฺขลหุเก จาณกิตาจารสฺส วิจาเร มนุสฺสภูตสฺส อปฺปายุกสังวตฺตนิเก เหตุ ฯ อธิฏฺฐานงฺ กิกฺขาย

ជារបស់មានមកកាលមុន មិនរោយរាយ មិនផ្គាប់រោយរាយហើយ រមែងមិនខ្ជាត់ខ្ជាយ នឹងមិនខ្ជាត់ខ្ជាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជនក៏មិនដៃលតិះដៀលឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី៨ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ ៨ ប្រការនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចំរើន ដើម្បីសេចក្តីសុខ ។

(៤០) ម្នាលភិក្ខុទាំងឡាយ ឫទ្ធិណាតិឫទ្ធ ដៃលបុគ្គលសេពច្បឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃឫទ្ធិណាតិឫទ្ធ ដៃលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ផល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ អនិន្ទាឫទ្ធ

អាសេវិតំ ភាវិតំ ពហុលីកតំ ឯវយសំវត្តនិកំ តំវត្ថាន-
យោនិសំវត្តនិកំ បិត្តំវិសយសំវត្តនិកំ ។ យោ សព្ព-
លហុសោ អនិដ្ឋាផលសទ្ធ វិចាកោ មនុស្សភូតសទ្ធ
ភោគព្យសនសំវត្តនិកោ ហោតិ ។ កាមេសុ មិច្ឆាចារេ
កិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ ឯវយសំវត្ត-
និកោ តំវត្ថានយោនិសំវត្តនិកោ បិត្តំវិសយសំវត្តនិកោ ។
យោ សព្ពលហុសោ កាមេសុ មិច្ឆាចារសទ្ធ វិចាកោ
មនុស្សភូតសទ្ធ សបត្តវេរសំវត្តនិកោ ហោតិ ។ មុសាវាទេ
កិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ ឯវយសំវត្ត-
និកោ តំវត្ថានយោនិសំវត្តនិកោ បិត្តំវិសយសំវត្តនិកោ ។
យោ សព្ពលហុសោ មុសាវាទផលសទ្ធ វិចាកោ មនុស្ស-
ភូតសទ្ធ អភូតព្ភក្ខានសំវត្តនិកោ ហោតិ ។ បិសុណាយ
កិក្ខវេ វាចាយ អាសេវិតាយ ភាវិតាយ ពហុលីកតាយ ឯវយ-
សំវត្តនិកាយ តំវត្ថានយោនិសំវត្តនិកាយ បិត្តំវិសយសំវត្ត-
និកាយ ។ យោ សព្ពលហុសោ បិសុណាយ វាចាយ
វិចាកោ មនុស្សភូតសទ្ធ មិត្តេហិ ភេទនសំវត្តនិកោ
ហោតិ ។ ផរុសាយ កិក្ខវេ វាចាយ អាសេវិតាយ ភាវិតាយ

ដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃអទិន្នាទានដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីវិនាសនៃភោគៈ ដល់តែតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆាចារ ដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃកាមេសុមិច្ឆាចារ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសត្រូវនឹងពៀរ ដល់តែតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ មុសាវាទ ដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃមុសាវាទ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីគេពោលបង្កាច់ ដោយពាក្យមិនពិត ដល់តែតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ បិសុណាវាចា ដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបិសុណាវាចា ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីបែកធ្លាក់ចាកមិត្រ ដល់តែតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ផរុសវាចា ដែលបុគ្គលថ្នឹកហើយ ចំរើនហើយ

ฅหาลีกตา นิรยสวตฺตนิกา ติรจฺฉานโยนิสวตฺตนิกา ปิตฺติวิสยสวตฺตนิกา ฯ โย สพฺพลหุสา ฉวุสาย ฯาจาย วิหาเรา มนุสฺสภูตสฺส อมนาปสงฺกปฺปสวตฺตนิเรา โหติ ฯ สมฺมปฺปลาเฅ ปกฺขเว อาสวิเรา ภาวิเรา ฅหาลีกเรา นิรยสวตฺตนิเรา ติรจฺฉานโยนิสวตฺตนิเรา ปิตฺติวิสยสวตฺตนิเรา ฯ โย สพฺพลหุสา สมฺมปฺปลาปสฺส วิหาเรา มนุสฺสภูตสฺส อมานุสฺสิยา ฯาจาสวตฺตนิเรา โหติ ฯ สุภมยาจาน ปกฺขเว อาสวิเ ภาวิเ ฅหาลีกเ นิรยสวตฺตนิเ ติรจฺฉานโยนิสวตฺตนิเ ปิตฺติวิสยสวตฺตนิเ ฯ โย สพฺพลหุสา สุภมยาจานสฺส วิหาเรา มนุสฺสภูตสฺส ทุปฺปตฺติสวตฺตนิเรา โหติ ฯ

ทานวคฺโค จตุตฺโถ ฯ

ตสฺสุทฺทานํ

เทฺว ฯาฯานิ วุตฺตานิ ทฺเว ปตฺถนา ทานูปปตฺติ กิริยา เทฺว สปฺปุริสา สพฺพลหุสา อกิสฺสโว จ วุตฺตาติ ฯ

ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃផរុសវាចា ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសម្ងួនមិនជាទីគាប់ចិត្ត ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ សម្ផប្បលាបៈដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃសម្ផប្បលាបៈដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីពាក្យដែលមិនគួរកាន់យក ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរាទំនិងមេរ័យដែលបុគ្គលថ្នឹកហើយ ចំរើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃការផឹកនូវសុរាមេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីភាពជាឆ្កួត ដល់កើតជាមនុស្ស ។

ចប់ ទានវគ្គ ទី ៤ ។

ឧទ្ទាននៃវគ្គនោះ គឺ

និយាយអំពីទានពីរលើក អំពីទានវត្ថុ ១ អំពីបុញ្ញកិរិយា ១ អំពីការកើតឡើងនៃទាន ១ អំពីបុញ្ញកិរិយាវត្ថុ ១ អំពីសប្បុរសពីរលើក អំពីផលដ៏ស្រាលជាងផលទាំងអស់ ១ អំពីអានិសង្ស ១ ។

ទុប្បោសបរិគ្គោ

(៤៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ
ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ
ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អដ្ឋង្គ-
សមន្នាគតោ ភិក្ខវេ ទុច្ចោសយោ ទុប្បុត្តោ មហាបួឡោ
ហោតិ មហានិរយោ មហាជុតិកោ មហាវិប្ផារោ ។
កតមំ ទុប្បុត្តោ ច ភិក្ខវេ អដ្ឋង្គសមន្នាគតោ ទុច្ចោសយោ
មហាបួឡោ ហោតិ មហានិរយោ មហាជុតិកោ
មហាវិប្ផារោ ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ
បដិសញ្ចិក្ខតិ យាវតីហំ អរហន្តោ ចាឡាតិចាតំ បហាយ
ចាឡាតិចាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា
លជ្ជី ទយាបន្នា សព្ពបាណភូតហិតានុកម្បិនោ វិហរន្តិ

ឧបោសថវគ្គ

(៤១) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ កាលនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គល ចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញា ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត

អហំ បជ្ជ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ ចាណាតិចាតំ បហាយ ចាណាតិចាតា បដិវិរតោ និហិតទណ្ឌោ និហិ-តសត្ថោ លជ្ជី ទយាបន្នោ សព្ពបាណភូតហិតានុកម្បី វិហរាមិ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវតីវំ អរហន្តោ អនិដ្ឋានានំ បហាយ អនិដ្ឋានានា បដិវិរតា និដ្ឋានាយី និដ្ឋបាដិកង្ខី អត្តេនេន សុចិភូតេន អត្តនា វិហរន្តិ អហំ-បជ្ជ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ អនិដ្ឋានានំ បហាយ អនិដ្ឋានានា បដិវិរតោ និដ្ឋានាយី និដ្ឋបាដិកង្ខី អត្តេនេន សុចិភូតេន អត្តនា វិហរាមិ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ឧត្តរិយេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវតីវំ អរហន្តោ អព្រហ្មចរិយំ បហាយ ព្រហ្មចារិនោ អារកចារិនោ វិរតា មេថុនា គាមធម្មា

កន្លងថ្ងៃនេះ ចំណែកខ្ញុំនឹងអញ លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះ នឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចំរើនឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គ ១ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះតែវត្ថុដែលគេឲ្យ មានខ្ញុំជាស្អាត មិនមែនជាអ្នកលួចដកបអស់ជីវិត កន្លងថ្ងៃនេះ ចំណែកខ្ញុំនឹងអញ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះតែវត្ថុដែលគេឲ្យ មានខ្ញុំជាស្អាត មិនមែនជាអ្នកលួច អស់យប់នេះ នឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចំរើនឧបោសថផងដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គ ២ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ដែលជាធម្មសម្អប់អ្នកស្រុក ដកបអស់ជីវិត

អហំបជ្ជ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អាភចារី វិរតោ មេថុនា តាមធម្មា ឥមិនាបង្គេន អរហាតំ អនុកភេមិ ឧបោ-សថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា តតិយេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ មុសាវាទំ បហាយ មុសាវាទា បដិវិរតា សច្ចវាទិនោ សច្ចសន្ធា បេតា បច្ចយិកា អវិសំវាទកា លោកស្ស អហំបជ្ជ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ សច្ចវាទី សច្ចសន្ធោ បេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ឥមិនា-បង្គេន អរហាតំ អនុកភេមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ចតុត្ថេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ សុរាមេរយមជ្ជប្បមាទ-ដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋា បដិវិរតា

បណ្ណាសក ឧបោសថវគ្គ

ភិក្ខុទាំងឡាយ ចំណែកខ្លួនអញ លះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តធ្លាយ រៀវចាកមេថុន ដែលជាធម៌បស់អ្នកស្រុក អស់យប់នេះ នឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្លួនអញនឹងចំរើនក្បាទោបោសថផង ដោយអង្គនេះឯង ។ ទោបោសថប្រកបដោយអង្គ ៣ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់មុសាវាទ រៀវចាកមុសាវាទ អ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្កាច់លោក ភិក្ខុទាំងឡាយ ចំណែកខ្លួនអញលះបង់មុសាវាទ រៀវចាកមុសាវាទ ជាអ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្កាច់លោក អស់យប់នេះ នឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្លួនអញនឹងចំរើនក្បាទោបោសថផង ដោយអង្គនេះឯង ។ ទោបោសថប្រកបដោយអង្គ ៤ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកគ្រឿងស្រវឹងគឺសុរានឹងមេរ័យ រៀវចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកគ្រឿងស្រវឹងគឺសុរានឹងមេរ័យ ជាហេតុរស់ជីវិត

អមាំបជ្ជ ឥមញ្ច រត្តឺ ឥមញ្ច ទិវសំ សុភមេរយមជ្ឈប្ប-
មាទដ្ឋានំ បហាយ សុភមេរយមជ្ឈប្បមាទដ្ឋានា បដិវិរតោ
ឥមិនាបង្គេន អរហាតំ អនុភវេមិ ឧភោសហោ ច មេ
ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បញ្ចមេន អង្គេន សមន្នា-
គតោ ហោតិ ។បេ។ យាវជីវំ អរហាន្តោ ឯកភត្តិកោ
រត្តូបរតោ វិរតោ វិការលភោជនា អមាំបជ្ជ ឥមញ្ច រត្តឺ
ឥមញ្ច ទិវសំ ឯកភត្តិកោ រត្តូបរតោ វិរតោ វិការល-
ភោជនា ឥមិនាបង្គេន អរហាតំ អនុភវេមិ ឧភោសហោ
ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ឆដ្ឋេន អង្គេន
សមន្នាគតោ ហោតិ ។បេ។ យាវជីវំ អរហាន្តោ នច្ចគីត-
វាទិតវិស្សុកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-
វិភូសនដ្ឋានំ បហាយ នច្ចគីតវាទិតវិស្សុកទស្សន-
មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ

ក្នុងថ្ងៃនេះ ចំណែកខ្ញុំនឹងអញ្ជើញ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺធម៌គ្រឿងស្រវឹង គឺសុរានិងមេរ័យ រៀរាភកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺធម៌គ្រឿងស្រវឹង គឺសុរានិងមេរ័យ អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចាំកាន់ឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គ ៨ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ បរិភោគបាយតែម្តង រៀរបរិភោគ ក្នុងវេលាយប់ រៀរាភកភោជន ក្នុងវេលាវិកាល ជាពហុអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំនឹងអញ្ជើញ បរិភោគបាយតែម្តង រៀរបរិភោគ ក្នុងវេលាយប់ រៀរាភកភោជនក្នុងវេលាវិកាល អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនឹងចាំកាន់ឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គ ៨ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់ការរាំ ច្រៀង ប្រគំ មើលល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ ប្រដាប់តាក់តែង ស្អិតស្អាងពាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ រៀរាភកការរាំ ច្រៀង ប្រគំ មើលល្បែងដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង ពាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ជាពហុអស់ជីវិត

អហំ បជ្ជ ឥមញ្ច រត្តឺ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ-
ស្សុកនសុដ្ឋនមាលាកម្មវិលេបនធារណមណ្ឌនវិភូសន-
ដ្ឋានំ បហាយ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយន-
មហាសយនមាលាកម្ម វិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ឥមិនា-
បង្គេន អរហាតំ អនុកកោមិ ពុទ្ធោសថោ ច មេ ឧបវុត្ថោ
ភវិស្សតីតិ ។ ឥមិនា សត្តមេន អង្គេន សមន្នាគតោ
ហោតិ។បេ។ យាវជីវំ អរហាន្តោ ឧច្ចាសយនមហាសយនំ
បហាយ ឧច្ចាសយនមហាសយនា បដិវិរតា នីចសេយ្យំ
កប្បេន្តិ មញ្ចកេ ឯ តិណាសន្ថរកេ ឯ អហំបជ្ជ ឥមញ្ច
រត្តឺ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ បហាយ
ឧច្ចាសយនមហាសយនា បដិវិរតោ នីចសេយ្យំ កប្បេមិ
មញ្ចកេ ឯ តិណាសន្ថរកេ ឯ ឥមិនាបង្គេន អរហាតំ
អនុកកោមិ ពុទ្ធោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។

កន្លងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់ការពាំ ប្រៀង ប្រតំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ នឹងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង ពងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សែង ។ រៀបចាក ការពាំ ប្រៀង ប្រតំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ នឹងការ ទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង ពងកាយដោយផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាបផ្សែង ។ អស់យប់នេះនឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្ត ទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោ-សថប្រកបដោយអង្គទី៧នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះ បង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងសេនាសនៈដ៏ប្រសើរ រៀបចាក សេនាសនៈដ៏ខ្ពស់ហួសប្រមាណនឹងសេនាសនៈដ៏ប្រសើរ សម្រេចនូវ ទីដេក ដ៏ទាបលើគ្រែក្តី លើកម្រាល ដែលគេធ្វើដោយស្មៅក្តី ដរាបអស់ ជីវិតក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងសេនាសនៈដ៏ប្រសើរ រៀបចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ នឹង សេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្តី លើកម្រាលដែល គេធ្វើដោយស្មៅក្តី អស់យប់នេះនឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្ត ទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។

ฯ มิตา อฑฺฒเมน อเฏฺฐน สมฺปาเทตา เหเตน ฯ ฆนํ อุปาทาย เหา กิตฺวา อฑฺฒฏฺฐสมฺปาเทตา อุเทสเต มหาปญฺโญ เหเตน มหาอตฺถโก มหาวิสโย มหาวิสยวา เหเตน ฯ

(๔๒) อฑฺฒฏฺฐสมฺปาเทตา กิตฺวา อุเทสเต อุปาทาย มหาปญฺโญ เหเตน มหาอตฺถโก มหาวิสโย มหาวิสยวา ฯ กถํ อุปาทาย จ กิตฺวา อฑฺฒฏฺฐสมฺปาเทตา อุเทสเต มหาปญฺโญ เหเตน มหาอตฺถโก มหาวิสโย มหาวิสยวา ฯ ๙๓ กิตฺวา อริยสาวโก ๙ติ ปฏิสญฺจิกฺขติ ยาวตา อรหนฺโต อตีตา ปหายปหาตพฺพา ปหายปหาตา ปฏิวิทฺธา ฉินฺนมูลกา ฉินฺนสีสา ลุทฺธา อยาปตฺตา สพฺพปฺปหีนกิเลสา ปหีนกิเลสา วิหรนฺติ อปฺปฏิสนฺธิกา ๙มญฺจ ๙ติ ๙มญฺจ ทิวสํ ปหายปหาตพฺพา ปหายปหาตา ปฏิวิทฺธา ฉินฺนมูลกา ฉินฺนสีสา ลุทฺธา อยาปตฺตา สพฺพปฺปหีนกิเลสา วิหรนฺติ

ទោសថប្រកបដោយអង្គ ៨នេះឯង។ ម្នាលភិក្ខុទាំងឡាយ ទោសថ ប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយច្រើន ។

(៤២) ម្នាលភិក្ខុទាំងឡាយ ទោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ទោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សត្វសត្វ ដរាបអស់ជីវិតក្នុងថ្ងៃនេះ ចំណែកខ្លួនអញលះបង់បាណាតិបាត រៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សត្វសត្វ អស់យប់នេះនឹងថ្ងៃនេះ

ឥមិនាបង្គេន អរហតំ អនុកភោមិ ពុទោសថោ ច មេ ពុបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នាគតោ ហោតិ ។ (បឋមេន យថា វិត្ថារោ) យាវជីវំ អរហង្គោ ពុទ្ធាសយនមហាសយនំ បហាយ ពុទ្ធាសយនមហាសយនា បដិវិរតោ ឆិចសេយ្យំ កប្បេន្តិ មញ្ចកោ វា តិណាសន្ថរកោ វា អហំបជ្ជ ឥមញ្ច រត្តិំ ឥមញ្ច ទិវសំ ពុទ្ធាសយនមហាសយនំ បហាយ ពុទ្ធាសយនមហាសយនា បដិវិរតោ ឆិចសេយ្យំ កប្បេមិ មញ្ចកោ វា តិណាសន្ថរកោ វា ឥមិនាបង្គេន អរហតំ អនុកភោមិ ពុទោសថោ ច មេ ពុបវុត្ថោ ភវិស្សតីតិ ។ ឥមិនា អដ្ឋមេន អង្គេន សមន្នាគតោ ហោតិ ។ ឯវំ ពុបវុត្ថោ ខោ កិក្ខវេ អដ្ឋង្គសមន្នាគតោ ពុទោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។

តីវមហប្ផលោ ហោតិ តីវមហានិសំសោ តីវមហាជុតិកោ តីវមហាវិប្ផារោ ។ សេយ្យថាបិ កិក្ខវេ យោ

យកតម្រាប់ព្រះអរហន្តទាំង៦ព្រះអង្គ ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។ (សេចក្តីពិស្តារដូចអង្គទី ១) ព្រះអរហន្តទាំង៦ព្រះអង្គ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណនឹងសេនាសនៈដ៏ប្រសើរ រៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណនឹងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើត្រែក្តី លើកម្រាល ដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងសេនាសនៈដ៏ប្រសើរ រៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ នឹងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើត្រែក្តី លើកម្រាល ដែលធ្វើដោយស្មៅក្តី អស់យប់នេះនឹងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំង៦ព្រះអង្គផង អញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។

ឧបោសថ មានផលច្រើន ដូចម្តេច មានអានិសង្សច្រើន ដូចម្តេច មានសេចក្តីរុងរឿងច្រើន ដូចម្តេច មានសេចក្តីផ្សាយទៅច្រើន ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គល

ឥមេសំ សោឞ្ឋសន្នំ មហាជនបទានំ បហូតសត្ត-
រតនានំ ឥស្សរាធិបច្ចំ រជ្ជំ ការេយ្យ សេយ្យថីទំ អង្គានំ
មគធានំ កាសីនំ កោសលានំ វជ្ជីនំ មល្លានំ ចេតីនំ
វំសានំ កុរូនំ បញ្ចាលានំ មច្ឆានំ សូរសេនានំ អស្ស-
កានំ អវន្តីនំ គន្ធារានំ កម្ពោជានំ អដ្ឋន្នំ សមន្តាគតស្ស
ឧចោសជស្ស ឯតំ កលំ នាគ្ឃតិ សោឞ្ឋសឹ ។ តំ
កិស្ស ហេតុ ។ កមលាំ កិក្ខវេ មានុសកំ រជ្ជំ
ឥទ្ធំ សុខំ ឧបនិធាយ ។ យានិ កិក្ខវេ មានុសកានិ
បញ្ចាសំ វស្សានិ ចាតុម្មហារាជិកានំ ទេវានំ ឯសោ
ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន
មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន
ទិព្វានិ បញ្ច វស្សសតានិ ចាតុម្មហារាជិកានំ ទេវានំ
អាយុប្បមាណំ ។ ឋានំ ខោ បនេតំ កិក្ខវេ វិជ្ជតិ
យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋន្នំ សមន្តាគតំ
ឧចោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា
ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។

សោយភាវ ជាឥស្សរាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទ សម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទ ឈ្មោះអង្គៈ ១ មគធៈ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វង្សៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិនៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត ១ ក្នុងចំណិតទី ១៦ ។ លើកនៃទោសថប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្យ ។ ម្នាលភិក្ខុទាំងឡាយ ៥០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ចាតុម្មហារាជិកទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់ចាតុម្មហារាជិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវទោសថដែលប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ។

ឥធំ ខោ បន មេតំ កិក្ខវេ សង្ឃាយ កាសិតំ កបឍំ មានុសកំ វដ្ដំ និព្ពុំ សុខំ ឧបនិជាយ ។ យំ កិក្ខវេ មានុសកំ វស្សសតំ តាវត្តិំសានំ ទេវានំ ឯកាហំ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តិំសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន និព្ពុំ វស្ស-សហស្សំ តាវត្តិំសានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ កិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តាវត្តិំសានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥធំ ខោ បន មេតំ កិក្ខវេ សង្ឃាយ កាសិតំ កបឍំ មានុសកំ វដ្ដំ និព្ពុំ សុខំ ឧបនិជាយ ។ យានិ កិក្ខវេ មានុសកានិ ទ្វេ វស្សសតានិ យាមានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តិំសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ

ម្នាលភិក្ខុទាំងឡាយ ពាជសម្បត្តិរបស់មនុស្ស ជារបស់ស្គួចស្តើង ហើយ
យកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសំដែង
ហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ១០០ឆ្នាំ
របស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់តាវត្តិង្សទេវតា ពាក់ពាក្រឹនោះបាន
៣០ ត្រូវជា១ខែ ពាក់ខែនោះ បាន ១២ ខែត្រូវជា ១ ឆ្នាំ ពាក់ឆ្នាំនោះបាន
១០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់តាវត្តិង្សទេវតា ។ ម្នាល
ភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុង
លោកនេះ ចាំរក្សាន្ទូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយ
ពាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតាវត្តិង្សទេវតា ។ ម្នាល
ភិក្ខុទាំងឡាយ ពាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្គួចស្តើង ហើយ
យកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសំដែង
ហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ២០០ ឆ្នាំ
របស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកយាមទេវតា ពាក់ពាក្រឹនោះ
បាន ៣០ ពាក្រឹត្រូវជា ១ ខែ ពាក់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ

តេន សំវច្ឆរេន ទិញ្ញានិ ទ្វេ វស្សសហស្សានិ យាមានំ
ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ
វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ
ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា
យាមានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥធ ខោ
បន មេតំ ភិក្ខវេ សង្ខាយ ភាសិតំ កបណំ
មានុសកំ វដ្ដំ ទិព្ពំ សុខំ ឧបនិធាយ ។ យានិ
ភិក្ខវេ មានុសកានិ ចត្តារិ វស្សសតានិ តុសិតានំ
ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា
តីសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ
សំវច្ឆរោ តេន សំវច្ឆរេន ទិញ្ញានិ ចត្តារិ វស្សសហស្សានិ
តុសិតានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ
ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា
អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា
បរម្មរណា តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួកជនជាបរិសទ្យ ១ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ថែរក្សាសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយសទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាកសេចក្តីកំណាញ់ ១

ឯវំ មត្តំ វិសោធេតំ សោត្តានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច យេសញ្ច វិជ្ជតិ ជាវយោ
តម្បិ សីលវតំ អាហុ ធម្មដ្ឋំ សច្ចវាទិនំ
សោឧប្បសាការសម្បន្នា អដ្ឋង្គំសុសមាគតា
តាទិសី សីលវតី ឧបាសិកា ឧបបជ្ជតិ
នេរាលោកំ មនាបត្តិ ។

[៥០] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុក្កាមោ
ឥធ លោកវិជយាយ បដិបន្នោ ហោតិ អយំ ស លោកោ
អារទ្ធោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ
មាតុក្កាមោ សុសំវិហិតកម្មន្តោ ហោតិ សង្គហិតបរិជនោ
ភត្តុ មនាបំ ចរតិ សម្ភតំ អនុរក្ខតិ ។ កថញ្ច ភិក្ខវេ
មាតុក្កាមោ សុសំវិហិតកម្មន្តោ ហោតិ ។ ឥធ ភិក្ខវេ
មាតុក្កាមោ យេ តេ ភត្តុ អព្ភន្តរកកម្មន្តា ។បេ។ យំ
ខោ ភិក្ខវេ មាតុក្កាមោ សុសំវិហិតកម្មន្តោ ហោតិ ។

ជម្រះផ្លូវជាទីទៅកាន់បរលោក ឲ្យស្អាតជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា នារីនោះមានសីល បិតនៅក្នុងធម៌ ពោលនូវពាក្យពិត ជាឧបាសិកាដែលបរិបូណ៌ដោយអាការ ១៦ (១) ប្រកបដោយអង្គទាំង ៨ ប្រការ មានសីលបែបនោះ រមែងទៅកើត ក្នុងទេវលោក ឈ្មោះមនាបកាយិកា ។

(៩០) ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិសេស្យ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ។បេ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ជាស្ត្រីចេះចាត់ចែង ការងារដោយប្រពៃ យ៉ាងនេះឯង ។

---

๑ អាការ ๑๖ នោះ សំដៅយកបបួលអ្នកនៅថ្ងៃ ៨ ចូលមកទៀតផង ។ អដ្ឋកថា ។

កថញ្ច កិកូវ មាតុគ្គាមោ សង្គហិតបរិជនោ ហោតិ ។
ឥធ កិកូវ មាតុគ្គាមោ យេ តេ ភត្តុ អព្ភន្តរា
អាណាជនា ។បេ។ ឯវំ ខោ កិកូវ មាតុគ្គាមោ
សង្គហិតបរិជនោ ហោតិ ។ កថញ្ច កិកូវ មាតុគ្គាមោ
ភត្តុ មជាបំ ចរតិ ។ ឥធ កិកូវ មាតុគ្គាមោ យំ
ភត្តុ អមជាបសង្ហាតំ តំ ជីវិតហេតុបិ ន អជ្ឈាចរតិ ។
ឯវំ ខោ កិកូវ មាតុគ្គាមោ ភត្តុ មជាបំ ចរតិ ។
កថញ្ច កិកូវ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។
ឥធ កិកូវ មាតុគ្គាមោ យំ ភត្តា អាហរតិ ។បេ។
ឯវំ ខោ កិកូវ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។
ឥមេហិ ខោ កិកូវ ចតូហិ ធម្មេហិ សមន្នាគតោ
មាតុគ្គាមោ ឥធលោកវិជយាយ បដិបន្នោ ហោតិ
អយំស លោកោ អារទ្ធោ ហោតិ ។ ចតូហិ កិកូវ
ធម្មេហិ សមន្នាគតោ មាតុគ្គាមោ បរលោកវិជយាយ
បដិបន្នោ ហោតិ បរស្សុ លោកោ អារទ្ធោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះសង្គ្រោះពួកជនជាបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ពួកជនណាជាខាងក្នុង ជាបន្ទុករបស់ស្វាមី ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមចេះសង្គ្រោះពួកជនជាបរិសទ្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះប្រព្រឹត្តអំពើជាទីគាប់ចិត្តរបស់ស្វាមីតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ អំពើណាដែលមិនជាទីគាប់ចិត្តនៃស្វាមី បើទុកជាមានហេតុដល់ជីវិត ក៏មិនប្រព្រឹត្តកន្ទួងន្ទូវអំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រព្រឹត្តអំពើជាទីគាប់ចិត្តនៃស្វាមីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមីរកបានមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ស្វាមីនាំមកនូវទ្រព្យណា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ចេះថែទាំសម្បត្តិដែលស្វាមីរកបានមកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកនេះ លោកនេះក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រាវឲ្យហើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រាវឲ្យហើយ ។

កតមេហិ ចតូហិ ។ ឥធ កិក្ខវេ មាតុត្តាមោ សទ្ធា-
សម្បន្នោ ហោតិ សីលសម្បន្នោ ហោតិ ចាគសម្បន្នោ
ហោតិ បញ្ញាសម្បន្នោ ហោតិ ។ កតមញ្ច កិក្ខវេ
មាតុត្តាមោ សទ្ធាសម្បន្នោ ហោតិ ។ ឥធ កិក្ខវេ
មាតុត្តាមោ សទ្ធោ ហោតិ ។ បេ ។ ឯវំ ខោ កិក្ខវេ
មាតុត្តាមោ សទ្ធាសម្បន្នោ ហោតិ ។ កតមញ្ច កិក្ខវេ
មាតុត្តាមោ សីលសម្បន្នោ ហោតិ ។ ឥធ កិក្ខវេ
មាតុត្តាមោ ចាណាតិចាតា បដិវិរតោ ហោតិ ។ បេ ។
សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឯវំ ខោ
កិក្ខវេ មាតុត្តាមោ សីលសម្បន្នោ ហោតិ ។ កតមញ្ច
កិក្ខវេ មាតុត្តាមោ ចាគសម្បន្នោ ហោតិ ។ ឥធ កិក្ខវេ
មាតុត្តាមោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ
។ បេ ។ ឯវំ ខោ កិក្ខវេ មាតុត្តាមោ ចាគសម្បន្នោ
ហោតិ ។ កតមញ្ច កិក្ខវេ មាតុត្តាមោ បញ្ញាសម្បន្នោ
ហោតិ ។ ឥធ កិក្ខវេ មាតុត្តាមោ បញ្ញវា ហោតិ ។ បេ ។
ឯវំ ខោ កិក្ខវេ មាតុត្តាមោ បញ្ញាសម្បន្នោ ហោតិ ។
ឥមេហិ ខោ កិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ

ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម
ក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយសីល ១ បរិបូណ៌
ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម
បរិបូណ៌ដោយសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុង
លោកនេះ មានសទ្ធា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌
ដោយសទ្ធាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម បរិបូណ៌
ដោយសីល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ
វៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ
គឺផឹកនូវទឹកស្រវឹងគឺសុរាទាំងមេរ៉ៃ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបរិ-
បូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាមបរិ-
បូណ៌ដោយចាគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុង
លោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ
។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយចាគៈយ៉ាងនេះ
ឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម បរិបូណ៌ដោយបញ្ញា តើដូច
ម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីមានបញ្ញា
។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយបញ្ញាយ៉ាងនេះ
ឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

មាតុត្តាមោ បរលោកវិជយាយ បដិបន្នោ ហោតិ បរស្ស លោកោ អារទ្ធោ ហោតីតិ ។

សុសំវិហិតកម្មន្តោ សន្តហិតបវិដ្ឋចោ
កតុ មជាបំ ចរតិ សម្ភតំ អនុរក្ខតិ
សទ្ធាសីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មក្កំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច យស្សត្ថា វិដ្ឋិ ជាយតេ
តម្បិ សីលវតី អាហុ ធម្មដ្ឋំ សច្ចវាទិនិំ
សោឧប្បសាការសម្បន្នោ អដ្ឋង្គំសុសមាគតា
តាទិសី សីលវតី ឧភាសិកា ឧបបជ្ជតិ
ទេវលោកំ មជាមន្តិ ។

ឧភោសចរិត្តោ បញ្ចមោ ។

តត្រុត្តរិំ

សង្ខិត្តេ វិត្ថតេ វិសាខេ វាសេដ្ឋោ ពោជ្ឈាយ បញ្ចមំ
អនុរុទ្ធំ បន វិសាខេ ឧកុលា ឥធលោកិកា ទ្វេតិ ។

បណ្ណាសកោ សមត្តោ ។

ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថា មាតុគ្រាមនោះ ឋានប្រាកដហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួកជនជាបរិសទ្យ ១ ប្រព្រឹត្តអំពើ ជាទីគាប់ចិត្តនៃស្វាមី ១ ថែរក្សាសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយសទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាកសេចក្តីកំណាញ់ជម្រះផ្លូវជាទីទៅកាន់បរលោកឲ្យស្អាតជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា នារីនោះ មានសីលបិតនៅ ក្នុងធម៌ ពោលនូវពាក្យពិត ។ ឋានសិការដែលបរិបូណ៌ដោយអាការ ១៦ ប្រកបដោយអង្គទាំង ៨ មានសីលបែបនោះ រមែងទៅកើតក្នុងទេវលោកឈ្មោះមនាបកាយិកា ។

ចប់ ឧបោសថវគ្គ ទី ៥ ។

ឧទ្ទាននៃឧបោសថវគ្គនោះគឺ

និយាយអំពីការរក្សាឧបោសថយ៉ាងសង្ខេប ១ ពិស្តារ ១ អំពីនាងវិសាខា ១ អំពីវាសេដ្ឋព្រាហ្មណ៍ ១ ជាគំរប់ ៥ នឹងនាងពោជ្ឈា អំពីព្រះអនុរុទ្ធ ១ អំពីនាងវិសាខា ១ អំពីនកុលមាតា ១ អំពីការឈ្នះលោកនេះ មានពីរលើក ។

ចប់ បណ្ណាសក ។

បណ្ណាសកាសង្គហិតា វគ្គ

សង្ខារវគ្គោ

(៩១) ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុក្កាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុក្កាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជាតិ ។ ទុតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុក្កាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។

បណ្ណាសកាសង្គហិតវគ្គ

សង្ខារវគ្គ

(៥១) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅ ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅ ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរមាតុគ្រាម គួរចេញចាកផ្ទះ ឋានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់សំដែងហើយ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ឃាត់ថា ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ហើយបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតឋានសំដែងទៀយ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគំរប់ពីរដងថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាម គួរចេញចាកផ្ទះ ឋានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។

អលំ គោតមំ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគត-
ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជាតិ ។
តតិយម្បិ ខោ មហាបជាបតី គោតមី កកវន្តំ ឯតទវោច
សាធុ កន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ
ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អលំ
គោតមំ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ
ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជាតិ ។ អថខោ
មហាបជាបតី គោតមី ន កកវា អនុជានាតិ មាតុគ្គា-
មស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ
បព្ពជ្ជន្តិ ទុក្ខី ទុម្មនា អស្សុមុខី រុទមានា កកវន្តំ
អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ
កកវា កបិលវត្ថុស្មឹ យថាភិរន្តំ វិហរិត្វា យេន
វេសាលី តេន ចារិកំ បក្កាមិ អនុបុព្ពេន ចារិកំ
ចរមានោ យេន វេសាលី តទវសរិ តត្រ សុទំ កកវា
វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះក្នុងធម្មវិន័យដែលតថាគតបានសំដែងឡើយ។ ព្រះនាងមហាបជាបតីគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះជាគំរប់បីដងថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ។ ម្នាលនាងគោតមី ណ្ហើយនាងកុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតបានសំដែងឡើយ។ លំដាប់នោះឯង ព្រះនាងមហាបជាបតីគោតមី បានជ្រាបថា ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ ក៏តើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រទ្រង់ព្រះកន្សែងហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ។ គ្រានោះឯង ព្រះដ៏មានព្រះភាគ ទ្រង់គង់សម្រេចសម្រាន្ត ក្នុងក្រុងកបិលពស្តុ តាមគួរដល់ពុទ្ធអធ្យាស្រ័យ ហើយស្តេចចៀសចេញទៅកាន់ចារិក ក្រុងវេសាលី កាលទ្រង់ស្តេចទៅកាន់ចារិក តាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលីនោះឯង។ មានសេចក្តីដំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់គង់សម្រេចសម្រាន្ត ក្នុងកូដាគារសាលា នាមហាវន ទៀបក្រុងវេសាលីនោះ។

អថខោ មហាបជាបតី គោតមី កេសេ ឆេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា សម្ពហុលាហិ សាកិ-យាហិ(๑) សទ្ធិំ យេន វេសាលី តេន បក្កាមិ អនុបុព្ពេន យេន វេសាលី មហាវនំ កូដាគារសាលា តេនុបសង្កមិ។ អថខោ មហាបជាបតី គោតមី សុនេហិ ចានេហិ រជោកិណ្ណេន កត្តេន ទុក្ខី ទុម្មុខា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ មហាបជាបតឹ គោតមឹ សុនេហិ ចានេហិ រជោកិណ្ណេន កត្តេន ទុក្ខឹ ទុម្មុខំ អស្សុមុខឹ រុទមានំ ពហិទ្វារកោដ្ឋកេ ឋិតំ ឯវញ្ច អមហាបជាបតឹ គោតមឹ ឯតទវោច កឹ ឥទ្ធិ តុវំ គោតមិ សុនេហិ ចានេហិ រជោកិ-ណ្ណេន កត្តេន ទុក្ខី ទុម្មុខា អស្សុមុខី រុទមានា ពហិ-ទ្វារកោដ្ឋកេ ឋិតាតិ ។ តថា ហិ បន កត្តេ អានន្ទ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្ម-វិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ តេនហិ គោតមិ

๑ ឱ. ម. សាកិយានិហិ ។

លំដាប់នោះឯង ព្រះនាងមហាបជាបតិគោតមី ឲ្យគេកោរព្រះកេសា ហើយស្លៀកសំពត់ជ្រលក់ ដោយទឹកអម្ចត់ ទ្រង់យាងសំដៅទៅក្រុងវេសាលី ជាមួយនឹងពួកនាងសាក្យានីជាច្រើន យាងចូលទៅកាន់កូដាគារសាលា នាមហាវន ទៀបក្រុងវេសាលីនោះ តាមលំដាប់ ។ លោនោះ ព្រះនាងមហាបជាបតិគោតមី មានព្រះបាទចាំងគូ ពុរពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ ។ ព្រះអានន្ទដ៏មានអាយុ បានឃើញព្រះនាងមហាបជាបតិគោតមី មានព្រះបាទចាំងគូ ពុរពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ កំពុងតែឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ លុះបានឃើញហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាងមានព្រះបាទចាំងគូពុរពង មានព្រះអង្គព្រះឡាក់ដោយធូលី កើតទុកតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅដូច្នេះ ។ បពិត្រព្រះអានន្ទដ៏ចំរើន បានជាដូច្នោះ ព្រោះតែព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយផងសោះ ។ បពិត្រព្រះនាងគោតមី បើដូច្នោះ

ឥធេវ តាវ ភោមហិ យាវហំ ភគវន្តំ យាចាមិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អថខោ អាយស្មា អនន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនន្ទោ ភគវន្តំ ឯតទវោច ឯសា ភន្តេ មហាបជាបតី គោតមី សុនេហិ ចានេហិ រជោកិណ្ណេន កត្តេន ទុក្កី ទុម្មុខា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតា ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជាតិ ។

សូមព្រះនាងទ្រង់រង់ចាំកន្លះទីនេះសិនចុះ ទំរាំអាត្មាភាព ទៅក្រាបបង្គំទូលសុំព្រះដ៏មានព្រះភាគ ឲ្យមាតុគ្រាម ចានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតិគោតមីនុ៎ះ មានព្រះហឫទ័យគាំងគួ ពុរពេង មានព្រះអង្គប្រឡាក់ធូលី កើតទុក្ខកួចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្ទុយទ្វារ ទៀបក្រៅទ្វារខាងក្រៅ ដោយក្រាបថា ព្រះដ៏មានព្រះភាគមិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ ចានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ ម្នាលអានន្ទ ណ្ហើយអ្នក កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងឡើយ ។

ទុតិយម្បិ ខោ ។បេ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតម្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតម្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជាតិ ។ អថខោ អាយស្មាតោ អានន្ទស្ស ឯតទហោសិ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតម្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជំ យន្នូនាហំ អញ្ញេនបិ បរិយាយេន ភគវន្តំ យាចេយ្យំ មាតុគ្គាមស្ស តថាគតម្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភព្ភោ នុ ខោ ភន្តេ មាតុគ្គាមោ តថាគតម្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជិត្វា សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិកាតុន្តិ ។

ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូល ជាគំរប់ពីរដងដដែល ។ បេ ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគំរប់ ៣ ដងដដែលថា បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ ចាកបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយផង ។ ម្នាលអានន្ទ ណ្ហើយអ្នកកុំគាប់ចិត្ត ឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ឥទ្ធរនេះ ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយទេ បើដូច្នោះ គួរតែអាត្មាអញក្រាបបង្គំទូលសុំព្រះដ៏មានព្រះភាគ ដោយបរិយាយដទៃទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយ គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី បានដែរឬ ។

កញ្ចោ អានន្ទ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ
អគារស្មា អនគារិយំ បព្ពជិត្វា សោតាបត្តិផលម្បិ
សកទាគាមិផលម្បិ អនាគាមិផលម្បិ អរហត្តផលម្បិ
សច្ឆិកាតុន្តិ ។ សចេ កន្តេ កញ្ចោ មាតុគ្គាមោ តថាគ-
តប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជិត្វា
សោតាបត្តិផលម្បិ ។បេ។ អរហត្តផលម្បិ សច្ឆិកាតុំ
ពហុការា កន្តេ មហាបជាបតី គោតមី កកុវតោ
មាតុច្ឆា អាចារិកា ធោសិតា កកុវន្តំ ជនេត្តិយា
ការិកាយ ខញ្ញំ ចាយេសិ ។ សាធុ កន្តេ
លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ
អគារស្មា អនគារិយំ បព្ពជ្ជន្តិ ។ សចេ អានន្ទ
មហាបជាបតី គោតមី អដ្ឋ ការុធម្មេ បដិក្ខិត្តា
សា វស្សា ហោតុ ឧបសម្បទា ។ វស្សសតូប-
សម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ
អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កត្តព្ពំ

ម្នាលអានន្ទ មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ក៏គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។ បពិត្រព្រះអង្គដ៏ចំរើន បើមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសំដែងហើយ គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលផង ។ បេ ។ អរហត្តផលផង បពិត្រព្រះអង្គដ៏ចំរើន ព្រះនាងមហាបជាបតិគោតមី មានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះដ៏មានព្រះភាគ ជាន់បីជាប់ចិញ្ចឹម កាលព្រះមាតាទ្រង់ទិវង្គតទៅ ជាន់បំបៅព្រះដ៏មានព្រះភាគ តរៀងមក ។ បពិត្រព្រះអង្គដ៏ចំរើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាម ចេញចាកផ្ទះ ជាន បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សំដែងហើយផង ។ ម្នាលអានន្ទ បើព្រះនាងមហាបជាបតិគោតមី ទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការជាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ (ឯគរុធម៌ ៨ ប្រការនោះគឺ) ភិក្ខុនីសូម្បីឧបសម្បទាជានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងឧបសម្បទាកនៃថ្ងៃនោះ

អយម្បិ ឆម្ភោ សក្កត្វា ករុកត្វា មានេត្វា ឫជេត្វា យាវជីវំ អនតិក្កមនីយោ ។ ឯ កិក្ខនិយា អភិក្ខុកេ អារាសេ វស្សំ ឧបគន្តព្ពំ អយម្បិ ឆម្ភោ សក្កត្វា ករុកត្វា មានេត្វា ឫជេត្វា យាវជីវំ អនតិក្កមនីយោ ។ អន្ធវ្ហ-មាសំ កិក្ខនិយា កិក្ខុសង្ឃតោ ឧភោសឋបុច្ឆកញ្ច តាឯទុបសង្កមនញ្ច បរិយេសិតព្ពំ អយម្បិ ឆម្ភោ សក្កត្វា ករុកត្វា មានេត្វា ឫជេត្វា យាវជីវំ អនតិក្កម-នីយោ ។ វស្សំ វុត្ថាយ កិក្ខនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្ពំ ទិដ្ឋេន សុតេន បរិសង្កាយ អយម្បិ ឆម្ភោ សក្កត្វា ករុកត្វា មានេត្វា ឫជេត្វា យាវជីវំ អន-តិក្កមនីយោ ។ ករុឆម្មំ អជ្ឈាបន្នាយ កិក្ខនិយា ឧភតោ-សង្ឃេ បក្ខមានត្តំ បរិតព្ពំ អយម្បិ ឆម្ភោ សក្កត្វា ករុកត្វា មានេត្វា ឫជេត្វា យាវជីវំ អនតិក្កមនីយោ ។ ទ្វេ វស្សានិ ឆសុ ឆម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្ពា

បណ្ណាសកាសង្គហិត សង្ឃនវគ្គ

នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្ត កន្ទុះដ៏ជាបអស់ជីវិត ๑ ฯ ភិក្ខុនី មិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុះដ៏ជាបអស់ជីវិត ๑ ฯ ភិក្ខុនីត្រូវស្វែងរកសួរទោសឋានចូលទៅស្តាប់ឧវាទផង អំពីសំណាក់ភិក្ខុសង្ឃរាល់កន្ទុះ๑ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុះ ដ៏ជាបអស់ជីវិត ๑ ฯ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសំណាក់សង្ឃទាំង ๒ ពួក (គឺភិក្ខុសង្ឃ ๑ ភិក្ខុនីសង្ឃ ๑) ដោយឋាន ๓ យ៉ាង គឺ ឃើញ ឮ រង្កៀស នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុះ ដ៏ជាបអស់ជីវិត ๑ ฯ ភិក្ខុនីត្រូវគារុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសំណាក់សង្ឃទាំង ๒ ពួកនេះ ជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុះ ដ៏ជាបអស់ជីវិត ๑ ฯ ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ๒ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខាបទទាំង ๖ (๑) ប្រការគ្រប់ ๒ ឆ្នាំហើយ

---

๑ សំដៅយកសិក្ខាបទ ๖ ពីឆក្កនិបាត ឆសុវិកាសភោជនៈ ฯ

អយម្បិ ជម្ហោ សក្កត្វា ករុកត្វា មានេត្វា បូជេត្វា យាវ-
ជីវំ អនតិក្កមនីយោ ។ ន កេនចិ បរិយាយេន កិក្ខុនិ-
យា កិក្ខុ អក្កោសិតព្ពោ បរិភាសិតព្ពោ អយម្បិ ជម្ហោ
សក្កត្វា ករុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កម-
នីយោ ។ អជ្ជតគ្គេ ឥវជោ កិក្ខុនីនំ កិក្ខុសុ វចនបថោ
អនោវជោ កិក្ខូនំ កិក្ខុនីសុ វចនបថោ អយម្បិ ជម្ហោ
សក្កត្វា ករុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កម-
នីយោ ។ សចេ អានន្ទ មហាបជាបតី គោតមី ឥមេ អដ្ឋ
ករុជម្មេ បដិក្ខណ្ហាតិ សាវសប្បា ហោតុ ឧបសម្បទាតិ ។
អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ
ឥមេ អដ្ឋ ករុជម្មេ ឧក្ខហេត្វា យេន មហាបជាបតី
គោតមី តេនុបសង្កមិ ឧបសង្កមិត្វា មហាបជាបតឹ
គោតមឹ ឯតទវោច សចេ ខោ ត្វំ គោតមិ អដ្ឋ ករុជម្មេ
បដិក្ខណ្ហាយ្យាសិ សាវ តេ ករិស្សតិ ឧបសម្បទា ។

នេះជាធម៌ដែលកិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្ត
កន្ទុងឆ ដរាបអស់ជីវិត ១ ។ កិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចកិក្ខុ ដោយ
បរិយាយណាមួយឡើយ នេះជាធម៌ដែលកិក្ខុនីត្រូវធ្វើសក្ការៈ គោរព
រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុងឆ ដរាបអស់ជីវិត ១ ។ តាំងពីថ្ងៃ ដែល
បានឧបសម្បទានេះទៅ កិក្ខុនីត្រូវតែស្តាប់បង្គាប់កិក្ខុ ឯកិក្ខុមិនត្រូវស្តាប់
បង្គាប់កិក្ខុនីវិញទេឡើយ នេះជាធម៌ដែលកិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់
អាន បូជា កុំគប្បីប្រព្រឹត្តកន្ទុងឆ ដរាបអស់ជីវិត ១ ។ ម្នាលអានន្ទ
បើព្រះនាងមហាបជាបតិគោតមី ទទួលប្រព្រឹត្តតាមគរុធម៌ទាំង ៨ នេះ
បាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ លំដាប់នោះ
ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ ៨ ប្រការ ក្នុងសំណាក់ព្រះ
ដ៏មានព្រះភាគ (ចាំស្ងាត់ហើយ) ក៏ចូលទៅរកព្រះនាងមហាបជាបតិ-
គោតមី លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិ-
គោតមីដូច្នេះថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិតាម
គរុធម៌ ៨ ប្រការបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាង ។

វស្សសតូបសម្បន្នាយ កិក្ខុនិយា តទហុបសម្បន្នស្ស
កិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិ-
កម្មំ កត្តព្ពំ អយម្បិ ធម្មោ សក្កត្វា ករុកត្វា
មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ បេ ។
អដ្ឋតក្កេ ឧវាដោ កិក្ខុនីនំ កិក្ខូសុ វចនបថោ
អនោវាដោ កិក្ខូនំ កិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ
សក្កត្វា ករុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្ក-
មនីយោ ។ សចេ ខោ តុំ កោតមិ ឥមេ អដ្ឋ ករុធម្មេ
បដិក្ខណ្ណោយ្យាសិ សារេ តេ ករិស្សតិ ឧបសម្បទាតិ ។
សេយ្យថាបិ កន្តេ អានន្ទ ឥត្ថី វ បុរិសោ វ ឧមារេ
យុវា មណ្ឌនកជាតិកោ សីសន្ហាតោ ឧប្បលមាលំ
វ វស្សិកមាលំ វ អធិមុត្តកមាលំ វ លភិត្វា
ឧភោហិ ហត្ថេហិ បដិគ្គហេត្វា ឧត្តមង្គេ សិរស្មិំ
បតិដ្ឋាបេយ្យ ឯវមេវ ខោ អហំ កន្តេ ឥមេ អដ្ឋ
ករុធម្មេ បដិក្ខិបាមិ យាវជីវំ អនតិក្កមនីយេតិ ។

(ឯគរុធម៌ ៨ ប្រការនោះគឺ) កិកុនីសូម្បីឧបសម្បទា បានមួយរយវស្សា ហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះកិកុ ដែលទើបនឹងបួសហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលកិកុនីត្រូវធ្វើ សក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ๑ ។បេ។ ចាប់ដើមតាំងពីថ្ងៃ (ដែលបានឧបសម្បទា) នេះទៅ កិកុនីត្រូវតែស្តាប់បង្គាប់កិកុ ឯកិកុមិនត្រូវស្តាប់បង្គាប់កិកុនីវិញឡើយ នេះជាធម៌ដែលកិកុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ๑ ។ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិគរុធម៌ ๘ ប្រការនេះបាន ។ ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងបាន ។ ព្រះនាងមហាបជាបតិគោតមី ធ្វើយតបថា បពិត្រព្រះអានន្ទដ៏ចំរើន ស្ត្រីឬបុរសនៅក្រុមុំកំឡោះប្រកបដោយជាតិជាអ្នកស្អិតស្អាងខ្លួន មានក្បាលលប់លាងហើយ បានកម្រងផ្កាឧប្បលក្តី កម្រងផ្កាម្ទេះក្តី កម្រងផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ ដំកល់ទុកលើអវយវៈដ៏ឧត្តមគឺក្បាល យ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចំរើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ ๘ ប្រការនេះ មិនប្រព្រឹត្តកន្លង ដរាបអស់ជីវិត ក៏យ៉ាងនោះដែរ ។

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

អដ្ឋខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។
ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ
ឯតទវោច បដិក្កមតិ ភន្តេ មហាបជាបតិយា គោត-
មិយា អដ្ឋ ករុណម្មា យាវជីវំ អនតិក្កមនីយានិ ។ សចេ
អានន្ទ ជាលកិស្ស មាតុក្កាមោ តថាគតប្បវេទិតេ
ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជ្ជំ ចរដ្ឋិតកំ
អានន្ទ ព្រហ្មចរិយំ អភិសម្ភវិស្សវិស្សសហស្សមេវ សន្ទម្មោ
តិដ្ឋេយ្យ ។ យតោ ច ខោ អានន្ទ មាតុក្កាមោ តថាគត-
ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្ពជិតោ
ឧឡារំ អានន្ទ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ភវិស្សតិ បញ្ចេវាឡារំ
អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ សេយ្យថាបិ អានន្ទ
យានិ កានិចិ កុលានិ ពហុឥត្ថិកានិ អប្បបុរិសកានិ
តានិ សុប្បធំសិយានិ ហោន្តិ ចោរេហិ កុម្ភត្ថេនកេហិ

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន គរុធម៌ទាំង ៨ ប្រការ ព្រះនាងមហាបជាបតិគោតមីព្រមទទួលហើយ មិនប្រព្រឹត្តឱ្យកន្ទុងដរាបអស់ជីវិតទេ ។ ម្នាលអានន្ទ ប្រសិនបើ មាតុគ្រាម មិនបានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយទេ ម្នាលអានន្ទ ព្រហ្មចរិយធម៌នឹងបានតាំងនៅជាអង្វែង ព្រះសទ្ធម្មគឺអរហត្តផលនឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ។ ម្នាលអានន្ទ តែកាលណា មាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសំដែងហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចរិយធម៌មិនតាំងនៅយូរអង្វែងទេ ម្នាលអានន្ទឥឡូវនេះ ព្រះសទ្ធម្មនឹងបិតនៅ បានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ ត្រកូលតាំងច្បាស់ណាមួយ ដែលមានស្ត្រីច្រើន មានប្រុសតិច ត្រកូលតាំងនោះ ពួកចោរលួចឧដ្ឋិតក្នុងទីបក្ខដ៏កម្ចាត់ ហើយគន់មើលទ្រព្យក្នុងផ្ទះអកដៃដោយពន្ធឺនោះ អាចចូលមកបំផ្លាញបានដោយងាយ យ៉ាងណាមិញ

ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ ភាតុគ្គាមោ
អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ
ហោតិ ។ សេយ្យថាបិ អានន្ទ សម្ពន្ធេ សាលិក្ខេត្តេ
សេតដ្ឋិកា នាម ភេកជាតិ ឯបតតិ ឯវំ តំ សាលិក្ខេត្តំ
ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ
លភតិ ភាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ
ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ ។ សេយ្យថាបិ អានន្ទ
សម្ពន្ធេ ឧច្ចក្ខេត្តេ មញ្ជេដ្ឋិកា នាម ភេកជាតិ ឯបតតិ
ឯវំ តំ ឧច្ចក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ
យស្មឹ ធម្មវិនយេ លភតិ ភាតុគ្គាមោ អគារស្មា អនគារិយំ
បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ ។ សេយ្យថាបិ
អានន្ទ បុរិសោ មហាតោ តឧប្បាកស្ស បដិកច្ឆេ
ទាន្ធឹ ពន្ធេយ្យ យាវនេវ ឧទកស្ស អនតិក្កមនាយ
ឯវមេវ ខោ អានន្ទ មយា បដិកច្ឆេ ភិក្ខុនីនំ
អដ្ឋ គរុធម្មា បញ្ញត្តា យាវជីវំ អនតិក្កមនីយាតិ ។

ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ ឋានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនឋានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ ពោគជាតិឈ្មោះសេតដ្ឋិកា (ក្រា-ស) ផ្ងាប់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះមិនឋានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាម ចេញចាកផ្ទះ ឋានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនឋានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ ពោគជាតិឈ្មោះមញ្ជដ្ឋិកា (ក្រាក្រហម) ផ្ងាក់ចុះក្នុងច្បារអំពៅណា ដែលកំពុងលូតលាស់ល្អ ច្បារអំពៅនោះ មិនឋានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ ឋានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនឋានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ បុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំជាមុន ដើម្បីមិនឲ្យទឹកហូរចេញទៅជាកំណត់ យ៉ាងណាមិញ ម្នាលអានន្ទ គរុធម៌ ៨ ប្រការ ដែលតថាគត ឋានបញ្ញត្តហើយ ចំពោះកិកុនីជាដម្បូង ដើម្បីមិនឲ្យ (កិកុនី) ប្រព្រឹត្តកន្លង ដរាបដល់អស់ជីវិត ក៏យ៉ាងនោះដែរ ។

สุตฺตนฺตปิฏกេ អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

(๔๒) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ កិក្ខុ កិក្ខុនោវាទកោ សម្មន្និតព្ពោតិ ។ អដ្ឋហិ ខោ អានន្ទ ធម្មេហិ សមន្នាគតោ កិក្ខុ កិក្ខុនោវាទកោ សម្មន្និតព្ពោ ។ កតមេហិ អដ្ឋហិ ។ ឥធានន្ទ កិក្ខុ សីលវា ហោតិ ។បេ។ សមាធាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។បេ។ ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស ជាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តិតានិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចេវ យោ

(๕๒) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារ-សាលា នាមហាវន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន កិក្ខុប្រកបដោយធម៌ប៉ុន្មាន ដែលសង្ឃគួរសន្មត ជាអ្នកឲ្យទុកចដល់នាងកិក្ខុនីបាន ។ ម្នាលអានន្ទ កិក្ខុប្រកបដោយធម៌ ៨ ប្រការ ទើបសង្ឃគួរសន្មត ជាអ្នកឲ្យទុកចដល់នាងកិក្ខុនីបាន ។ ប្រកបដោយធម៌ចំនួន ៨ ប្រការ តើដូចម្តេច ។ ម្នាលអានន្ទ កិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទចំនួនឯង ១ ជាអ្នកចេះចាំច្រើន ។ បេ ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ ឱវាទមោក្ខចំនួនពីរកិក្ខុនោះ កំចេះចាំដោយសេចក្តីពិស្តារ ចែកចេញដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកមានវាចាពីរោះ ពោលពាក្យពីរោះ ប្រកបដោយវាចាអ្នកត្រង់

ភគវាយ សមត្ថាកតោ វិស្សដ្ឋាយ អនេលកទ្បាយ អត្តស្សវិញ្ញាបនិយា បដិពលោ ហោតិ កិត្តិសទ្ទស្សវ ឆម្មិយា កថាយ សន្តុស្សិតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ យេកុយ្យេន កិត្តិនិធំ បិយោ ហោតិ មនាបោ ន ខោ បនេតំ ភគវន្តំ ឧទ្ទិស្សវ បព្វជិតាយ កោសាយវត្តនិវសនាយ ករុណម្មមជ្ឈាបន្នបុព្វោ ហោតិ វិសតិវស្សោ ហោតិ អតិរេកវីសតិវស្សោ ។ ឥមេហិ ខោ អានន្ទ អដ្ឋហិ ឆម្មេហិ សមត្ថាកតោ កិត្តិ កិត្តិនោភនកោ សម្មន្និតព្វោតិ ។

(៥៣) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកា វូបកដ្ឋា

ជាវេចាកេ្សកេ្សាយមិនមានទោស អាចញុំាងអ្នកផងឲ្យដឹងច្បាស់សេចក្តី ១ ជាអ្នកអង់អាច ដើម្បីញុំាងភិក្ខុនីសង្ឃ ឲ្យយល់ ឲ្យប្រតិបត្តិតាម ឲ្យក្សាហាន ឲ្យជ្រះថ្លាដោយធម្មីកថា ១ ជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃនាងភិក្ខុនីពាំងឆ្ងាយដោយច្រើន ១ ជាអ្នកមិនធ្ងាប់ត្រូវគេរុកោបត្តិ(១) ដោយនាងភិក្ខុនី ដែលស្ងៀកសំពត់ជ្រលក់ដោយទឹកអមួត្ត បួសចំពោះព្រះដ៏មានព្រះភាគអង្គនុ៎ះ ១ ជាអ្នកមានវស្សា ២០ ឬមានវស្សាច្រើនជាង ២០ ឆ្នើងទៅ ១ ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយធម៌ពាំង ៨ ប្រការនេះឯង ទើបសង្ឃគួរសន្មតជាអ្នកឲ្យ ឧបាទដល់នាងភិក្ខុនីបាន ។

(៩៣) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយក៏បិតនៅ ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី បិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ សំដែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ព្រោះថា ខ្ញុំព្រះអង្គបានស្តាប់ធម៌ព្រះដ៏មានព្រះភាគហើយ គប្បីចៀសចេញទៅតែម្នាក់ឯង

---

๑ សំដៅយកកាយសំសគ្គៈ ការចាប់ពាល់ត្រូវកាយភិក្ខុនី ។ អដ្ឋកថា ។

អប្បមត្តា អាតាបិនី បហិតត្តា វិហរេយ្យន្តិ ។ យេ
ខោ តុំ គោតមំ ជម្ពូ ជានេយ្យាសិ ឥមេ ជម្ពា
សរកាយ សំវត្តន្តិ នោ វិភង្គាយ សំយោគាយ
សំវត្តន្តិ នោ វិសំយោគាយ អាចយាយ សំវត្តន្តិ នោ
អបចយាយ មហិច្ឆតាយ សំវត្តន្តិ នោ អប្បិច្ឆតាយ
អសន្តុដ្ឋិយា សំវត្តន្តិ នោ សន្តុដ្ឋិយា សង្គណិកាយ
សំវត្តន្តិ នោ បវិវេកាយ កោសជ្ជាយ សំវត្តន្តិ នោ
វីរិយារម្ភាយ ទុព្ភរតាយ សំវត្តន្តិ នោ សុភរតាយាតិ ។
ឯវំសេន គោតមំ ជានេយ្យាសិ នេសោ ជម្ពូ នេសោ
វិនយោ នេតំ សត្ថុសាសនន្តិ ។ យេ ច ខោ តុំ គោតមំ
ជម្ពូ ជានេយ្យាសិ ឥមេ ជម្ពា វិភង្គាយ សំវត្តន្តិ នោ
សរកាយ វិសំយោគាយ សំវត្តន្តិ នោ សំយោគាយ

មិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន(មិនខាន)។ ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំង៤យ៉ាងណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រកបក្នុងវដ្ត: មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្ត: ប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្ត: មិនប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្ត: ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិចប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅ ដើម្បីស្ងាត់ចាកពួក ប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលនាងគោតមី មួយទៀត នាងគប្បីដឹងនូវធម៌ទាំង៤យ៉ាងណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្ត: មិនប្រព្រឹត្តទៅ ដើម្បីការប្រកបក្នុងវដ្ត:

អបចយាយ សំវត្តន្តិ នោ អាចយាយ អប្បិច្ឆតាយ សំវត្តន្តិ នោ មហិច្ឆតាយ សន្តុដ្ឋិយា សំវត្តន្តិ នោ អសន្តុដ្ឋិយា បវិវេកាយ សំវត្តន្តិ នោ សង្គណិកាយ វីរិយារម្ភាយ សំវត្តន្តិ នោ កោសជ្ជាយ សុភរតាយ សំវត្តន្តិ នោ ទុព្ភរតាយាតិ ។ ឯកំសេន តោតមិ ជាវេយ្យាសិ ឯសោ ឆម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសនន្តិ ។

(៥៤) ឯកំ សមយំ ភគវា កោឌ្ឍិយេសុ វិហរតិ កក្ករបត្តំ នាម កោឌ្ឍិយានំ និគមោ ។ អថខោ ទីឃជាណុ កោឌ្ឍិយបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទីឃជាណុ កោឌ្ឍិយបុត្តោ ភគវន្តំ ឯតទវោច មយំ ភន្តេ តិហ៑ កាមភោគី បុត្ត-សម្ពាធសយនំ អជ្ឈាវសាម កាសិកចន្ទនំ បច្ចនុភោម

ប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅ ដើម្បីប្រាថ្នាច្រើន ប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅ ដើម្បីមិនសន្តោស ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីធ្លិលច្រអូស ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ ។ ម្នាលនាងគោតមី នាងគប្បីចាំទុក ដោយពិតចុះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្តាហើយ ។

[៥៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងនិគមឈ្មោះកក្កវបត្តៈ របស់កោឡិយក្សត្រក្នុងដែនកោឡិយៈ ។ គ្រានោះ ទីឃជាណុកោឡិយបុត្រ (កោឡិយបុត្រឈ្មោះទីឃជាណុ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគរួចហើយ អង្គុយក្នុងទីសមគួរ ។ លុះទីឃជាណុកោឡិយបុត្រ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំព្រះអង្គជាគ្រហស្ថ បរិភោគកាម តែងគ្រប់គ្រងទីដំណេកបង្អែតបង្អល់ដោយកូន ប្រស់ព្រំនូវលំអិតនៃទឹមចន្ទន៍ ពីដែនកាសី

មាលាកន្ធវិលេបនំ ធារយាម ជាតរូបរជតំ សាទិយាម
តេសំ ឆោ ភន្តេ ភគវា អម្ហាកំ តថា ធម្មំ ទេសេតុ យេ
អម្ហាកំ អស្សុ ធម្មា ទិដ្ឋធម្មហិតាយ ទិដ្ឋធម្មសុខាយ
សម្បរាយហិតាយ សម្បរាយសុខាយាតិ ។ ចត្តារោមេ
ព្យក្ខបជ្ជ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ
ទិដ្ឋធម្មសុខាយ ។ កតមេ ចត្តារោ ។ ឧដ្ឋានសម្បទា
អារក្ខសម្បទា កល្យាណមិត្តតា សមជីវិតា ។ កតមា
ច ព្យក្ខបជ្ជ ឧដ្ឋានសម្បទា ។ ឥធ ព្យក្ខបជ្ជ កុលបុត្តោ
យេន កម្មដ្ឋានេន(๑) ជីវិតំ កប្បេតិ យទិ កសិយា
យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្តេន យទិ
រាជហោរិសេន យទិ សិប្បញ្ញតរេន តត្ថ ទក្ខោ ហោតិ
អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ
កាតុំ អលំ សំវិធាតុំ អយំ វុច្ចតិ ព្យក្ខបជ្ជ ឧដ្ឋាន-
សម្បទា ។ កតមា ច ព្យក្ខបជ្ជ អារក្ខសម្បទា ។

---

๑ ម. កម្មដ្ឋានេន ។

ទ្រទ្រង់នូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ត្រេកអរនូវមាសនឹងប្រាក់ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ ទ្រង់សំដែងធម៌ បែបនោះ ដល់យើងខ្ញុំចាំងឡាយនោះ ជាធម៌ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍កងបរលោកក្នុង ដើម្បីសេចក្តីសុខកងបរលោក ដល់យើងខ្ញុំព្រះអង្គ ។ ម្នាលព្យគ្ឃបជ្ជៈ (๑) ធម៌ចាំង៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍កងបច្ចុប្បន្ន ដើម្បីសេចក្តីសុខកងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌៤ ប្រការ តើដូចម្តេច ។ គឺ ឧដ្ឋានសម្បទា ๑ អារក្ខសម្បទា ๑ កល្យាណមិត្តតា ๑ សមជីវិតា ๑ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រ កងលោកនេះ ចិញ្ចឹមជីវិត ដោយការប្រឹងប្រែង កងការងារណា គឺកសិកម្ម ជួញប្រែក្តី រក្សាគោក្តី ការងាររបស់ខ្មាន់ធ្នូក្តី ការងាររបស់ពាជបុរសក្តី សិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ កងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយឧប្បាយ ជាគ្រឿងពិចារណាកងការងារទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ឧដ្ឋានសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះអារក្ខសម្បទា តើដូចម្តេច ។

---

๑ ហៅថាមហាវេណី ព្រោះបុព្វបុរសទាំងត្រកូលរបស់បុរសនោះ កើតក្នុងវង្សនេះ ។ អដ្ឋកថា ។

ឥធ ព្យក្ឃបជ្ជ កុលបុត្តស្ស កោតា ហោន្តិ ឧដ្ឋានវីរិ-
យាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា
ធម្មលទ្ធា តេ អារក្ខេន កុត្តិយា សម្បាទេតិ កិន្តិ
មេ ឥមេ កោតេ នេវ ពជ្ឈាតោ ហាយេយ្យុំ ន ចោរ
ហាយេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន
អប្បិយា ទាយាទា ហាយេយ្យុន្តិ អយំ វុច្ចតិ ព្យក្ឃបជ្ជ
អារក្ខសម្បទា ។ **តតិយា** ច ព្យក្ឃបជ្ជ កល្យា-
ណមិត្តតា ។ ឥធ ព្យក្ឃបជ្ជ កុលបុត្តោ យស្មឹ
គាមេ វា និគមេ វា បដិវសតិ តត្រ យេ តេ
ហោន្តិ គហបតិ វា គហបតិបុត្តា វា ឧហាក វា
វុឌ្ឍសីលិនោ វុឌ្ឍា វា វុឌ្ឍសីលិនោ សទ្ធាសម្បន្នា
សីលសម្បន្នា ចាគសម្បន្នា បញ្ញាសម្បន្នា តេហិ
សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ
យថាវុឌ្ឍានំ សទ្ធាសម្បន្នានំ សទ្ធាសម្បទំ អនុសិក្ខតិ
យថាវុឌ្ឍានំ សីលសម្បន្នានំ សីលសម្បទំ អនុសិក្ខតិ

ម្នាលព្យគ្ឃបជ្ជៈ កោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកំឡាំងព្យាយាម ប្រឹងប្រែង សន្សំដោយកំឡាំងដៃ បែកញើសហូរញើស ជាកោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្រនោះ បានញុំាងកោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់គ្រង ដោយគិតថា ធ្វើដូចម្តេច កុំឲ្យស្តេចទាំងឡាយ នាំយកកោគៈទាំងនេះ របស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្ទាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្តើមយកទៅបាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា អារក្ខសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះកល្យាណមិត្តតា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុក ឬ និគមណា ពួកជនណា ពោះគហបតីក្តី គហបតិបុត្រក្តី ក្លៀវក្លៃតែចំរើនដោយសីលក្តី ចាស់ហើយតែចំរើនដោយសីលក្តី បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា ដែលនៅក្នុងស្រុក ឬ និគមនោះ កុលបុត្រនោះ តែងឈរ ចរចា សាកច្ចាជាមួយនឹងពួកជនទាំងនោះ តែងសិក្សានូវសទ្ធាសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសទ្ធា តាមសមគួរ សិក្សានូវសីលសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសីល តាមសមគួរ

យថារូបានំ ចាគសម្បន្នានំ ចាគសម្បទំ អនុសិក្ខតិ
យថារូបានំ បញ្ញាសម្បន្នានំ បញ្ញាសម្បទំ អនុសិក្ខតិ
អយំ វុច្ចតិ ព្យក្ខបជ្ជ កល្យាណមិត្តតា ។ កតមា
ច ព្យក្ខបជ្ជ សមជីវិតា ។ ឥធ ព្យក្ខបជ្ជ កុលបុត្តោ
អាយញ្ច កោសានំ វិទិត្វា វយញ្ច កោសានំ វិទិត្វា
សមជីវិកំ កប្បេតិ ជាច្ចោភគ្ឃំ ជាតិហីនំ ឃរំ មេ
អាយោ វយំ បរិយោធាយ ឋស្សតិ ន ច មេ វយោ អាយំ
បរិយោធាយ ឋស្សតីតិ ។ សេយ្យថាបិ ព្យក្ខបជ្ជ តុលា-
ធារោ វា តុលាធារន្តេវាសី វា តុលំ បគ្គហេត្វា ជានាតិ
ឱនតំ ឧន្នតន្តិ ឯវមេវំ ខោ
ព្យក្ខបជ្ជ កុលបុត្តោ អាយញ្ច កោសានំ វិទិត្វា វយញ្ច
កោសានំ វិទិត្វា សមជីវិកំ កប្បេតិ ជាច្ចោភគ្ឃំ
ជាតិហីនំ ឃរំ មេ អាយោ វយំ បរិយោធាយ ឋស្សតិ
ន ច មេ វយោ អាយំ បរិយោធាយ ឋស្សតីតិ ។

សិក្ខានុវិចាគសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្ខានុវិបញ្ញាសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយបញ្ញាតាមសមគួរ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា កល្យាណមិត្តតា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ដឹងច្បាស់នូវការចំរើននៃកោគៈទាំង៣យ៉ាង ដឹងច្បាស់នូវការវិនាស៣ នៃកោគៈទាំង៣យ៉ាង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្រិតក្រៀតពេក ដោយគិតថា សេចក្តីចំរើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចំរើនបានឡើយ ។ ម្នាលព្យគ្ឃបជ្ជៈ ប្រៀបដូចជនអ្នកថ្វឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្វឹងជញ្ជីងក្តី លើកនូវជញ្ជីង ថ្វឹងហើយក៏ដឹងថា ទន់ខាងម្ខាងផង បះឡើងខាងម្ខាងផង យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រអ្នកដឹងច្បាស់នូវការចំរើន នៃកោគៈទាំង៣យ៉ាង ដឹងច្បាស់នូវការវិនាស៣ នៃកោគៈទាំង៣យ៉ាង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្រិតក្រៀតពេក ដោយគិតថា សេចក្តីចំរើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចំរើនបានឡើយ ក៏យ៉ាងនោះដែរ។

សចាយំ ព្យក្ឃបជ្ជ កុលបុត្តោ អបប្បាយោ សមានោ ពុទ្ធរំ ជីវិតំ កប្បេតិ តស្ស ភវន្តិ វត្តារោ ពុទ្ធុម្ពរខាទកញ្ញាយំ កុលបុត្តោ កោកេ ខាទតីតិ ។ សចេ បនាយំ ព្យក្ឃបជ្ជ កុលបុត្តោ មហាយោ សមានោ កសិរំ ជីវិតំ កប្បេតិ តស្ស ភវន្តិ វត្តារោ អន្ធមារកញ្ញាយំ កុលបុត្តោ មរិស្សតីតិ(១) ។ យតោ ច ខោយំ ព្យក្ឃបជ្ជ កុលបុត្តោ អាយញ្ច កោសានំ វិនិត្វា វយញ្ច កោសានំ វិនិត្វា សមជីវិតំ កប្បេតិ ឆាទ្វោសានុ្ឃ ឆាតិហីនំ ឃរំ មេ អាយោ វយំ បរិយោទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយោទាយ ឋស្សតីតិ អយំ វុច្ចតិ ព្យក្ឃបជ្ជ សមជីវិតា ។ ឃរំ សមុប្បន្នានំ ព្យក្ឃបជ្ជ កោសានំ ចត្តារិ អចាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ ចាបមិត្តោ ចាបសហាយោ ចាបសម្ផវន្ថោ ។

---

๑ ម. អធិទ្ធមរិកំ វាយំ កុលបុត្តោ មរិស្សតីតិ ។ ម. អធិដ្ឋមរណំ វាយំ កុលបុត្តោ មរិស្សតីតិ ។

ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើ កុលបុត្រនេះមានសេចក្តីចំរើនតិច ហើយ ចិញ្ចឹមជីវិតច្រើនលើសលុប អ្នកផងតែងនិយាយ ដល់កុលបុត្រនោះថា កុលបុត្រនេះ បរិភោគនូវភោគៈទាំងឡាយ ដូចជាគេស៊ីផ្លែល្វា(១) ។ ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើ កុលបុត្រនេះ មានសេចក្តីចំរើនធំ ហើយចិញ្ចឹមជីវិតដោយក្បិតក្បៀត អ្នកផងតែងនិយាយដល់កុលបុត្រនោះថា កុលបុត្រនេះមុខជានឹងស្លាប់ ។ ដោយឥតឱពាទ ។ ម្នាលព្យគ្ឃបជ្ជៈ កាលណាកុលបុត្រនេះ ដឹងច្បាស់នូវសេចក្តីចំរើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវសេចក្តីវិនាសនៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ពះខ្ពាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចំរើនរបស់អាត្មាអញ នឹងគ្របសង្កត់នូវសេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចំរើនបានឡើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សមជីវិតា ។ ម្នាលព្យគ្ឃបជ្ជៈ កាលដែលភោគៈទាំងឡាយ ចំរើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាងគឺ ជាអ្នកលេងស្រី ១ លេងសុក ១ លេងល្បែងភ្នាល់ ១ មានមិត្តដ៏លាមក មានសំឡាញ់ដ៏លាមក សមគប់នឹងបុគ្គលដ៏លាមក ១ ។

---

๑ អ្នកចង់ស៊ីផ្លែល្វា មិនបេះឲ្យល្មមតែបរិភោគផ្លែត ទៅជាប់ដើមអង្រែង ឲ្យជ្រុះផ្លែទាំងអស់នោះតែម្តង ហើយរើសយកតែផ្លែណាដែលគួរស៊ីបាន ផ្លែក្រៅពីនោះ ទៅសល់ចោលជាច្រើន ។ អដ្ឋកថា ។

សេយ្យថាបិ ព្យក្ខបជ្ជ មហាតោ តទុភយកស្ស ចត្តារិ ចេវ អាយមុខានិ ចត្តារិ ច អបាយមុខានិ តស្ស បុរិសោ យានិ ចេវ អាយមុខានិ តានិ បិទហេយ្យ យានិ ច អបាយមុខានិ តានិ វិវរេយ្យ ទេវកោ ច ន សម្មា ជារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្យក្ខបជ្ជ មហាតោ តទុភយកស្ស បរិហានិយេវ បាដិកង្ខា នោ វុឌ្ឍិ ឯវមេវ ខោ ព្យក្ខបជ្ជ ឯវំ សមុប្បន្នានំ កោធានំ ចត្តារិ អបាយមុខានិ ហោន្តិ ឥត្ថីឆុត្តោ សុរាឆុត្តោ អក្ខឆុត្តោ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ ។ ឯវំ សមុ-ប្បន្នានំ ព្យក្ខបជ្ជ កោធានំ ចត្តារិ អាយមុខានិ ហោន្តិ ន ឥត្ថីឆុត្តោ ន សុរាឆុត្តោ ន អក្ខឆុត្តោ កល្យា-ណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ ។

ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះទឹកដ៏ធំ មានផ្លូវនៃសេចក្តីចំរើន ៤ យ៉ាងផង មានប្រធាននៃសេចក្តីវិនាស ៤ យ៉ាងផង បុរសគប្បីបិទខ្ទប់នូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី គប្បីបើកបង្ហូរនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី ទាំងភ្លៀង ក៏មិនបង្អោនទូវាទឹកដោយប្រពៃក្តី ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ ស្រះដ៏ធំនោះនឹងមានសេចក្តីសាបសូន្យជាប្រាកដ មិនមានសេចក្តីចំរើនឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលកោគៈទាំងឡាយ ចំរើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាងគឺ ជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រដ៏លាមក មានសំឡាញ់ដ៏លាមក សមគប់នឹងបុគ្គលដ៏លាមក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ កាលបើកោគៈទាំងឡាយ ចំរើនឡើងយ៉ាងនេះហើយ ប្រធាននៃសេចក្តីចំរើន ៤ យ៉ាងគឺ ជាអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ក៏មានឡើង ។

សេយ្យថាបិ ព្យក្ឃបជ្ជ មហាតោ តទ្ឆាកស្ស ចត្តារំ
ថេវ អាយមុខានិ ចត្តារិ ច អថាយមុខានិ តស្ស
បុរិសោ យានិ ថេវ អាយមុខានិ តានិ វិវរេយ្យ យានិ
ច អថាយមុខានិ តានិ បិទហេយ្យ ទេវោ ច សម្មា
ធារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្យក្ឃបជ្ជ មហាតោ
តទ្ឆាកស្ស វុឌ្ឍិយេវ ថាដិកថ្ងា នោ បរិហានិ
ឯវមេវ ខោ ព្យក្ឃបជ្ជ ឯវំ សមុប្បន្នានំ ភោគានំ ចត្តារិ
អាយមុខានិ ហោន្តិ ឧ ឋ្ឋានវុដ្ឋោ ឧ សុកចវុដ្ឋោ ឧ
អក្ខធុដ្ឋោ កល្យាណមិត្តោ កល្យាណសហាយោ
កល្យាណសម្ប្បវង្កោ ។ ឥមេ ខោ ព្យក្ឃបជ្ជ ចត្តារោ
ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ ទិដ្ឋធម្ម-
សុខាយ ។ ចត្តារោមេ ព្យក្ឃបជ្ជ ធម្មា កុលបុត្តស្ស
សម្បរាយហិតាយ សំវត្តន្តិ សម្បរាយសុខាយ ។ កតមេ
ចត្តារោ ។ សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា
បញ្ញាសម្បទា ។ កតមា ច ព្យក្ឃបជ្ជ សទ្ធាសម្បទា ។
ឥធ ព្យក្ឃបជ្ជ កុលបុត្តោ សទ្ធោ ហោតិ សទ្ធហតិ

បណ្ណាសកាសង្គហិត សង្ខារវគ្គ

ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះដ៏ធំ មានផ្លូវនៃសេចក្តីចំរើន ៤ យ៉ាងផង មានប្រធាននៃសេចក្តីវិនាស ៤ យ៉ាងផង បុរសគប្បីបើកបង្ហូរទូទ្លំផ្លូវនៃសេចក្តីចំរើនទាំងនោះ របស់ស្រះនោះផង គប្បីបិទនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀង ក៏បង្អោរចុះនូវធារទឹក ដោយប្រពៃផង ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ សេចក្តីចំរើនរបស់ស្រះនោះនឹងមានប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលបើភោគៈទាំងឡាយ ចំរើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវ នៃសេចក្តីចំរើន៤យ៉ាងគឺ អ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលដ៏ល្អ ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ ៤ ប្រការនេះឯង ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍កុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខកុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ៤ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍កុងបរលោក ដើម្បីសេចក្តីសុខកុងបរលោក ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងនៃព្រះតថាគតថា

តថាគតស្ស ពោធិ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា
ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ វុច្ចតិ ព្យក្ខបជ្ជ
សទ្ធាសម្បទា ។ កតមា ច ព្យក្ខបជ្ជ សីលសម្បទា ។
ឥធ ព្យក្ខបជ្ជ កុលបុត្តោ ទាឡាតិទាតា បដិវិរតោ
ហោតិ ។ បេ ។ សុរាមេរយមជ្ជបមាទដ្ឋានា បដិវិរតោ
ហោតិ អយំ វុច្ចតិ ព្យក្ខបជ្ជ សីលសម្បទា ។ កតមា
ច ព្យក្ខបជ្ជ ចាគសម្បទា ។ ឥធ ព្យក្ខបជ្ជ កុលបុត្តោ
វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ
បយតបាណី វោសគ្គរតោ យាចយោគោ ទានសំវិភាគ-
រតោ អយំ វុច្ចតិ ព្យក្ខបជ្ជ ចាគសម្បទា ។ កតមា
ច ព្យក្ខបជ្ជ បញ្ញាសម្បទា ។ ឥធ ព្យក្ខបជ្ជ កុលបុត្តោ
បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ
អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា អយំ
វុច្ចតិ ព្យក្ខបជ្ជ បញ្ញាសម្បទា ។ ឥមេ ខោ ព្យក្ខបជ្ជ
ចត្តារោ ធម្មា កុលបុត្តស្ស សម្បរាយមហិតាយ សំវត្តន្តិ
សម្បរាយសុខាយាតិ ។

ព្រះដ៏មានព្រះភាគអង្គនោះ ។បេ។ ជាសាស្តានៃទេវតានឹងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់កំណើតថ្មីទៀតហើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថាសទ្ធាសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។បេ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សីលសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់សម ត្រេកអរ ក្នុងការចែករំលែកនូវទាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ចាគសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានប្រាជ្ញាប្រកបដោយប្រាជ្ញា ជាដំណើរយល់ការសេចក្តីចំរើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ មុះមុត ជាដំណើរយល់ការដែលអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា បញ្ញាសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំង ៤ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងលោក ដើម្បីសេចក្តីសុខក្នុងលោក ដល់កុលបុត្រ ។

ទុជ្ជាតា កម្មធេយ្យេសុ អប្បមត្តោ វិជានតា
សមំ កាយេន វាចាយ សម្មតំ អនុរក្ខតិ
សន្ធោ សីលេន សម្បន្នោ វន្ទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច សន្ទិស្សា ឃរមេសិនោ
អក្ខាតា សច្ចជាមេន ទុភយត្ថ សុខាវហា
និដ្ឋធម្មហិតត្ថាយ សម្បរាយសុខាយ ច
ឯវមេតំ កមាជ្ជានំ ចាតោ បុញ្ញំ បវឌ្ឍតីតិ ។

(៥៥) អថខោ ទុជ្ជយោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទុជ្ជយោ ព្រាហ្មណោ ភគវន្តំ ឯតទវោច មយំ ភោ គោតម(១) បឋមំ គន្ធកាមា

---

๑ ម. មយំ អស្សុ ភោ គោតម ។

កុលបុត្រ អ្នកមានឫទ្ធិយ៉ាមប្រឹងប្រែង ក្នុងទីនៃការងារទាំងឡាយ ១ មិនប្រហែសធ្វេសមានការចាត់ចែង ១ ចិញ្ចឹមដឹងស្មើ ១ ចេះថែរក្សាទ្រព្យ ដែលរកបានមក ១ មានសទ្ធា ១ បរិបូណ៌ ដោយសីល ១ ជំងន់នូវពាក្យពេចន៍ ១ ប្រាសចាកសេចក្តីកំណាញ់ រមែងជំរះនូវផ្លូវមានសួស្តី ជាផ្លូវទៅកាន់បរលោកជានិច្ច ១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរដែលព្រះដ៏មានព្រះភាគព្រះអង្គជាសច្ចនាម ទ្រង់សំដែងហើយ ដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្លែ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគនឹងបុណ្យនេះ តែងចំរើន ដល់គ្រហស្ថទាំងឡាយយ៉ាងនេះឯង ។

(៥៥) លំដាប់នោះ ទុដ្ឋយព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ នឹងពាក្យដែលគួរលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះទុដ្ឋយព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន យើងខ្ញុំមានប្រាថ្នា ដើម្បីទៅឃ្វាតចេញអំពីស្រុក

តេសញ្ញេ ភវំ គោតមោ អម្ហាកំ តថា ធម្មំ ទេសេតុ យេ
អម្ហាកំ អស្សុ ធម្មា ទិដ្ឋធម្មហិតាយ ទិដ្ឋធម្មសុខាយ
សម្បរាយហិតាយ សម្បរាយសុខាយាតិ ។ ចត្តារោមេ
ព្រាហ្មណ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ
ទិដ្ឋធម្មសុខាយ ។ កតមេ ចត្តារោ ។ ឧដ្ឋានសម្បទា
អារក្ខសម្បទា កល្យាណមិត្តតា សមជីវិតា ។ កតមា
ច ព្រាហ្មណ ឧដ្ឋានសម្បទា ។ ឥធ ព្រាហ្មណ កុល-
បុត្តោ យេន កម្មដ្ឋានេន ជីវិកំ កប្បេតិ យទិ កសិយា
យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្តេន យទិ
រាជហោរសេន យទិ សិប្បញ្ញតរេន តត្ថ ទក្ខោ ហោតិ
អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ
កាតុំ អលំ សំវិធាតុំ អយំ វុច្ចតិ ព្រាហ្មណ ឧដ្ឋាន-
សម្បទា ។ កតមា ច ព្រាហ្មណ អារក្ខសម្បទា ។
ឥធ ព្រាហ្មណ កុលបុត្តស្ស ភោគា ហោន្តិ ឧដ្ឋានវីរិ-
យាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា

ធម៌ទាំង៤ប្រការណា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោក គប្បីមានដល់ពួកយើងខ្ញុំ សូមព្រះគោតមដ៏ចំរើន ទ្រង់សំដែងនូវធម៌នោះដល់យើងខ្ញុំ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ធម៌ទាំង៤ប្រការ ៤ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺ ទដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ ។ ម្នាលព្រាហ្មណ៍ ចុះទដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយការប្រឹងប្រែងក្នុងការងារណា ទោះក្សត្តិ ជួញប្រែក្តី រក្សាគោក្តី ការងាររបស់ខ្ញាន់ធ្នូក្តី ការងាររបស់ពាជបុរសក្តី សិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយទប្បាយជាគ្រឿងពិចារណា ក្នុងការងារទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្រាហ្មណ៍ នេះហៅថា ទដ្ឋានសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះអារក្ខសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកំឡាំងព្យាយាម ប្រឹងប្រែង សន្សំដោយកំឡាំងដៃ បែកញើស ហូរញើស ជាកោគៈ ប្រកបដោយធម៌

ឧម្មុលទ្ធា តេ អារក្ខេន កុត្តិយា សម្បាទេតំ កិន្តិ មេ
ឥមេ តោតេ នេវ ភជាតោ ហាវេយ្យុំ ន ចោរ ហាវេយ្យុំ
ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា
ធាយាធា ហាវេយ្យុន្តិ អយំ វុច្ចតិ ព្រាហ្មណ អារក្ខស-
ម្បទា ។ កតមា ច ព្រាហ្មណ កល្យាណមិត្តតា ។
ឥធ ព្រាហ្មណ កុលបុត្តោ យស្មឹ តាមេ ភ ឯកមេ ភ
បដិវិសតិ តត្រយេ តេ ហោន្តិ គហបតិ ភ គហបតិបុត្តា
ភ ឧហាក ភ វុឌ្ឍសីលិនោ វុឌ្ឍា ភ វុឌ្ឍសីលិនោ
សទ្ធាសម្បន្នា សីលសម្បន្នា ចាគសម្បន្នា បញ្ញាសម្បន្នា
តេហិ សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ
យថាវុឌ្ឍានំ សទ្ធាសម្បន្នានំ សទ្ធាសម្បន្នំ អនុ-
សិក្ខតិ យថាវុឌ្ឍានំ សីលសម្បន្នានំ សីលសម្បន្នំ
អនុសិក្ខតិ យថាវុឌ្ឍានំ ចាគសម្បន្នានំ ចាគសម្បន្នំ
អនុសិក្ខតិ យថាវុឌ្ឍានំ បញ្ញាសម្បន្នានំ បញ្ញាសម្បន្នំ
អនុសិក្ខតិ អយំ វុច្ចតិ ព្រាហ្មណ កល្យាណមិត្តតា ។

បណ្ណាសកាសង្គហិត សត្វានវត្ត

កុលបុត្រនោះ រមែងញ៉ាំងកោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់គ្រងដោយគតិថាធ្វើដូចម្តេច កុំឲ្យស្តេចទាំងឡាយ នាំយកកោគៈទាំងនេះរបស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចយកទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្តើមយកទៅបាន ម្នាលព្រាហ្មណ៍ នេះហៅថាអារក្ខសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះកល្យាណមិត្តតាតើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុកឬនិគមណា ពួកជនណា ទោះគហបតីក្តី គហបតិបុត្រក្តី ក្មេងតែចំរើនដោយសីល ចាស់ហើយតែចំរើនដោយសីល បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា មាននៅក្នុងស្រុក ឬនិគមនោះ (កុលបុត្រនោះ) រមែងឈរចរចា សាកច្ចាជាមួយនឹងពួកជនទាំងនោះ តែងសិក្សាទូរស័ព្ទសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសទ្ធា តាមសមគួរ សិក្សាទូរសីលសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសីល តាមសមគួរ សិក្សាទូរចាគសម្បទា នឹងពួកជន អ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្សាទូរបញ្ញាសម្បទា នឹងពួកជន អ្នកបរិបូណ៌ ដោយបញ្ញា តាមសមគួរ ម្នាលព្រាហ្មណ៍ នេះហៅថា កល្យាណមិត្តតា ។

กตมา จ ព្រាហ្មណ សមជីវិតា ។ ឥធ ព្រាហ្មណ
កុលបុត្តោ អាយញ្ច កោតានំ វិទិត្វា វយញ្ច កោតានំ
វិទិត្វា សមជីវិកំ កប្បេតិ ជាឡ្ហោតន្តិ ជាតិហីនំ
ឯវំ មេ អាយោ វយំ បរិយាធាយ ឋស្សតិ ន ច
មេ វយោ អាយំ បរិយាធាយ ឋស្សតីតិ ។ សេយ្យថាបិ
ព្រាហ្មណ តុលាធារោ វា តុលាធារន្តេវាសី វា តុលំ
បគ្គហេត្វា ជានាតិ ឯត្តកេន វា ឧន្នតំ ឯត្តកេន វា
ឱនតន្តិ ឯវមេវ ខោ ព្រាហ្មណ កុលបុត្តោ អាយញ្ច
កោតានំ វិទិត្វា វយញ្ច កោតានំ វិទិត្វា សមជីវិកំ
កប្បេតិ ជាឡ្ហោតន្តិ ជាតិហីនំ ឯវំ មេ អាយោ វយំ
បរិយាធាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាធាយ
ឋស្សតីតិ ។ សចាយំ ព្រាហ្មណ កុលបុត្តោ អបរាយោ
សមានោ ឧឡារំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ
ឧឡារាយ ឧបដ្ឋាយិកាយ កុលបុត្តោ កោកេ ខាទតីតិ ។
សចេ បនាយំ ព្រាហ្មណ កុលបុត្តោ មហាយោ សមានោ

សោ ខោ អហំ តិក្ខត្តុំ អបវេន សមយេន អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ទុភាសញ្ហេវ សញ្ញាមិ រួចាមិ ច បស្សាមិ តាហិ ច ទេវតាហិ សទ្ធិំ សន្តិដ្ឋាមិ សល្លបាមិ សាកច្ឆំ សមាបជ្ជាមិ តា ច ទេវតា ជានាមិ ឥមា ទេវតា អមុកម្ហា ឯ អមុកម្ហា ឯ ទេវនិកាយោតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឥមស្ស កម្មស្ស វិបាកេន ឥតោ ចុតា តត្ថ ឧបបជ្ជាតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឱរិមាហារា ឱរិំសុ ខុឌ្ដកប្បដិសំវេទិនិយោតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឱរិំ-ឃាយុកា ឱរិំវិរដ្ឋិតិកាតិ តា ច ទេវតា ជានាមិ យតិ ឯ មេ តាហិ ទេវតាហិ សទ្ធិំ សន្ថិរ្ហេតុបុព្ពំ យតិ ឯ ន សន្ថិរ្ហេតុបុព្ពន្តិ ។ យាវតីវញ្ហេ មេ តិក្ខត្តុំ ឱរិំ អជ្ឈភវិំសុ អតិទេវញ្ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ

ម្នាលភិក្ខុ ចាំដ៏ឡាយ សម័យដទៃទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបចាំដ៏ឡាយផង បិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ចា ជាមួយនឹងទេវតាចាំដ៏ឡាយនោះផង ស្គាល់ទេវតាចាំដ៏នោះថា ទេវតាចាំដ៏ឡាយនេះ មកអំពីទេវនិកាយ ឯណោះ។ ដូច្នេះផង ស្គាល់ទេវតាចាំដ៏ឡាយនោះថា ទេវតាចាំដ៏ឡាយ នេះ ច្យុតអំពីទីនេះ ទៅកើតកន្លែងនោះ ដោយផលកម្មនេះ ដូច្នេះផង ស្គាល់ទេវតាចាំដ៏នោះថា ទេវតាចាំដ៏ឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាចាំដ៏នោះថា ទេវតាចាំដ៏ឡាយនេះ មានអាយុវែងយ៉ាងនេះ បិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាចាំដ៏នោះថា អាត្មាអញក្តាប់នៅជាមួយនឹងទេវតាចាំដ៏ឡាយនោះ ឬថា មិនក្តាប់នៅជាមួយទេ ដូច្នេះផង។ ម្នាលភិក្ខុចាំដ៏ឡាយ អធិទេវញ្ញាណទស្សនៈ (ការដឹងនឹងការឃើញនូវទេវតាដ៏ក្រៃលែង) របស់តថាគតមានបរិវដ្ដ ៨ ប្រការយ៉ាងនេះ មិនបរិសុទ្ធដោយណា

នេវ តាវហំ ភិក្ខវេ សនេវតេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោ បច្ចញ្ញាសិំ ។ យតោ ច ខោ មេ ភិក្ខវេ ឃវំ អដ្ឋមកំ ឧបាទាយ អនិទេវញ្ញាណទស្សនំ សុវិសុទ្ធំ អហោសិ អថាហំ ភិក្ខវេ សនេវតេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធិំ អភិសម្ពុទ្ធោ បច្ចញ្ញាសិំ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[๗๒] អដ្ឋិមានិ ភិក្ខវេ អភិភាយតនានិ ។ កតមានិ អដ្ឋ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្ពណ្ណានិ

ម្នាលភិក្ខុទាំងឡាយ តថាគត ក៏មិនថាន់ប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក នឹងព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានឹងមនុស្សជាតិបាន ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលណា អធិទេវញ្ញាណទស្សនៈ របស់តថាគតមានបរិវដ្ត ៨ ប្រការយ៉ាងនេះ បរិសុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតប្តេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានឹងមនុស្ស ។ មិនតែប៉ុណ្ណោះសោត ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់តថាគតមិនកម្រើក ជាតិនេះជាជាតិចុងក្រោយ ក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

(๗๒) ម្នាលភិក្ខុទាំងឡាយ អកិរិយាតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអកុសលកម្មណ៍ផង) នេះមាន ๘ យ៉ាង ។ ๘ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់

តានិ អភិក្កុយ្យ ជានាមិ បស្សាមីតិ ฌាំសញ្ញី ហោតិ ๕ំ
បឋមំ អភិភាយតនំ ។ អជ្ឈត្តំ រូបសញ្ញី ฌាកោ ពហិទ្ធា
រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្ពណ្ណានិ តានិ
អភិក្កុយ្យ ជានាមិ បស្សាមីតិ ฌាំសញ្ញី ហោតិ ๕ំ
ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ฌាកោ
ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្ពណ្ណានិ តានិ
អភិក្កុយ្យ ជានាមិ បស្សាមីតិ ฌាំសញ្ញី ហោតិ ๕ំ
តតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ฌាកោ ពហិទ្ធា
រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្ពណ្ណានិ តានិ
អភិក្កុយ្យ ជានាមិ បស្សាមីតិ ฌាំសញ្ញី ហោតិ ๕ំ
ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ฌាកោ ពហិទ្ធា
រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ
នីលនិភាសានិ តានិ អភិក្កុយ្យ ជានាមិ បស្សាមីតិ
ฌាំសញ្ញី ហោតិ ๕ំ បញ្ចមំ អភិភាយតនំ ។

គ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអកិរិយាតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអកិរិយាតៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអកិរិយាតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអកិរិយាតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ដូចជាផ្កាឡចង្កឹលច្រាប់ថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអកិរិយាតនៈទី ៥ ។

អដ្ឋត្តំ អរូបសញ្ញី ឍកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឍវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។ អដ្ឋត្តំ អរូបសញ្ញី ឍកោ ពហិទ្ធា រូបានិ បស្សតិ លោហិតានិ លោហិតកវណ្ណានិ លោហិត-កនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឍវំសញ្ញី ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អដ្ឋត្តំ អរូបសញ្ញី ឍកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្ស-នានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឍវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយ-តនំ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ អភិភាយតនានីតិ ។

បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានសម្បុរលឿង ជាទីចង្អុលប្រាប់ថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអតិកាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលប្រាប់ថា នេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអតិកាយតនៈទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានសម្បុរស ជាទីចង្អុលប្រាប់ថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអតិកាយតនៈទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អតិកាយតនៈមាន ៨ យ៉ាងនេះឯង ។

(๗๓) អដ្ឋមេ តិក្ខវ៎ វិមោក្ខា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេ៎ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្ពសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អដ្ឋង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចា-យតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្ពសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្ពសោ វិញ្ញាណញ្ចាយតនំ សម-តិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្ពសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។

(๗๓) ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះមាន ๘ យ៉ាង ។ ๘ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលមានរូបឈ្មាន រមែងឃើញនូវរូបគឺកសិណទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ๑ ។ បុគ្គលពួកមួយ មិនមានសេចក្តីសំគាល់នូវរូបខាងក្នុង (មានសក់ជាដើម) រមែងឃើញនូវរូបខាងក្រៅទាំងឡាយគឺកសិណ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ๒ ។ បុគ្គលមានចិត្តចុះស៊ប់ថា វណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ๓ ។ ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានដល់នូវអាកាសានញ្ចាយតនឈ្មាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ๔ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនឈ្មាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនឈ្មាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ๕ ។ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនឈ្មាន ដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនឈ្មាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ๖ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនឈ្មាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញានាសញ្ញាយតនឈ្មាន នេះជាវិមោក្ខទី ๗ ។

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ វិមោក្ខាតិ ។

(๗๔) អដ្ឋិមេ ភិក្ខវេ អនវយភោហារា ។ កតមេ អដ្ឋ ។ អនិដ្ឋេ និដ្ឋាគតិតា អស្សុតេ សុតវាគតិតា អមុតេ មុតវាគតិតា អវិញ្ញាតេ វិញ្ញាតវាគតិតា និដ្ឋេ អនិដ្ឋាគតិតា សុតេ អស្សុតវាគតិតា មុតេ អមុតវាគតិតា វិញ្ញាតេ អវិញ្ញាតវាគតិតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ អនវយភោហារាតិ ។

(๗๕) អដ្ឋិមេ ភិក្ខវេ អវយភោហារា ។ កតមេ អដ្ឋ ។ អនិដ្ឋេ អនិដ្ឋាគតិតា អស្សុតេ អស្សុតវាគតិតា អមុតេ អមុតវាគតិតា អវិញ្ញាតេ អវិញ្ញាតវាគតិតា និដ្ឋេ និដ្ឋាគតិតា សុតេ សុតវាគតិតា មុតេ មុតវាគតិតា វិញ្ញាតេ វិញ្ញាតវាគតិតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ អវយភោហារាតិ ។

ព្រោះកន្ទងន្ទូវនៃវិសញ្ញានាសញ្ញាយតនដ្ឋាន ដោយប្រការទាំងពួង បាន
ដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានឹងវេទនា) នេះជា
វិមោក្ខទី ៨ ។ ម្នាលភិក្ខុទាំងឡាយ វិមោក្ខមាន ៨ យ៉ាងនេះឯង ។

(៧៨) ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ (វោហារមិនប្រសើរ)
នេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញនិយាយថា ឃើញ ១
មិន ឮ និយាយថា ឮ ១ មិនបានហិតក្លក់ និយាយថា បានហិតក្លក់ ១
មិនដឹងនិយាយថា ដឹង ១ ឃើញនិយាយថា មិនឃើញ ១ ឮ និយាយថា
មិនឮ ១ បានហិតក្លក់ និយាយថា មិនបានហិតក្លក់ ១ ដឹង និយាយថា
មិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ មាន ៨ យ៉ាងនេះ
ឯង ។

(៧៩) ម្នាលភិក្ខុទាំងឡាយ អរិយវោហារ (វោហារដ៏ប្រសើរ) នេះ
មាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញ និយាយថា មិនឃើញ
១ មិន ឮ និយាយថា មិនឮ ១ មិនបានហិតក្លក់និយាយថា មិនបានហិត
ក្លក់ ១ មិនដឹង និយាយថា មិនដឹង ១ ឃើញ និយាយថា ឃើញ ១ ឮ
និយាយថា ឮ ១ បានហិតក្លក់ និយាយថា បានហិតក្លក់ ១ ដឹង និយាយ
ថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយវោហារមាន ៨ យ៉ាងនេះឯង ។

(๗๖) អដ្ឋិមា ភិក្ខវេ បរិសា ។ កតមា អដ្ឋ ។ ខត្តិយបរិសា ព្រាហ្មណបរិសា គហបតិបរិសា សមណបរិសា ចាតុម្មហារាជិកបរិសា តាវតឹ្តសបរិសា មារបរិសា ព្រហ្មបរិសា ។ អភិជានាមិ ខោ បនាហំ ភិក្ខវេ អនេកសតំ ខត្តិយបរិសំ ឧបសង្កមិតា(๑) ។ តត្របិ មយា សន្ទិដ្ឋបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបន្នបុព្វា តត្ត យាទិសកោ តេសំ វណ្ណោ ហោតិ តាទិសកោ មយ្ហំ វណ្ណោ ហោតិ យាទិសកោ តេសំ សរោ ហោតិ តាទិសកោ មយ្ហំ សរោ ហោតិ ធម្មិយា ច កថាយ សន្ទស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ ភាសមានញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ ភាសតិ ទេវោ វា មនុស្សោ វាតិ ធម្មិយា ច កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អន្តរធាយាមិ អន្តរហិតញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា មនុស្សោ វាតិ ។

๑ ឧបសង្កមិតាតិបិ ។

(๗๖) ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ๘ ពួក ។ ๘ ពួក តើអ្វីខ្លះ ។ គឺខត្តិយបរិសទ្យ ๑ ព្រាហ្មណបរិសទ្យ ๑ គហបតិបរិសទ្យ ๑ សមណបរិសទ្យ ๑ ចាតុម្មហារាជិកបរិសទ្យ ๑ តាវត្តឹង្សបរិសទ្យ ๑ មារបរិសទ្យ ๑ ព្រហ្មបរិសទ្យ ๑ ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្លាប់បានចូលទៅរកខត្តិយបរិសទ្យ ជាច្រើនរយ ។ ក្នុងបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសាកច្ចាជាមួយផង សម្បុររបស់ជនទាំងនោះ ក្នុងបរិសទ្យនោះ យ៉ាងណា សម្បុររបស់តថាគតក៏យ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះ យ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគត បានញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ជនទាំងនោះ មិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬមនុស្សដូច្នេះឡើយ លុះតថាគតញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគតបាត់ទៅហើយ ចំណែកជនទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។

អកិដ្ឋាឆាមិ ខោ បឆាមាំ កិស្ហេ អនេកាសតំ ព្រាហ្មណាបរិសំ ។ បេ ។ គហាបតិបរិសំ សមណាបរិសំ ចាតុម្មហារាជិកបរិសំ តាវតិំសបរិសំ មារបរិសំ ព្រហ្មបរិសំ ឧបសង្កមិត្វា ។ តត្រាបិ មយា សន្ធិសន្ធបុព្វញ្ហេ សល្ហបិតបុព្វញ្ហ សាកច្ឆា ច សមាបន្នបុព្វ តត្ថ យានិសកោ តេសំ វណ្ណោ ហោតិ តានិសកោ មយ្ហំ វណ្ណោ ហោតិ យានិសកោ តេសំ សរោ ហោតិ តានិសកោ មយ្ហំ សរោ ហោតិ ឆដ្ឋិយា ច កថាយ សន្ធស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ ភាសមានញ្ហ មំ ន ជានន្តិ កោ នុ ខោ អយំ ភាសតិ ទេវោ វា មនុស្សោ វាតិ ។ ឆដ្ឋិយា ច កថាយ សន្ធស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អន្តរធាយាមិ អន្តរហិតញ្ហ មំ ន ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា មនុស្សោ វាតិ ។ ឥមា ខោ កិស្ហេ អដ្ឋ បរិសាតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ធ្លាប់ចូលទៅរកព្រាហ្មណបរិសទ្យ ជាច្រើនវារ ។ បេ ។ ចូលទៅរក គហបតិបរិសទ្យ សមណបរិសទ្យ ចាតុម្មហារាជិកបរិសទ្យ តាវត្តឹង្សបរិសទ្យ មារបរិសទ្យ ព្រហ្មបរិសទ្យ ។ ក្នុងព្រហ្មបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសោកច្ឆាជាមួយផង សម្បុរបស់ព្រហ្មទាំងនោះ ក្នុងបរិសទ្យនោះយ៉ាងណា សម្បុរបស់តថាគត ក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគតបានញុំាងព្រហ្មទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ចំណែកព្រហ្មទាំងនោះមិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ លុះតថាគតញុំាងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគត បាត់ទៅហើយ ចំណែកព្រហ្មទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យ ៨ ពួកនេះឯង ។

បណ្ណាសកាសង្គហិតោ ចាលវគ្គោ

(๗๗) ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្ពណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលឹ បិណ្ឌាយ បាវិសិ ។ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ គណ្ហាហិ អានន្ទ និសីទនំ យេន ចាលវេតិយំ(๑) តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។

អថខោ ភគវា យេន ចាលវេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ សារន្ទទចេតិយំ រមណីយំ ចាលវេតិយំ ។

---

๑ ម.ម. ចាបាលចេតិយំ ។

(๗๗) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងក្រុងកូដាគារ-សាលា នាមហាវន ជិតក្រុងវេសាលី ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ លុះទ្រង់ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាក ក្នុងវេលាថ្ងៃឯបាវាលចេតិយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាមខាងក្រោយៗព្រះដ៏មានព្រះភាគទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគ កាលស្តេចចូលទៅកាន់បាវាល-ចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ។

យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ សោ អានន្ទ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា នុន្នរីកោ ឯឡមូគោ ករិយមានេ នុន្នរីកោ នុភាសេ ករិយមានេ ជាសក្ខិំ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ ភន្តេ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។ ឥតិយម្បិ ខោ ភគវា ។

ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចំរើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានដម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ។ បានសន្សំទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ បុគ្គលនោះ គោះបើប្រាថ្នានឹងគប្បីបិតនៅអស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចំរើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានដម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ។ បានសន្សំទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ តថាគត បើប្រាថ្នាគប្បីបិតនៅអស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាខ្មៅ-រកែ ទ្រង់ធ្វើទុកាសជាខ្មៅរកែយ៉ាងនេះហើយ ក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអាពាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ បិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគត បិតនៅអស់ ១ អាយុកល្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកទេវតា នឹងមនុស្សដូច្នេះសោះ ព្រោះមារចូលមកផ្ទៃកំនិត ។ ព្រះដ៏មានព្រះភាគទ្រង់មានព្រះពុទ្ធដីកា ជាគំរប់ពីរដងផង ។

តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ សារន្ទទចេតិយំ រមណីយំ ចាបាលចេតិយំ ។ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា ។ បេ ។ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា តំ ។ ឃាវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឥង្ឃារិកេ ឯមិត្តេ ការិយមានេ ឥង្ឃារិកេ ឥការសេ ការិយមានេ ឆាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភគ្គេ ភគវា កប្បំ តិដ្ឋតុ ភគ្គេ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។

ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះអានន្ទដ៏មានអាយុ ជាគំរប់៣ដងដ៏ផងថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ ចាបាលចេតិយ ជាទីគួរត្រេកអរ ។ ម្នាលអានន្ទ អ្នកចំពោះតាំង ៤ បើបុគ្គលណាមួយ បានចំរើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានដម្កល់ស៊ប់ បានប្រព្រឹត្តរឿយ ។ បានសន្សំទុក បានប្រារព្ធល្អហើយ ។ បេ ។ ម្នាលអានន្ទ តថាគត បើប្រាថ្នា គប្បីបិតនៅ អស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាខ្មៅកៃយ៉ាងនេះហើយ ក៏នៅតែមិនអាចយល់សេចក្តីច្បាស់លាស់ បានឡើយ ហើយមិនបានអាភតនាព្រះដ៏មានព្រះភាគ ថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ បិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចំរើន សូមព្រះសុគត បិតនៅអស់ ១ អាយុកល្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចំរើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតា និងមនុស្សទាំងឡាយដូច្នេះសោះឡើយ ព្រោះមារចូលមកវាត់គំនិត ។

អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ តគ្ឃ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា ភគវតោ អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។

អថខោ មារោ បាបិមា អចិរប្បក្កន្តេ អាយស្មន្តេ អានន្ទេ ភគវន្តំ ឯតទវោច បរិនិព្ពាតុទានិ ភន្តេ ភគវា បរិនិព្ពាតុ សុគតោ បរិនិព្ពានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្ពាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧក្ខបេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូលទៅចុះ អ្នកចូលសំគាល់នូវកាលដែលគួរនឹងទៅតឥឡូវនេះចុះ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចអង្គុយទៀបគល់ឈើមួយជិតព្រះដ៏មានព្រះភាគ ។

គ្រានោះ កាលបើព្រះអានន្ទដ៏មានអាយុ ចៀសចេញទៅ មិនយូរប៉ុន្មាន មារមានចិត្តបាប ក៏បានពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើនឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន ព្រោះថា ព្រះដ៏មានព្រះភាគ បានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុ ជាសាវ័ករបស់តថាគត ដែលឈ្លាសវៃឆ្លៀវឆ្លាស ភ្លឺរឹងក្លា ដល់នូវការកៀរកោចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀនសូត្រនូវអត្ថៈនៃអាចារ្យរបស់ខ្លួនហើយ ទ្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន

ឧបវុដ្ឋំ បរបុរាណំ សហធម្មេន សុនិក្កហិតំ និក្កហេតុ-
សបុរិសាហរិយំ ធម្មំ ទេសិស្សន្តីតិ ។ ឯតរហិ កន្តេ
កិក្ខូ កកវតោ សាវកា វិយត្តា វិនិតា វិសារទា បត្ត-
យោគក្ខេមា ពហុស្សុតា ធម្មធរ ធម្មានុធម្មប្បដិបន្នា
សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ
ឧក្កហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ
វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧបវុដ្ឋំ បរបុរាណំ
សហធម្មេន សុនិក្កហិតំ និក្កហេត្វា សបុរិសាហរិយំ
ធម្មំ ទេសេន្តិ ។ បរិនិព្វាតុកាន កន្តេ កកវា បរិនិព្វាតុ
សុកតោ បរិនិព្វានកាលោ ធាន កន្តេ កកវតោ
សាសនា ខោ បនេសា កន្តេ កិក្ខវោ ឯ
តាវមំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ
ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ ។ បេ ។ យាវ

ចានសង្កត់សង្កិនបរបក្សាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបាន
សង្កត់សង្កិនដោយល្អតាមពាក្យ ដែលសមហេតុ ហើយសំដែងធម៌ ប្រកប
ដោយប្បាដិហារ្យ នៅមិនទាន់មាន ដរាបណាទេ តថាគតនឹងមិនទាន់
បរិនិព្វានដរាបនោះដូច្នេះ ។ បពិត្រព្រះអគ្គដ៏ចំរើន ឥឡូវនេះ ពួកភិក្ខុជា
សាវិការបស់ព្រះដ៏មានព្រះភាគ ចានឈ្លាសវៃ ភ្លៀវភ្លា ដល់នូវការក្សេម
ចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិ
ដ៏សមគួរ ប្រព្រឹត្តតាមធម៌ ចាំធ៌ចានរៀនទូវាទៈនៃអាចារ្យរបស់ខ្លួន ហើយ
ច្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយចានហើយ ចាំធ
សង្កត់សង្កិនបរបក្សាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលចានសង្កត់
សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ប្រកបដោយ
ប្បាដិហារ្យចានហើយ ។ បពិត្រព្រះអគ្គដ៏ចំរើន ឥឡូវនេះ សូមព្រះ
ដ៏មានព្រះភាគចរិនិព្វានទៅ សូមព្រះសុគតចរិនិព្វានទៅ បពិត្រព្រះអគ្គ
ដ៏ចំរើន ឥឡូវនេះ ជាកាលគួរនឹងចរិនិព្វាន របស់ព្រះដ៏មានព្រះភាគ
ហើយ បពិត្រព្រះអគ្គដ៏ចំរើន ព្រោះព្រះដ៏មានព្រះភាគ ត្រាស់វាចានេះ
ហើយថា ម្នាលមារមានចិត្តចាប ពួកភិក្ខុនី ជាសាវិកា របស់តថាគត
មិនទាន់មានដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។ បេ ។

មេ ឧបាសកា ន សាវកា ភវិស្សន្តិ ។ បេ ។ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧក្កហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បដិហារិយំ ធម្មំ ទេសិស្សន្តីតិ ។ ឯតរហិ កន្តេ ឧបាសិកា អភវត្តោ សាវិកា វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧក្កហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្ពុតានិ កន្តេ ភគវា បរិនិព្ពុតំ សុគតោ

ពួកឧបាសក ជាសាវក របស់តថាគត មិនខាន់មាន ដរាបណា ។បេ។ ពួកឧបាសិកា ជាសាវិកា របស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរ ដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ ចាំនូវវៀនទូវាទៈនៃអាចារ្យ របស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យ ងាយបាន បានសង្កត់សង្កិនទូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ច ដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ សំដែងធម៌ ប្រកបដោយចាដិហារ្យ នៅមិនខាន់មាន ដរាបណាទេ ។ បពិត្រព្រះអគ្គដ៏ចំរើន ឥឡូវនេះ ពួកឧបាសិកា ជាសាវិកា របស់ព្រះដ៏មានព្រះភាគ ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ចាំងបានវៀនទូវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សំដែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ចាំងសង្កត់សង្កិនទូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់ សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសំដែងធម៌ ប្រកបដោយចាដិហារ្យបានហើយ ។ បពិត្រព្រះអគ្គដ៏ចំរើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ

បរិនិព្ពានកាលោ នាធិ ភន្តេ ភគវតោ អាសិតា ខោ បនេសា ភន្តេ ភគវតា វុចតិ តាវមហំ ថាបិម បរិនិព្ពាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ។ ឯតរហិ ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ ។ បរិនិព្ពានធាតុ ភន្តេ ភគវា បរិនិព្ពាតុ សុគតោ បរិនិព្ពានកាលោ នាធិ ភន្តេ ភគវតោតិ ។ អបេក្ខាសុរោ ភូ ថាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្ពានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្ពាយិស្សតីតិ ។ អថខោ ភគវា ចាតុលេតិយេ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ ។

បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចំរើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា នឹងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតានឹងមនុស្ស មិនទាន់ចេះសំដែងបាន ដោយប្រពៃ ដរាបណា តថាគតនឹងមិនបរិនិព្វាន ដរាបនោះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះដ៏មានព្រះភាគនេះ បានខ្ជាប់ខ្ជួនហើយ បានចំរើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានឹងមនុស្ស ចេះសំដែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះដ៏មានព្រះភាគហើយ ។ ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ ឰដ៏បារាលចេតិយ ។

ตุสฺมิญฺเจ กจฺจายน อายุสฺมา เอวมาห มหากจฺจายโน
อโหสิ ภิกฺขนฺตเรน สเลเขน ปาฏิปทิเกน
จ ปณฺฑิเตน ฯ อถโข กจฺจาย ปจฺจตฺตญฺเว ปฏิสงฺขา
ยโย เอกมนฺตเ นิสีทิ นิสีทเนสิ

ตุมฺเหตุมฺเหปิ สพฺเพ กจฺจายนมาสชฺชิ มุนิ
อฏฺฐงฺคตเ สมาหิเต อกิญฺจิ จกฺขุมิตฺตสมฺปนฺเน ฯ
อถโข อายสฺมเต อานนฺทสฺส เอตทโหสิ มหา
ยโย ภิกฺขเว สุมหา ยโย ภิกฺขเว
ภิกฺขนฺตเรน สเลเขน ปาฏิปทิเกน จ
ปณฺฑิเตน ฯ เอกา นุ โข เหตุ เอกา ปจฺจโย
มหเต ภิกฺขเว สฺส ชาตุกามยาติ ฯ อถโข
อายสฺมา อานนฺโท เยน ภควา เตนุปสงฺกมิ
อุปสงฺกมิตฺวา ภควนฺตเ อภิวาเทตฺวา เอกมนฺตเ นิสีทิ ฯ

លុះព្រះដ៏មានព្រះភាគ ទ្រង់ជាក់អាយុសង្ខារហើយ កំកើតការភ្ញាក់ផ្អើលដ៏ធំ គួរឲ្យភ្ញក់ភ្ញឹកព្រឺព្រួចរោម ទាំងផ្គរកំណាន់ឮឡើង ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ កំបន្ទឺនូវឧទាននេះ ក្នុងវេលានោះថា

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញ នូវព្រះនិព្វាន ដែលមានគុណថ្លឹងមិនបានផង នូវកពផង ទ្រង់លះបង់នូវសង្ខារ ដែលនាំសត្វទៅកាន់កំណើត ទ្រង់គ្រែកអានូវអាវុធ ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំហើយ (ដោយអំណាចសមថៈ) ទ្រង់បានទំលាយនូវបណ្តាញគឺតិលេស ដែលកើតមាននៅ ក្នុងព្រះអង្គដូចជាក្រោះ ។

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យភ្ញក់ភ្ញឹក ឲ្យព្រឺព្រួចរោម ទាំងផ្គរកំណាន់ឮឡើង ។ ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំម្ល៉េះ ។ ទើបព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។

ឯកមន្តំ ឆិសិង្ឃោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច មហា វតាយំ ភន្តេ ភូមិចាលោ សុមហា វតាយំ ភន្តេ ភូមិចាលោ ភីសនកោ សលោមហំសោ ទេវទុន្ទភិយោ ច ផលឹសុ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ មហាតោ ភូមិចាលស្ស ចាតុភាវយាតំ ។

អដ្ឋមេ អានន្ទ ហេតូ អដ្ឋ បច្ចយា មហាតោ ភូមិចាលស្ស ចាតុភាវយ ។ កតមេ អដ្ឋ ។ យំ អានន្ទ មហាបឋវី ឧទកេ បតិដ្ឋិតា ឧទកំ វាតេ បតិដ្ឋិតំ វាតោ អាកាសដ្ឋោ ហោតិ សោ អានន្ទ សមយោ យំ មហាវាតា វាយន្តិ មហាវាតា វាយន្តា ឧទកំ កម្បេន្តិ ឧទកំ កម្បិតំ បឋវីំ កម្បេតិ អយំ អានន្ទ បឋមោ ហេតុ បឋមោ បច្ចយោ មហាតោ ភូមិចាលស្ស ចាតុភាវយ ។ បុន ចបរំ អានន្ទ សមណោ វា ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ ទេវតា មហិទ្ធិកា មហានុភាវា

លុះព្រះអានន្ទដ៏មានអាយុ គង់កន្លងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចំរើន ការកក្រើកផែនដីនេះ ធំពេកណាស់តើ គួរឲ្យភ្ញក់ភ្ញឹក គួរឲ្យព្រឺព្រួចរោម ទាំងផ្គរកំលាន់ឮម្ល៉ើង ។ បពិត្រព្រះអង្គដ៏ចំរើន ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំម្ល៉ះ ។

ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកើតការកក្រើកផែនដីនេះមាន ៨ យ៉ាង ។ ហេតុបច្ច័យទាំង ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអានន្ទ មហាប្រឋពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់បក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដី ឲ្យកក្រើកដែរ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិដល់នូវការស្គាត់ជំនាញ ក្នុងចិត្តឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ

ตสฺส ปริตฺตา ปภาสญฺา ภาวิตา โหติ อปฺปมาณา อาโภสญฺา โส ๙มํ ปภาๆ กเรติ สหเรติ สมฺปกเรติ อยํ อานนฺท ทุติโย โหตุ ทุติโย ปฏิโย มหาโส ภูมิจาลสฺส ตาตุภาวาย ฯ ปุน จปรํ อานนฺท ยถา เจตสา จิตฺตา สโต สมฺปชาโน มาตุ กุจฺฉิ ๆกฺกมติ ตถายํ ปภาๆ กเรติ สหเรติ สมฺปกเรติ อยํ อานนฺท ตติโย โหตุ ตติโย ปฏิโย มหาโส ภูมิจาลสฺส ตาตุภาวาย ฯ ปุน จปรํ อานนฺท ยถา เจตสา สโต สมฺปชาโน มาตุ กุจฺฉิสฺมา นิกฺกมติ ตถายํ ปภาๆ กเรติ สหเรติ สมฺปกเรติ อยํ อานนฺท จตุตฺโถ โหตุ จตุตฺโถ ปฏิโย มหาโส ภูมิจาลสฺส ตาตุภาวาย ฯ ปุน จปรํ อานนฺท ยถา ตถาคโส อนุตฺตรํ สมฺมาสมฺโพธึ อภิสมฺพุชฺฌติ ตถายํ ปภาๆ กเรติ สหเรติ สมฺปกเรติ

បុគ្គលនោះ ឋានចំរើនបឋវីសញ្ញា ឲ្យមានកំឡាំងតិច ចំរើនអាបោសញ្ញា ឲ្យមានកំឡាំងច្រើន បុគ្គលនោះ រមែងធ្លើផែនដីនេះ ឲ្យកក្រើករំពើប ញាប់ញ័រឋាន ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ២ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ ច្យុតចាកពួកទេវតា ដែលឋិតនៅក្នុងឋានតុសិតមានសតិនឹងសម្បជញ្ញៈ ចាប់បដិសន្ធិក្នុងព្រះមាតុទេវី ក្នុងកាលនោះផែនដីនេះ តែងកក្រើករំពើប ញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើកផែនដី ជាពន្លឹងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលពោធិសត្វ មានសតិនឹងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុទេវី ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើបញាប់ញ័រ

អយំ អានន្ទ បញ្ចមោ ហេតុ បញ្ចមោ បច្ចយោ មហតោ ភូមិជាលស្ស ជាតុភាវាយ ។ បុន ចបរំ អានន្ទ យថា តថាគតោ អនុត្តរំ ធម្មចក្កំ បវត្តេតិ តថាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ ឆដ្ឋោ ហេតុ ឆដ្ឋោ បច្ចយោ មហតោ ភូមិជាលស្ស ជាតុភាវាយ ។ បុន ចបរំ អានន្ទ យថា តថាគតោ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជតិ តថាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ សត្តមោ ហេតុ សត្តមោ បច្ចយោ មហតោ ភូមិជាលស្ស ជាតុភាវាយ ។ បុន ចបរំ អានន្ទ យថា តថាគតោ អនុបាទិសេសាយ និព្ពានធាតុយា បរិនិព្ពាយតិ តថាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ អដ្ឋមោ ហេតុ អដ្ឋមោ បច្ចយោ មហតោ ភូមិជាលស្ស ជាតុភាវាយ ។

ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ញុំាងអនុត្តរធម្មចក្រ ឲ្យប្រព្រឹត្តទៅ កាលនោះផែនដីនេះ តែងកក្រើករំពើបញ្ជាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៦ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគតមានសតិនឹងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំពើបញ្ជាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត បរិនិព្វាន ដោយអនុបាទិសេសនិព្វានជាតុ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំពើបញ្ជាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំ ។

ឥមេ ខោ អានន្ទ អដ្ឋ ហេតូ អដ្ឋ បច្ចយា មហតោ ភូមិចាលស្ស ចាតុភាវាយាតិ ។

ចាលវគ្គោ ទុតិយោ[1] ។

តតិយវគ្គោ

ឥច្ឆា អលញ្ច សំវិត្តំ កយា អកិរុជា តេ សហ វិមោក្ខោ ទ្វេ ច ភេមាភ បវិសា ភូមិចាលេន ចាតិ ។

---

១ ម. ព្រូមិចាលវគ្គោ ទុតិយោ ។

ម្នាលអានន្ទ ហេតុបច្ច័យ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ
មាន ៨ យ៉ាងនេះឯង ។

ចប់ ចាលវគ្គទី ២ ។

ឧទ្ទាននៃចាលវគ្គនោះ គឺ

និយាយអំពីសេចក្តីប្រាថ្នា ១ កិកុដែលគួរ ១ ព្រះដ៏មានព្រះ
ភាគទ្រង់សំដែងធម៌ ដោយសង្ខេប ១ ព្រះដ៏មានព្រះភាគ
ទ្រង់គង់ក្នុងគយាសីសប្រទេស ១ អកិកាយតនៈ ១ វិមោក្ខ ១
អាហារ ៤លើក បរិសទ្យ ១ ផែនដីកក្រើក ១ ។

(៧៨) សទ្ធោ កិក្ខវេ កិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតុំ កិត្តាមហំ(១) សទ្ធោ ច អស្សទ្ធំ សីលវា ចាតិ យតោ ច ខោ កិក្ខវេ កិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច កិក្ខវេ កិក្ខុ ហោតិ សីលវា ច នោ ពហុស្សុតោ ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន អង្គំ បរិបូរេតុំ កិត្តាមហំ សទ្ធោ ច អស្សទ្ធំ សីលវា ច ពហុស្សុតោ ចាតិ យតោ ច ខោ កិក្ខវេ កិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច កិក្ខវេ កិក្ខុ ហោតិ សីលវា ច ពហុស្សុតោ ច នោ ធម្មកថិកោ ។បេ។ ធម្មកថិកោ ច នោ បរិសាវចរោ ។ បេ ។ បរិសាវចរោ ច នោ វិសារទោ បរិសាយ ធម្មំ ទេសេតិ ។ បេ ។

---

១ ម.ម. កិត្តាហំ ។

យមកវគ្គ

(៧៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សុតទេ យ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សុតផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សុតផងហើយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សុតផង តែមិនមែនធម្មកថិកទេ ។ បេ ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។ បេ ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកភ្លៀវក្លា ខាងសំដែងធម៌កណ្តាលបរិសទ្យទេ ។ បេ ។

វិសារទោ ច បវិសារទេ ឆម្ចំ ទេសេតិ នោ ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។បេ។ ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន អបរិហីនោ ហោតិ តេន តំ អង្គំ បរិហីនត្តំ កិញ្ចាបិ សទ្ធោ ច អស្ស សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បវិសារទោ ច វិសារទោ ច បវិសាយ ធម្មំ ទេសេយ្យំ ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ

ជាអ្នកភ្ញៀវភ្លា ខាងសំដែងធម៌កណ្តាលបរិសទ្យផង តែជាអ្នកមិនបានតាមប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវឈានទាំង៤ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នទេ។បេ។ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង៤ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង តែមិនធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ក្នុងបច្ចុប្បន្នទេ យ៉ាងនេះ ទើបកិរិយានោះ ឈ្មោះថាមិនបរិបូរដោយអង្គនោះ កិរិយានោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកភ្ញៀវភ្លាខាងសំដែងធម៌កណ្តាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង៤ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ នឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង

យតោ ច ខោ កិក្ខវៃ កិក្ខុ សង្ខោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បវិសារជពៃ ច វិសារទោ ច បវិសាយ ធម្មំ ទេសេតិ ចតុន្នំ ឈានានំ អភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន បវិប្ផរោ ហោតិ ។ ឥមេហិ ខោ កិក្ខវៃ អដ្ឋហិ ធម្មេហិ សមន្នាគតោ កិក្ខុ សមន្តប្បាសាទិកោ ច ហោតិ សញ្ញាការបវិប្ផរោ ចាតិ ។

[៧៩] សង្ខោ កិក្ខវៃ កិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេន អង្គេន អបវិប្ផរោ ហោតិ តេន តំ អង្គំ បវិប្ផរេតព្ពំ កិន្នាហំ សង្ខោ ច អស្សុំ សីលវា ចាតិ យតោ ច ខោ កិក្ខវៃ កិក្ខុ សង្ខោ ច ហោតិ

ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកភ្លៀវភ្លាខាងសំដែងធម៌កណ្តាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នាបានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ ទិដ្ឋធម្មវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរ ដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ឲ្យកើតដោយត្រប់ត្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរ ដោយអាការៈ គឺចំណែកនៃសមណធម៌សព្វត្រប់ផង ។

(៧៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនបរិបូរ ដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកមានសទ្ធាផង

សីលវា ច ឃវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច កិត្តាវ កិត្តុ ហោតិ សីលវា ច នោ ពហុស្សុតោ ។បេ។ ពហុស្សុតោ ច នោ ធម្មកថិកោ ។បេ។ ធម្មកថិកោ ច នោ បរិសាវចរោ ។បេ។ បរិសាវចរោ ច នោ វិសារទោ បរិសាយ ធម្មំ ទេសេតិ ។ បេ ។ វិសារទោ ច បរិសាយ ធម្មំ ទេសេតិ(๑)យេ ច តេ សទ្ធា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរតិ នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឃវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតុំ កិត្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេយ្យំ យេ ច តេ សទ្ធា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរេយ្យំ

---

๑ ម. ម. ឯត្ថន្តរេ នោ ចាតិ អបំ ជាហោ ទិស្សតិ ។

មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សុតទេ ។ បេ ។ ជាពហុស្សុតផង តែមិនមែនជាធម្មកថិកទេ ។ បេ ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។ បេ ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកភ្លៀវភ្លាខាងសំដែងធម៌តណ្ហាលបរិសទ្យទេ ។ បេ ។ ជាអ្នកភ្លៀវភ្លាខាងសំដែងធម៌តណ្ហាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបដ្ឋានដែលកន្លងផុតនូវរូបដ្ឋាន ដោយនាមកាយផង តែមិនទាន់ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ ប្បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននៅឡើយ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនទាន់បរិបូរ ដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សុតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកភ្លៀវភ្លាខាងសំដែងធម៌តណ្ហាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបដ្ឋាន ដែលកន្លងផុតរូបដ្ឋាន ដោយនាមកាយផង

អាសវានំ ខយា អនាសវំ ចេតោវិមុត្តិំ បញ្ញាវិមុត្តិំ ឥដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បវិសារទចរោ ច វិសារទោ ច បវិសាយ ធម្មំ ទេសេតិ យេ ច តេ សត្តា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរតិ អាសវានំ ខយា ។បេ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន បវិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្ត-បាសាទិកោ ច ហោតិ សញ្ញាការបវិបូរោ ចាតិ ។

(๘๐) ឯកំ សមយំ កកវា ជាតិកេ វិហរតិ កិញ្ជក្កវាសេ ។ តត្រ ខោ កកវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ កកវតោ បច្ចស្សោសុំ ។ កកវា ឯតទវោច មរណស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ

ជានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ ទំនឹងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសំដែងធម៌ណាមេបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបផង ដែលកន្លងផុតនូវរូបផង ដោយនាមកាយផង ជានធ្វើឲ្យជាក់ច្បាស់ ។ ល ។ ព្រោះអស់អាសវៈទាំងឡាយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរ ដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ឲ្យកើតដោយគ្រប់គ្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរ ដោយអាការៈ គឺចំណែកនៃសមណធម៌សព្វគ្រប់ផង ។

(๘๐) សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងឥតិញ្ញកាសេដ្ឋៈ (ប្រាសាទឥដ្ឋ) ដ៏តនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចំរើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន

មហានិសំសា អមតោគធា អមតបរិយោសានា តាវជ
ញ្ញោ តុម្ហេ កិត្តាវ មរណាសតិត្ថ ។

ឯវំ វុត្តេ អញ្ញតរោ កិត្តុ តថាវំ ឯតទវោច អហំ
ខោ អាវុ តាវមិ មរណាសតិត្ថ ។ យថាតថំ បន តុម្ភំ
កិត្តុ តាវសិ មរណាសតិត្ថ ។ ឥធ មយ្ហំ អាវុ ឯវំ
ហោតិ អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ តថាគតោ សាសនំ
មនសិតាវេយ្យំ ពហុ វត មេ តតមស្សាតិ ឯវំ ខោ
អហំ អាវុ តាវមិ មរណាសតិត្ថ ។

អញ្ញតរោបិ ខោ កិត្តុ តថាវំ ឯតទវោច អហំបិ
ខោ អាវុ តាវមិ មរណាសតិត្ថ ។ យថាតថំ បន តុម្ភំ
កិត្តុ តាវសិ មរណាសតិត្ថ ។ ឥធ មយ្ហំ អាវុ ឯវំ
ហោតិ អហោ វតាហំ ទិវសំ ជីវេយ្យំ តថាគតោ សាសនំ
មនសិតាវេយ្យំ ពហុ វត មេ តតមស្សាតិ ឯវំ ខោ
អហំ អាវុ តាវមិ មរណាសតិត្ថ ។

មានអានិសង្សច្រើន ឈមចុះទាន់អមតៈ មានអមតៈជាទីបំផុត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចំរើនមរណស្សតិ ចុះ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅ អស់យប់ទំងឹថ្ងៃ អាត្មាអញ គប្បីធ្វើទុកតាមចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន (តាមសាសនារបស់ព្រះអង្គ) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅអស់ ១ ថ្ងៃ អាត្មាអញ ធ្វើទុកតាមចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិយ៉ាងនេះ ។

អញ្ញតរោបិ ខោ តិត្ថ្ថ កតវន្តំ ឯតទវោច អហំបិ ខោ កន្តេ ភាវមិ មរណាស្សតិន្តិ ។ យថាកថំ បន ត្វំ តិត្ថ្ថ ភាវេសិ មរណាស្សតិន្តិ ។ ឥធ មយ្ហំ កន្តេ ឯវំ ហោតិ អហោ វតាហំ ឧបឌ្ឍធិវសំ ជីវេយ្យំ តថាគតោ សាសនំ មនសិករេយ្យំ ពហុ វត មេ តតមស្សាតិ ឯវំ ខោ អហំ កន្តេ ភាវមិ មរណាស្សតិន្តិ ។

អញ្ញតរោបិ ខោ តិត្ថ្ថ តតវន្តំ ឯតទវោច អហំបិ ខោ កន្តេ ភាវមិ មរណាស្សតិន្តិ ។ យថាកថំ បន ត្វំ តិត្ថ្ថ ភាវេសិ មរណាស្សតិន្តិ ។ ឥធ មយ្ហំ កន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯតំ បិណ្ឌាចាតំ កុញ្ជមិ តថាតោ សាសនំ មនសិករេយ្យំ ពហុ វត មេ តតមស្សាតិ ឯវំ ខោ អហំ កន្តេ ភាវមិ មរណាស្សតិន្តិ ។

អញ្ញតរោបិ ខោ តិត្ថ្ថ តតវន្តំ ឯតទវោច អហំបិ ខោ កន្តេ ភាវមិ មរណាស្សតិន្តិ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្លើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅអស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្លើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្លើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្លើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈធាន់ចង្ហាន់បិណ្ឌបាតមួយ អាត្មាអញ គប្បីធ្លើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្លើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះ ថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិដែរ ។

ยถากถំ បន ភិក្ខុ ភាវេសិ មរណសฺสតិន្តិ ។ ឥធ មយ្ហំ កន្តេ ឯវំ ហោតិ អហោ វតាหំ តទន្តរំ ជីវេยฺยំ យទន្តរំ ឧបឌ្ឍបិណ្ឌបាតំ ភុញ្ជាមិ តាវតោ សាសនំ មនសិការេยฺยំ ពហុ វត មេ តតមសฺสតិ ឯវំ ខោ អหំ កន្តេ ភាវេមិ មរណសฺสតិន្តិ ។

អញ្ញតរោបิ ខោ ភិក្ខុ តាវន្តំ ឯតទហោ អหំបิ ខោ កន្តេ ភាវេមិ មរណសฺสតិន្តិ ។ យถากถំ បន ភិក្ខុ ភាវេសិ មរណសฺสតិន្តិ ។ ឥធ មយ្ហំ កន្តេ ឯវំ ហោតិ អហោ វតាหំ តទន្តរំ ជីវេยฺยំ យទន្តរំ ចតฺตาរោ បញ្ច អาលោបេ សង្ខាទិតฺวา(๑) អជฺឈោหរามิ តាវតោ សាសនំ មនសិការេยฺยំ ពហុ វត មេ តតមសฺสតิ ឯវំ ខោ អหំ កន្តេ ภาវេมิ มรณสฺสติន្តิ ។

๑ ម. សង្ខาទิตฺวา ។

ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅបានត្រឹមខណៈ ឆាន់បង្ហាន់បិណ្ឌបាតតាក់តណ្ហាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅបានត្រឹមខណៈ ដែលទំពាំនូតបាយ ៤ ឬ ៥ ពំនូត លេបបូល ៧ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិ យ៉ាងនេះ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណាស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណាស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯតំ អាលោបំ សង្ហរិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិការេយ្យំ ពហុ វត មេ កតមស្សាតំ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណាស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណាស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណាស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ អស្សសិត្វា វ បស្សសាមិ បស្សសិត្វា វ អស្សសាមិ ភគវតោ សាសនំ មនសិការេយ្យំ ពហុ វត មេ កតមស្សាតំ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណាស្សតិន្តិ ។

បណ្ណាសកាង្គហិត យមកវគ្គ

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈ តំណាលបអស់ ១ ពំនូត អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើតិចតួចការ ឲ្យបានច្រើនបពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចំរើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចំរើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូល ហើយចេញ ឬដកដង្ហើមចេញ ហើយចូល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើតិចតួចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គ ចំរើនមរណស្សតិ យ៉ាងនេះ ។

ឃំ វុត្តេ ភគវា តេ ភិក្ខូ ឯតទវោច យ្វាយំ ភិក្ខវេ ភិក្ខុ ឃំ មរណាសប្បតិំ ភាវេតិ អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ(๑) ភិក្ខវេ ភិក្ខុ ឃំ មរណាសប្បតិំ ភាវេតិ អហោ វតាហំ ទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឃំ មរណាសប្បតិំ ភាវេតិ អហោ វតាហំ ឧបឌ្ឍទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឃំ មរណាសប្បតិំ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ បិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឃំ មរណាសប្បតិំ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឧបឌ្ឍបិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។

---

๑ ម.ន. យោបាយំ ។

កាលបើ ពួកភិក្ខុទាំងនោះ ក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទើបអាត្មាអញ គប្បីរស់នៅ អស់យប់នឹងថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិដោយសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទើបអាត្មាអញ គប្បីរស់នៅអស់ ១ថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅ អស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទើបអាត្មាអញគប្បីរស់នៅត្រឹមខណៈធាន់ចង្ហាន់បិណ្ឌបាតមួយ អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។

យោ ចាយំ ភិក្ខវេ ភិក្ខុ ឥមំ មរណាសតិំ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ចតុរោ បញ្ច អាលោបេ សង្ខាទិត្វា អជ្ឈោហរាមិ កល្លចិតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សតិ ។ ឥមេ ត្វេវន្តិ ភិក្ខវេ ភិក្ខូ បមត្តា វិហរន្តិ ទន្ធំ មរណាសតិំ ភាវេន្តិ អាសវានំ ខយាយ ។

យោ ចាយំ(๑) ភិក្ខវេ ភិក្ខុ ឥមំ មរណាសតិំ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ អាលោបំ សង្ខាទិត្វា អជ្ឈោហរាមិ កល្លចិតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឥមំ មរណាសតិំ ភាវេតិ

๑ ឧ.ម. យោ ច ភុយំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទ្បើអាត្មាអញ គប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ទ្បើបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទ្បើអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ទ្បើបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថា មានសេចក្តីប្រមាទនៅឡើយ ចំរើនមរណស្សតិ ដើម្បីធ្វើទ្បើអស់អាសវៈទាំងឡាយ យឺតយូរទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ទ្បើអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាលេបបាយ ១ ពំនូត អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ទ្បើបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចំរើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បានទូវៅជនថោកជាប ឬថ្ងៃថ្ងូ លុម ១ ចំអែតភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញ ត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បានទូវៅជនថោកជាប ឬថ្ងៃថ្ងូ លុម ១ ចំអែតហើយ

ตสฺส เม ภาเยยฺย ลหุภกา ภเยฺยน ภาเยยฺยุ ภีรุกชาติกา ภีรุกชาติกสฺส เม ภยปฺปหานาย ธมฺมา เทสิตา ภวนฺติ ฯเปฯ ปฐมํ ภิกฺขเว ฐานํ อาคจฺฉติ ฯ

ปุน จปรํ ภิกฺขเว ภิกฺขุโน อุปฺปชฺเชยฺย โหติ อปฺปมตฺตโก อาพาโธ ตสฺส เม ภยปฺปหานาย ธมฺมา เทสิตา ภวนฺติ อยมฺปิ เม อปฺปมตฺตโก อาพาโธ ฐานเมตฺถ วิชฺชติ ยนฺนูนาหเมว ปหีนาย ปฏิปชฺเชยฺยนฺติ ปหีนาย ปฏิปชฺชติ ภีรุกชาติกสฺส เม ภยปฺปหานาย ธมฺมา เทสิตา ภวนฺติ ฯเปฯ ทุติยมฺปิ ภิกฺขเว ฐานํ อาคจฺฉติ ฯ

ปุน จปรํ ภิกฺขเว ภิกฺขุ ตีหิ ฐาเนหิ ปุคฺคโล โหติ อตีตปุคฺคโล เกลญฺญา ตสฺส เม ภยปฺปหานาย ธมฺมา เทสิตา ภวนฺติ อหมฺปิ เม ตีหิ ฐาเนหิ ปุคฺคโล อตีตปุคฺคโล เกลญฺญา ฐานเมตฺถ วิชฺชติ ยนฺนูนาหเมว ปหีนาย ปฏิปชฺเชยฺยนฺติ ปหีนาย ปฏิปชฺชติ ภีรุกชาติกสฺส ปตฺตยา

អាត្មាអញនោះមានរាងកាយស្រាល គួរដល់សមណកម្ម បើដូច្នោះ អាត្មាអញ ផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអាវុត្តិ ទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ កើតអាពាធតិចតួចនេះហើយ អាពាធចំរើនដល់អាត្មាអញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញ ផ្គងព្យាយាមឲ្យបានមុនសិន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអាវុត្តិ ទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចេញចាកជម្ងឺ ទើបតែស្បើយជម្ងឺថ្មី ។ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជម្ងឺ ទើបតែស្បើយជម្ងឺថ្មី ។ អាពាធរបស់អាត្មាអញ រើឡើងវិញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញផ្គងព្យាយាមឲ្យបានមុន ដើម្បីឲ្យដល់នូវគុណ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់សិន ភិក្ខុនោះក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់

បណ្ណាសកាសង្គហំតោ យមកវគ្គោ

អនធិកតស្ស អធិកមាយ អសង្ខិកតស្ស សង្ខិការំ-
យាយាតំ សោ ភិយ្យំ អារភតិ អប្បត្តស្ស បត្តិយា
អនធិកតស្ស អធិកមាយ អសង្ខិកតស្ស
សង្ខិការិយាយ ឥទំ កិក្ខវេ អដ្ឋមំ អារព្ភវត្ថុ ។ ឥមានិ
ខោ កិក្ខវេ អដ្ឋ អារព្ភវត្ថូនិ ។

យមកវគ្គោ តតិយោ ។

តត្រុទ្ទានំ

ទ្វេ បដិបទា អបរេ(๑) ឥច្ឆា លជ្ជា(๒) បរិហានំ
កុសីតំ អារព្ភវត្ថូនិ ។

---

๑ ឆ.ម. ទ្វេ សទ្ធា ទ្វេ មរណេស្សតិ ទ្វេ សម្បជ អថាបរេ ។ ๒ ឥច្ឆា អលំ ។

ដើម្បីឲ្យដឹងនូវគុណដែលខ្លួនមិនទាន់ឃានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណដែលខ្លួនមិនទាន់ឃានធ្វើឲ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអាវុត្តិ ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអាវុត្តិទាំង ៨ យ៉ាង ។

ចប់ យមកវគ្គ ទី ៣ ។

ខុទ្ទកវត្ថុនៃយមកវគ្គគោះគឺ

និយាយពីភិក្ខុបរិបូរ ដោយអង្គពីរលើក សម្បទា ១ ភិក្ខុចំពោះមរណស្សតិដទៃទៀត ១ សេចក្តីប្រាថ្នាលាភ ១ គួរដល់ខ្លួនឯងអ្នកដទៃ ១ សេចក្តីសាបសូន្យ របស់សេក្ខភិក្ខុ ១ កុសីតវត្តុ ១ អាវុត្តិ ១ ។

(៩៧) សតិសម្បជញ្ញេ កិច្ចវសេ អសតិ សតិសម្ប-
ជញ្ញវិបន្នស្ស ហត្ថបធិសំ ហោតិ ហិរោត្តប្បំ ហិរោត្តប្ប
អសតិ ហិរោត្តប្បវិបន្នស្ស ហត្ថបធិសោ ហោតិ ឥន្ទ្រិ-
យសំវរេ ឥន្ទ្រិយសំវរេ អសតិ ឥន្ទ្រិយសំវរវិបន្នស្ស
ហត្ថបធិសំ ហោតិ សីលំ សីលេ អសតិ សីលវិបន្នស្ស
ហត្ថបធិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ
អសតិ សម្មាសមាធិវិបន្នស្ស ហត្ថបធិសំ ហោតិ យថា-
ភូតញាណទស្សនំ យថាភូតញាណទស្សនេ អសតិ
យថាភូតញាណទស្សនវិបន្នស្ស ហត្ថបធិសោ ហោតិ
និព្ពិទាវិរាគេ និព្ពិទាវិរាគេ អសតិ និព្ពិទាវិរាគវិបន្នស្ស
ហត្ថបធិសំ ហោតិ វិមុត្តិញាណទស្សនំ ។ សេយ្យថាបិ
កិច្ចវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បច្ឆិមោបិ
ន ថាវិប្ផរិកត្តតិ តថោបិ ផេគ្គុបិ សារោបិ ន ថាវិប្ផរិកត្តតិ

(៨៧) ម្នាលភិក្ខុទាំងឡាយ កាលបើសតិនិទ្ទេសសម្បជញ្ញៈ មិនមាន ហិរិនិទ្ទេសចិត្តប្បៈ របស់បុគ្គលរបៀតបៀនចាកសតិនិទ្ទេសសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើហិរិនិទ្ទេសចិត្តប្បៈ មិនមាន ឥន្ទ្រិយសំវរៈ របស់បុគ្គលរបៀតបៀនចាកហិរិនិទ្ទេសចិត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើឥន្ទ្រិយសំវរៈ មិនមាន សីលរបស់បុគ្គលរបៀតបៀនចាកឥន្ទ្រិយសំវរៈ ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើសីល មិនមាន សម្មាសមាធិ របស់បុគ្គលរបៀតបៀនចាកសីល ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើសម្មាសមាធិមិនមាន យថាភូតញាណទស្សនៈ របស់បុគ្គលរបៀតបៀនចាកសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើយថាភូតញាណទស្សនៈ មិនមាន និព្វិទាវិរាគៈ របស់បុគ្គលរបៀតបៀនចាកយថាភូតញាណទស្សនៈ ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញាណទស្សនៈ របស់បុគ្គលរបៀតបៀនចាកនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមិនមានមែកនឹងស្វឹកហើយក្រមរឈើនោះក្តី មិនដល់នូវការពេញលេញទេ សម្បកស្រាយក្តី ខ្ចីមក្តី ក៏មិនដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ

ฝาเมว ขฺวา กิจฺจานิ สติสมฺปชญฺญ อสติ สติสมฺป-
ชญฺญวิปฺปยุตฺตสฺส ภาวูปนิสฺสยา โหนฺติ ทิฏฺฐิคตฺตญฺจ ทิฏฺฐิคตฺตญฺจ
อสติ ทิฏฺฐิคตฺตวิปฺปยุตฺตสฺส ภาวูปนิสฺสยา โหนฺติ ฯ เป ฯ
วิมุตฺติญาณธาตุยา ฯ สติสมฺปชญฺญ กิจฺจานิ สติ
สติสมฺปชญฺญสมฺปยุตฺตสฺส อุปนิสฺสยปจฺจเยน ปจฺจโย โหติ
ทิฏฺฐิคตฺตญฺจ ทิฏฺฐิคตฺตญฺจ สติ ทิฏฺฐิคตฺตสมฺปยุตฺตสฺส
อุปนิสฺสยปจฺจเยน ปจฺจโย โหติ ฯลฯ อินฺทฺริยสังวเร ฯลฯ อินฺทฺริยสังวเร
สติ ฯลฯ อินฺทฺริยสังวรสมฺปยุตฺตสฺส อุปนิสฺสยปจฺจเยน ปจฺจโย โหติ
สีลานิ สีลานิ สติ สีลสมฺปยุตฺตสฺส อุปนิสฺสยปจฺจเยน ปจฺจโย โหติ
สมฺมาสมาธิ สมฺมาสมาธิฺจ สติ สมฺมาสมาธิ-
สมฺปยุตฺตสฺส อุปนิสฺสยปจฺจเยน ปจฺจโย โหติ ยถาภูตญาณ-
ธาตุยา ยถาภูตญาณธาตุยาปิ สติ ยถาภูต-
ญาณธาตุยาสมฺปยุตฺตสฺส อุปนิสฺสยปจฺจเยน ปจฺจโย โหติ
นิพฺพิทาวิราคาย นิพฺพิทาวิราคาปิ สติ นิพฺพิทาวิราคสมฺปยุตฺตสฺส
อุปนิสฺสยปจฺจเยน ปจฺจโย โหติ วิมุตฺติญาณธาตุยา ฯ

ម្នាលភិក្ខុទាំងឡាយ កាលបើសតិនិទ្ទសម្បជញ្ញៈ មិនមាន ហិរិនិទ្ទ
ទុត្តប្បៈ របស់បុគ្គលវិបត្តិចាកសតិនិទ្ទសម្បជញ្ញៈ ឈ្មោះថាមានទុបនិស្ស័យ
សាបសូន្យ កាលបើហិរិនិទ្ទទុត្តប្បៈ មិនមាន (ឥន្ទ្រិយសំវរៈ) របស់បុគ្គល
វិបត្តិចាកហិរិនិទ្ទទុត្តប្បៈ ឈ្មោះថា មានទុបនិស្ស័យសាបសូន្យ ។ បេ ។
វិមុត្តិញាណទស្សនៈ មានទុបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង
ឡាយ កាលបើសតិនិទ្ទសម្បជញ្ញៈ មាន ហិរិនិទ្ទទុត្តប្បៈ របស់បុគ្គលបរិ-
បូណ៌ដោយសតិនិទ្ទសម្បជញ្ញៈ ឈ្មោះថា មានទុបនិស្ស័យបរិបូណ៌ កាល
បើហិរិនិទ្ទទុត្តប្បៈ មាន ឥន្ទ្រិយសំវរៈ របស់បុគ្គលបរិបូណ៌ដោយហិរិនិទ្ទ
ទុត្តប្បៈឈ្មោះថាមានទុបនិស្ស័យបរិបូណ៌ កាលបើឥន្ទ្រិយសំវរៈមាន សីល
របស់បុគ្គលបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ឈ្មោះថាមានទុបនិស្ស័យបរិបូណ៌
កាលបើសីលមាន សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសីល ឈ្មោះ
ថា មានទុបនិស្ស័យបរិបូណ៌ កាលបើសម្មាសមាធិ មាន យថាភូតញ្ញាណ-
ទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថាមានទុបនិស្ស័យ
បរិបូណ៌ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈ របស់
បុគ្គលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានទុបនិស្ស័យ
បរិបូណ៌ កាលបើនិព្វិទាវិរាគៈ មាន វិមុត្តិញាណទស្សនៈ របស់បុគ្គល
បរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា មានទុបនិស្ស័យបរិបូណ៌ ។

សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បច្ឆិមកាបិ ទារុម្ហរំ កច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ទារុម្ហរំ កច្ឆតិ ឯវមេវ ខោ ភិក្ខវេ សតិសម្បជញ្ញំ សតិសតិសម្បជញ្ញសម្បន្នស្ស ឧបធិសសម្បន្នំ ហោតិ ហិរិភេត្តប្បំ ហិរិភេត្តប្បេ សតិ ហិរិភេត្តប្បសម្បន្នស្ស ឧបធិសសម្បន្នំ ហោតិ ។ បេ ។ វិមុត្តិញ្ញាណទស្សនន្តិ ។

(๙๘) អថខោ អាយស្មា បុណ្ណាយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា បុណ្ណាយោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន អប្បេកទា តថាគតំ ធម្មទេសទា បដិ-ភាតំ អប្បេកទា ន បដិភាតីតិ ។ សន្តោ បុណ្ណាយ ភិក្ខូ ហោតិ ខោ ឧបសង្កមិតា នេវ តាវ តថាគតំ ធម្មទេសទា បដិភាតំ យតោ ច ខោ បុណ្ណាយ ភិក្ខូ សន្តោ ច ហោតិ ឧបសង្កមិតា ច ឯវំ តថាគតំ ធម្មទេសទា បដិភាតំ

ម្នាលភិក្ខុទាំងឡាយ ដើមឈើ ដែលបរិបូណ៌ ដោយមែកនឹងស្លឹកហើយ ត្រមរឈើនោះ ក៏ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី (របស់ឈើនោះ) ក៏ដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសតិនឹងសម្បជញ្ញៈ មាន ហិរិនឹងឧត្តប្បៈ របស់បុគ្គលបរិបូណ៌ ដោយសតិនឹងសម្បជញ្ញៈ ឈ្មោះថាមានឧបនិស្ស័យបរិបូណ៌ កាលបើហិរិនឹងឧត្តប្បៈ មាន (ឥន្ទ្រិយសំវរៈ) របស់បុគ្គលបរិបូណ៌ ដោយហិរិនឹងឧត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ។ បេ ។ វិមុត្តិញាណទស្សនៈ មានឧបមេយ្យយ៉ាងនោះដែរ ។

(៩៨) គ្រានោះព្រះបុណ្ណិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ហេតុអ្វី បច្ច័យអ្វី បានជាកន្លងកាលខ្លះ ព្រះតថាគតទ្រង់សំដែងធម្មទេសនា កន្លងកាលខ្លះ ក៏មិនសំដែង ។ ព្រះអង្គត្រាស់តបថា ម្នាលបុណ្ណិយៈ ភិក្ខុមានសទ្ធាហើយ តែមិនចូលមកវាកទេ តថាគតក៏មិនទាន់សំដែងធម្មទេសនា ម្នាលបុណ្ណិយៈ កាលបើភិក្ខុមានសទ្ធាផង បានចូលមកវាកផង យ៉ាងនេះ ទើបតថាគតសំដែងធម្មទេសនា

សទ្ធោ ច បុណ្ណិយ ភិក្ខុ ហោតិ ឧបសង្កមិតា ច នោ បយិរុបាសិតា ។បេ។ បយិរុបាសិតា ច នោ បរិបុច្ឆិតា បរិបុច្ឆិតា ច នោ ឧហិតសោតោ ធម្មំ សុណាតិ ឧហិតសោតោ ច ធម្មំ សុណាតិ នោ សុត្វា ធារេតិ សុត្វា ច ធម្មំ ធារេតិ នោ ធតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ ធតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ នោ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នេវ តាវ តថាគតំ ធម្មទេសនា បដិភាតិ ។ យតោ ច ខោ បុណ្ណិយ ភិក្ខុ សទ្ធោ ច ហោតិ ឧបសង្កមិតា ច បយិរុបាសិតា ច បរិបុច្ឆិតា ច ឧហិតសោតោ ច ធម្មំ សុណាតិ សុត្វា ច ធម្មំ ធារេតិ ធតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ ឯវំ តថាគតំ ធម្មទេសនា បដិភាតិ ។ ឥមេហិ ខោ បុណ្ណិយ(๑) ធម្មេហិ សមន្នាគតោ ឯកន្តប្បដិភាណំ តថាគតំ ធម្មទេសនា ហោតីតិ ។

---

๑ ម. ឯត្តាវតា អដ្ឋហីតិ អយំ ឥតោ ទិស្សតិ ។

ម្នាលបុណ្ណិយៈ កិក្ខុមានសទ្ធាផង បានចូលមករកផង តែមិនបានចូលមកអង្គុយជិត ។ បេ ។ បានចូលមកអង្គុយជិតហើយ តែមិនបានសាកសួរ បានសាកសួរហើយ តែមិនបានផ្ទៀងត្រចៀកស្តាប់ធម៌ ផ្ទៀងត្រចៀកស្តាប់ហើយ តែមិនស្តាប់ឲ្យចាំធម៌ ស្តាប់ចាំធម៌ហើយ តែមិនពិចារណានូវសេចក្តីនៃធម៌ ដែលខ្លួនចងចាំហើយ ពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនចងចាំហើយ តែមិនដឹងនូវអត្ថមិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ទេ តថាគត ក៏មិនសំដែងធម្មទេសនាឡើយ ។

ម្នាលបុណ្ណិយៈ កាលបើ កិក្ខុមានសទ្ធាផង បានចូលមករកផង បានចូលមកអង្គុយជិតផង បានសាកសួរផង បានផ្ទៀងត្រចៀងស្តាប់ធម៌ផង ស្តាប់ឲ្យចាំធម៌ផង ពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនចងចាំផង ដឹងនូវអត្ថដឹងនូវធម៌ហើយ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ផង យ៉ាងនេះទើបតថាគតសំដែងធម្មទេសនា ។ ម្នាលបុណ្ណិយៈ កិក្ខុប្រកបដោយធម៌ (៩ យ៉ាង) នេះឯង ទើបតថាគត សំដែងនូវធម្មទេសនា យ៉ាងច្បាស់លាស់ ។

[๙๙] สเจ ภิกฺขเว อญฺญติตฺถิยา ปริพฺพาชกา ฆรๆ ปุจฺเฉยฺยุ กึมูลกา อาวุโส สพฺเพ ธมฺมา กึสมฺภวา สพฺเพ ธมฺมา กึสมุทยา สพฺเพ ธมฺมา กึสโมสรณา สพฺเพ ธมฺมา กึปมุขา สพฺเพ ธมฺมา กึอธิปเตยฺยา สพฺเพ ธมฺมา กึอุตฺตริ สพฺเพ ธมฺมา กึสารา สพฺเพ ธมฺมาติ ฆรๆ ปุฏฺฐา สมฺเม ภิกฺขเว เตสๆ อญฺญติตฺถิยานๆ ปริพฺพาชกานๆ กิตฺติ ภาเสยฺยาถาติ ฯ ภควๆมูลกา โน ภนฺเต ธมฺมา ภควๆเนตฺติกา ภควๆปฏิสรณา สาธุ ภนฺเต ภควนฺตๆเยว ปฏิภาตุ ฯเปฯ สาสิตสฺส ภาสิตสฺส อตฺถา ภควาโต สุตฺวา ภิกฺขู ธาเรสฺสนฺตีติ ฯ เตนหิ ภิกฺขเว(๑) สุณาถ สาธุกๆ มนสิกโรถ ภาสิสฺสามีติ ฯ ฆรๆ ภนฺเตติ โข เต ภิกฺขู ปจฺจสฺโสสุๆ ฯ ภควา เอตทโวจ สเจ ภิกฺขเว อญฺญติตฺถิยา ปริพฺพาชกา ฆรๆ ปุจฺเฉยฺยุๆ กึมูลกา อาวุโส สพฺเพ ธมฺมา กึสมฺภวา สพฺเพ ธมฺมา กึสมุทยา สพฺเพ ธมฺมา กึสโมสรณา สพฺเพ ธมฺมา กึปมุขา

---

๑ ม. ปญฺจงฺคุตฺตเร เทสิสฺสามิ ตนฺติ อยเมตฺถ ปาโฐ ทิสฺสติ ฯ

(៩៩) ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យតិរ្ថិយសួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់គឺបញ្ចក្ខន្ធ មានអ្វីជាមូល ធម៌ទាំងអស់កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្ចឹម ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ សួរយ៉ាងនេះ តើអ្នកទាំងឡាយ គប្បីដោះស្រាយដូចម្តេចដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយនោះ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយមានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង របស់យើងខ្ញុំព្រះអង្គស្រាប់ហើយ បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគ សំដែងនូវសេចក្តីនៃភាសិតនេះឲ្យបាន ពួកភិក្ខុបានស្តាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ បានទទួលតបថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យតិរ្ថិយ សួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានអ្វីជាមូល ធម៌ទាំងអស់កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន

សព្ពេ ធម្មា កឹអាធិបតេយ្យា សព្ពេ ធម្មា កឹខុត្តរា សព្ពេ ធម្មា កឹសារា សព្ពេ ធម្មាតិ វា បុដ្ឋា តុម្ហេ កិត្តាវតា តេសំ អញ្ញតិត្ថិយានំ បរិញ្ញេយ្យានំ វា ព្យាករណេយ្យេ ធម្មេ លភថាតិ អាវុសោ សព្ពេ ធម្មា មនសិការសម្ភវា សព្ពេ ធម្មា ផស្សសមុទយា សព្ពេ ធម្មា វេទនាសមោសរណា សព្ពេ ធម្មា សមាធិប្បមុខា សព្ពេ ធម្មា សតាធិបតេយ្យា សព្ពេ ធម្មា បញ្ញុត្តរា សព្ពេ ធម្មា វិមុត្តិសារា សព្ពេ ធម្មាតិ វា បុដ្ឋា តុម្ហេ កិត្តាវតា តេសំ អញ្ញតិត្ថិយានំ បរិញ្ញេយ្យានំ វា ព្យាករណេយ្យេ ធម្មេ លភថាតិ ។

(១០០) អដ្ឋហិ កិត្តាវតា អង្គេហិ សមន្នាគតោ មហាចោរោ ទិប្បំ បរិយាបជ្ជតិ ន ចិរដ្ឋិតិកោ ហោតិ ។ កតមេហិ អដ្ឋហិ ។ អប្បហារន្តស្ស បហារំ អនវសេសំ អាទិយតិ ឥត្តិ ហរតិ(១) កុមារិំ ទូសេតិ បព្ភជិតំ វិលុម្បតិ ភជ្ជកោសំ វិលុម្បតិ អច្ចាសន្នេ កម្មំ ករោតិ ន ច នំ ជានកុសលោ ហោតិ ។

ខ.ម. ហរតិ ។

ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្ញុំ ម្នាលភិក្ខុទាំងឡាយ កាលបើ ពួកបរិព្វាជកអន្យតិត្ថិយសួរយ៉ាងនេះ អ្នកទាំងឡាយគប្បីដោះស្រាយដល់បរិព្វាជកអន្យតិត្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានឆន្ទៈជាមូលធម៌ ទាំងអស់កើតអំពីមនសិការៈ ធម៌ទាំងអស់ប្រជុំកើតអំពីផស្សៈ ធម៌ទាំងអស់ប្រជុំចុះក្នុងវេទនា ធម៌ទាំងអស់មានសមាធិជាប្រធាន ធម៌ទាំងអស់មានសតិជាអធិបតី ធម៌ទាំងអស់មានបញ្ញាជាវិសេស ធម៌ទាំងអស់មានវិមុត្តិជាខ្ញុំ ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកអន្យតិត្ថិយ សួរយ៉ាងនេះហើយ អ្នកទាំងឡាយ គប្បីដោះស្រាយដល់បរិព្វាជកអន្យតិត្ថិយទាំងនោះ យ៉ាងនេះឯង ។

(១០០) ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ប្រការ រមែងវិនាសឆាប់ មិនតាំងនៅយូរឡើយ ។ ប្រកបដោយអង្គ៨ប្រការតើដូចម្តេច ។ គឺប្រហារទូវបុគ្គលដែលមិនប្រហារតប(១) ១ កាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ នាំយកស្ត្រី ១ ប្រទូស្តនឹងក្មេងស្ត្រី ១ ឆក់បំពូជិត ១ ឆក់ព្រះពជឃ្លាំង ១ ធ្វើចោរកម្មក្នុងទីជិត (ស្រុកឬនិគមរាជធានីជាដើម) ១ ជាអ្នកមិនឈ្លាសវៃ ក្នុងការកប់ទ្រព្យទុក (ក្នុងទុក្ខិណេយ្យបុគ្គល) ១ ។

១– បុគ្គលដែលមិនបងៀនខ្លួន សម្បុណ្ណដោយគុណធម៌ មនុស្សចាស់ ក្មេងតូច ។ អដ្ឋកថា ។

สเมหิ เขา กิกฺขเว อฏฺฐหงฺเคหิ สมนฺนาคตา มหาโจเรา ขิปฺปำ ปริยาปชฺชติ น จิรฏฺฐิติกา โหติ ฯ

(๑๐๑) อฏฺฐหิ กิกฺขเว องฺเคหิ สมนฺนาคตา มหาโจเรา น ขิปฺปำ ปริยาปชฺชติ จิรฏฺฐิติกา โหติ ฯ กตเมหิ อฏฺฐหิ ฯ น อปฺปหารตฺตสฺส ปหาตำ น อนาวาสำ อาธิยติ น สิตฺถำ หาตำ น กุมารึ ทูเสตำ น ปฏิสนฺถตำ วิลุมฺปติ น ภณฺฑิกำ วิลุมฺปติ น อคารกำ วิลุมฺปติ น อชฺฌาสนฺเน กมฺมำ กเรติ นิฆานกุสลา โหติ ฯ สเมหิ เขา กิกฺขเว อฏฺฐหงฺเคหิ สมนฺนาคตา มหาโจเรา น ขิปฺปำ ปริยาปชฺชติ จิรฏฺฐิติกา โหตีติ ฯ

(๑๐๒) สมณาติ กิกฺขเว ตถาคตสฺเสตำ อธิวจนำ อรหาติ สมฺมาสมฺพุทฺธสฺส ปฺรหฺมณาติ กิกฺขเว ตถาคตสฺเสตำ อธิวจนำ อรหาติ สมฺมาสมฺพุทฺธสฺส เวทคูติ กิกฺขเว ตถาคตสฺเสตำ อธิวจนำ อรหาติ สมฺมาสมฺพุทฺธสฺส กิลาสฺกาติ กิกฺขเว ตถาคตสฺเสตำ อธิวจนำ อรหาติ สมฺมาสมฺพุทฺธสฺส

ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ ប្រការនេះឯង រមែងវិនាសធាប់ មិនតាំងនៅយូរឡើយ ។

(១០១) ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ ៨ ប្រការ រមែងមិនវិនាសធាប់ ជាអ្នកតាំងនៅយូរបាន ។ ប្រកបដោយអង្គ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺមិនប្រហារនូវបុគ្គល ដែលមិនប្រហារតប ១ មិនកាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ មិននាំយកស្ត្រី ១ មិនប្រទូស្តក្មេងស្ត្រី ១ មិនបង់បព្វជិត ១ មិនបង់ព្រះពជ្ឈាំង ១ មិនធ្វើចោរកម្មក្នុងទីជិត ១ ជាអ្នកឈ្វាសវៃ ក្នុងការកប់ទ្រព្យទុក (ក្នុងទក្ខិណេយ្យបុគ្គល) ១ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ៨ប្រការនេះឯង រមែងមិនវិនាសធាប់ ជាអ្នកតាំងនៅយូរបាន ។

(១០២) ម្នាលភិក្ខុទាំងឡាយ ពាក្យថា សមណៈ (អ្នកសូបវម្ងាប់) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ (អ្នកបន្ទាត់បង់នូវបាប) នេះ ជាឈ្មោះរបស់តថាគត ជ.អរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វេទគូ (អ្នកចេះចប់ត្រៃវេទ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា កិសក្កៈ (គ្រូពេទ្យរៃកាត់) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ

ធម្មោតិ កត្វា តថាគតស្សតំ អធិវចនំ អរហាតោ សម្មាសម្ពុទ្ធស្ស វិមោតិ កត្វា តថាគតស្សតំ អធិវចនំ អរហាតោ សម្មាសម្ពុទ្ធស្ស ញាណន្តិ កត្វា តថាគតស្សតំ អធិវចនំ អរហាតោ សម្មាសម្ពុទ្ធស្ស វិមុត្តោតិ កត្វា តថាគតស្សតំ អធិវចនំ អរហាតោ សម្មាសម្ពុទ្ធស្សាតិ ។

យំ សមណេន បត្តព្ពំ ព្រាហ្មណេន វុសីមតា
យំ វេទគុនា បត្តព្ពំ កិំសក្កេន អនុត្តរំ
យំ ធម្មោនេ បត្តព្ពំ វិមលេន វុសីមតា
យំ ញាណិនា ច បត្តព្ពំ វិមុត្តេន អនុត្តរំ
សោហំ វិជិតសង្គ្រាមោ មុត្តោ មោចេមិ ពន្ធនា
ឯតោម្ហិ បរមទន្តោ អសេក្ខោ បរិនិព្ពុតោតិ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថា និម្មលៈ (អ្នកគ្មានមន្ទិល) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមលៈ (អ្នកប្រាសចាកមន្ទិល) នេះជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ញាណី (អ្នកមានញាណ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមុត្ត (អ្នកផុតស្រឡះ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

គុណជាតណា ដែលតថាគតជាសមណៈ ជាព្រាហ្មណ៍ មានព្រហ្មចរិយៈនៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា ដែលតថាគត អ្នកចេះចប់ត្រៃវេទ ជាគ្រូពេទ្យរំកាត់ គប្បីសម្រេចក្តី គុណជាតនោះប្រសើរបំផុត គុណជាតណា ដែលតថាគត គ្មានមន្ទិល ប្រាសចាកមន្ទិល មានព្រហ្មចរិយៈនៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា ដែលតថាគត មានញាណ អ្នករួចស្រឡះ គប្បីសម្រេចក្តី គុណជាតនោះ ប្រសើរបំផុត តថាគតនោះ ជាអ្នកឈ្នះសង្គ្រាម រួចចាកចំណង់ ទាំងស្រុងមហាជន ឲ្យរួចចាកចំណង់ ជាបុគ្គលប្រសើរ មានខ្លួនទូន្មានហើយដោយប្រពៃ ជាអរសេក្ខបុគ្គល បរិនិព្វានហើយ ។

(๑๐๓) ฯเตน สมเยน ภควา โกสมฺพีสุ วิหรติ ฆาสิตาราเม ฯ อถ โข อุทโย ปริพฺพาชโก ยาวตติยกา ปฏิสลฺลานา วุฏฺฐิโต เยน ภควา เตนุปสงฺกมิ ฯ อุปสงฺกมิตฺวา ภควตา สทฺธึ สมฺโมทิ ฯ สมฺโมทนียึ กถึ สาราณียึ วีติสาเรตฺวา เอกมนฺตึ นิสีทิ ฯ เอกมนฺตนิสินฺโน โข อุทโย ปริพฺพาชโก ภควนฺตเมตทโวจ ฯ สาธุ ภนฺเต ภควา ยาวตติยกา ปฏิสลฺลานา วุฏฺฐิโต เยน มม ปาโมกฺโข เตนุปสงฺกมตุ ฯ ตสฺส ปาโมกฺโข ภควา ยาวตติยกา ปฏิสลฺลานา วุฏฺฐิโต เยน ปาโมกฺโข เตนุปสงฺกมิสฺสตีติ ฯ ตุณฺหี ภควา อธิวาเสสิ ฯ อถ โข ภควา ยาวตติยกา ปฏิสลฺลานา วุฏฺฐิโต เยน ปาโมกฺโข เตนุปสงฺกมิ ฯ อุปสงฺกมิตฺวา ปญฺญตฺเต อาสเน นิสีทิ ฯ นิสชฺช โข ภควา อุทยึ ปริพฺพาชกมาเมตทโวจ ฯ ยาวตติยกา ปน ตฺวา อุทย ปฏิสลฺลานา วุฏฺฐิโต เยน ปาโมกฺโข เตนุปสงฺกมิ ฯ ปาโมกฺโข ตยา ยาวตติยกา ปฏิสลฺลานา วุฏฺฐิโต เยน ปาโมกฺโข เตนุปสงฺกมิสฺสตีติ ฯ

(១០៣) សម័យមួយ ព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃ ច្រើនរូប ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងក្រុងកោសម្ពី ឋានស្តេចទៅ ដល់ព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គល:របស់ពួកអ្នកដែនកោសល ។ ឋាន ឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឥច្ឆានង្គល: ជិតស្រុក ឥច្ឆានង្គល:នោះ ។ ពួកព្រាហ្មណ៍ទំាងគហបតី អ្នកស្រុកឥច្ឆានង្គល: ឋានឮដំណឹង (ប្រកាសប្រាប់គ្នា) ថា ម្នាលគ្នាយើង ឮថា ព្រះសមណ-គោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវឋាន ស្តេចមកដល់ស្រុកឥច្ឆានង្គល:ហើយ ទ្រង់គង់ក្នុងដងព្រៃឥច្ឆានង្គល:ជិត ស្រុកឥច្ឆានង្គល: ។ កិត្តិសព្ទដ៏ពីរោះយ៉ាងនេះ របស់ព្រះគោតមដ៏ចំរើន អង្គនោះ លា្បឫ សុះសាយទៅថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្ត សម្មាសម្ពុទ្ធ ។ បេ ។ ក៏ការដែលឋានជួបប្រទះនឹងព្រះអរហន្តទាំង ឡាយមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។ គ្រានោះ ពួក ព្រាហ្មណ៍ទំាងគហបតី អ្នកស្រុកឥច្ឆានង្គល: កាលកន្លងរាត្រីនោះទៅ ហើយ ក៏នំាយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រែល នំាគ្នាដើរចូល សំដៅទៅកាដងព្រៃឥច្ឆានង្គល: លុះចូលទៅដល់ហើយ ក៏ឈរស្រែក ហ៊ោនិយាយខ្លាំង ឱឡែបក្លោងទ្វារខាងក្រៅ ។

តេន ខោ បន សមយេន អាយស្មា ឆាតោ
ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថ ខោ ភគវា អាយស្មន្តំ
ឆាតំ អាមន្តេសិ កេ បន តេ ឆាត ឧច្ចាសង្កា
មហាសង្កា តេវាជ្ជា មញ្ញេ មច្ចុំ វិលោបេន្តីតិ ។ ឯតេ
ភន្តេ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា បហូតំ
ខាទនីយំ ភោជនីយំ អាទាយ ពហិទ្ធារកាដ្ឋកេ ឋិតា
ភគវន្តញ្ញេវ ឧទ្ទិស្ស តិក្ខុសង្ឃញ្ញេតិ ។ មាហំ ឆាតំ
យសេន សមាគមំ មា ច មយា យសោ យោ ខោ
ឆាតំ ន យិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស
ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី
អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ
នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស
សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី
អកសិរលាភី សោ តំ មច្ឆសុខំ មច្ចុសុខំ
លាភសក្ការសិលោកសុខំ សាទិយេយ្យាតិ ។

សម័យនោះឯង ព្រះនាគិតៈដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មាន
ព្រះភាគ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈ
ដ៏មានអាយុថា ម្នាលនាគិតៈ ចុះពួកណាស្រែកហ៊ោ និយាយឮខ្ទរ៉ាំងម៉ែះ
ហាក់ដូចជាព្រានសំណាញ់ ដណ្តើមត្រីគ្នា ។ ព្រះនាគិតៈដ៏មានអាយុ
ក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស អ្នកតាំងនុះ ជាព្រាហ្មណ៍
នឹងគហបតី នៅក្នុងស្រុកឥច្ឆានង្គលៈ នាំយកភាគនីយកោដនីយាហារ
ដ៏ក្រាស់ក្រែល ចូលិសចំពោះព្រះដ៏មានព្រះភាគផង ព្រះភិក្ខុសង្ឃផង
ហើយឈរទៀបក្លោងទ្វារខាងក្រៅ ។ ម្នាលនាគិតៈ តថាគតសូមកុំឲ្យ
ជួបប្រសព្វនឹងយសបរិវារ តាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹង
តថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបាន
ដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសម-
សុខ សម្ពោធសុខ នេះដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ
សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បាន
ដោយស្រួលទេ បុគ្គលនោះឯង គប្បីត្រេកអរចំពោះសេចក្តីសុខ មិនស្អាត
សុខកង្វល់តិចតួចសោះ សុខកើតអំពីលាភសក្ការៈនឹងពាក្យសរសើរ ។

អធិវាសេតុជានំ ភន្តេ ភគវា អធិវាសេតុ សុគតោ
អធិវាសនការោជានំ ភន្តេ ភគវាតោ យេន យេនបិ-
ជានំ ភន្តេ ភគវា តមិស្សតិ តន្និជា ច ការិស្សន្តិ ព្រាហ្ម-
ណគហបតិការា នេគមា ចេវ ជានបទា ច ។ សេយ្យថាបិ
ភន្តេ ជុល្លុជុសិតកេ នេវ វស្សន្តេ យថានិន្នំ ឧទកានំ
សំវត្តន្តិ ឯវមេវ ខោ ភន្តេ យេន យេនបិជានំ ភគវា
តមិស្សតិ តន្និជា ច ការិស្សន្តិ ព្រាហ្មណគហបតិការា
នេគមា ចេវ ជានបទា ច ។ តំ កិស្ស ហេតុ ។
តថា ហិ ភន្តេ ភគវាតោ សីលប្បញ្ញាណន្តិ ។
មាហំ ជាតិត យសេន សមាគមំ មា ច មយា
យសោ យោ ខោ ជាតិត ន យិមស្ស នេក្ខម្មសុខស្ស
បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស
និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី

ព្រះនាគិតៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគទទួលនិមន្ត សូមព្រះសុគតទទួលនិមន្ត បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ កាលនេះជាកាលគួរព្រះដ៏មានព្រះភាគទទួលនិមន្តហើយ បពិត្រព្រះអង្គដ៏ចំរើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅកាន់ទីណា ។ កាន់កាលឥឡូវនេះ កំគង់ពួកព្រាហ្មណ៍ធំធំគហបតី ជាអ្នកនិគមក្តី អ្នកជនបទក្តី នឹងតាមទៅកាន់ទីនោះៗមិនខាន ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើក្លៀងមានដំណក់ទឹកថ្លោសៗបង្អុរចុះមក ទឹកតាំងឡាយ តែងហូរធ្លាក់ទៅកាន់ទីទាប ដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចំរើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅកាន់ទីណា ។ កាន់កាលឥឡូវនេះ កំគង់ពួកព្រាហ្មណ៍ធំធំគហបតី ជាអ្នកនិគមក្តី អ្នកជនបទក្តី នឹងតាមទៅកាន់ទីនោះៗមិនខាន ដូច្នោះឯង ។ ដំណើរនោះព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន ព្រោះព្រះដ៏មានព្រះភាគព្រះអង្គមានសីលធំធ្ងាជ្ងា ។ ម្នាលនាគិតៈ តថាគត សូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ចាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ

យសប្បហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសម-
សុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ច-
លាភី អកសិរលាភី សោ តំ មិទ្ធសុខំ មិទ្ធសុខំ លាភ-
សក្ការសិលោកសុខំ សាទិយេយ្យ ។ នេវតាបំ ខោ
ជាតិត ឯកច្ចា ន យិមស្ស នេក្ខម្មសុខស្ស បវិវេក-
សុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលា-
កិនិយោ អស្សុ អកិច្ចលាកិនិយោ អកសិរលាកិនិយោ
យសប្បហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសម-
សុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិ-
ច្ចលាភី អកសិរលាភី តុម្ហាកម្បិ ខោ ជាតិត សំកម្ម
សមាកម្ម សង្គំណិកវិហារំ អនុយុត្តានំ វិហរតំ ឯវំ ហោតិ
ន ហិទ្ធនបេ អាយស្មន្តោ ឥមស្ស នេក្ខម្មសុខស្ស បវិ-
វេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាម-
លាកិនោ អស្សុ អកិច្ចលាកិនោ អកសិរលាកិនោ

ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលទេ បុគ្គលនោះ គប្បីត្រេកអរចំពោះសេចក្តីសុខមិនស្អាត សុខក្នុងការដេកលក់ សុខដែលកើតអំពីលាភសក្ការៈ និងពាក្យសរសើរ ។ ម្នាលនាគិតៈ សូម្បីទេវតាពួកខ្លះ ក៏មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលដែរ ម្នាលនាគិតៈ អ្នកចាំឆ្យាយ កាលមកប្រជុំសមាគមគ្នា ខ្វល់ខ្វាយខាងការនៅច្រឡូកច្រឡំដោយពួកហើយ រមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកចាំឆ្យាយនេះ មុខជាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ

ยสฺสาหํ เนกฺขมฺมสุขสฺส ปวิเวกสุขสฺส อุปสม-
สุขสฺส สมฺโพธสุขสฺส นิกามลาภี อสฺสํ อกิ-
ญฺจนลาภี อกสิรลาภี ตถา หิ ปนเม อายสฺมโต
สีลกฺขนฺธา สมาธิกฺขนฺธา สพฺเพ กิเลสา ปหีนา ฯ
เอวาหํ ชาติยา ชิยฺยา ปสฺสามิ อญฺเญมญฺเ อนฺตลิปฺปโ-
ธเกน(๑) สญฺจิจฺจนฺเต สีเตนฺเต ตสฺส ปญฺญา
ชาติยา ฆาตาย ฯ เหเตติ น หายนฺตเม อายสฺมโต
เอวมสฺส เนกฺขมฺมสุขสฺส ปวิเวกสุขสฺส อุปสม-
สุขสฺส สมฺโพธสุขสฺส นิกามลาภิโน อสฺส
อกิญฺจนลาภิโน อกสิรลาภิโน ยสฺสาหํ
เนกฺขมฺมสุขสฺส ปวิเวกสุขสฺส อุปสมสุขสฺส
สมฺโพธสุขสฺส นิกามลาภี อสฺสํ อกิญฺจนลาภี
อกสิรลาภี ตถา หิ ปนเม อายสฺมโต
อญฺเญมญฺเ อนฺตลิปฺปโธเกน สญฺจิจฺจนฺเต สีเตนฺเต ฯ

๑ ฉ. ม. อนฺตลิปโธเวหิ ฯ

ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគត
បានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា
លោកដ៏មានអាយុទាំងនេះ មកប្រជុំសមាគមគ្នា ប្រកបរឿយៗខាងការនៅ
ច្រឡូកច្រឡំដោយពួក ។ ម្នាលនាគិតៈ ក្នុងទីឯណោះ តថាគតឃើញ
ពួកតិត្ថិ កំពុងសើចក្អាកក្អាយ សើចប្រឡែងគ្នា ដោយការចាក់ដោយ
ដន្ទញ្ជាគម្រាមដៃទៅវិញទៅមក ម្នាលនាគិតៈ តថាគតមានសេចក្តីត្រិះរិះ
យ៉ាងនេះថា លោកដ៏មានអាយុទាំងនេះ មុខជាមិនបានដូចប្រាថ្នា មិនបាន
ដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសម-
សុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ
សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយ
ស្រួល ដោយពិត ព្រោះថា លោកដ៏មានអាយុទាំងនេះ សើចក្អាកក្អាយ
សើចប្រឡែងគ្នា ដោយការចាក់ដោយដន្ទញ្ជាគម្រាមដៃ ទៅវិញទៅមក ។

ឥធ បនាហំ ឆាតិត កិត្តិំ បស្សាមិ យាវទត្ថំ ឧទរាវ-
ទេហកំ កុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ
អនុយុត្តេ វិហរន្តេ តស្ស មយ្ហំ ឆាតិត ឃវំ ហោតិ ឧ
ហាទ្ធនមេ អាយស្មន្តោ ឥមស្ស នេក្ខម្មសុខស្ស បវិវេក-
សុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាម-
លាភិនោ អស្ស អកិច្ឆលាភិនោ អកសិរលាភិនោ
យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសម-
សុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆ-
លាភី អកសិរលាភី តថា ហិ បនមេ អាយស្មន្តោ
យាវទត្ថំ ឧទរាវទេហកំ កុញ្ជិត្វា សេយ្យសុខំ បស្សសុខំ
មិទ្ធសុខំ អនុយុត្តា វិហរន្តិ ។ ឥធាហំ ឆាតិត កិត្តិំ
បស្សាមិ តាមន្តវិហារេ(១) សមាហិតំ និសិន្នំ តស្ស
មយ្ហំ ឆាតិត ឃវំ ហោតិ ឥធាធិ ឥមំ អាយស្មន្តំ
អារាមិកោ ឯ ឧបដ្ឋហិស្សតិ(២) សមណុទ្ទេសោ ឯ តំ
តម្ហា សមាធិម្ហា ឯមិស្សតីតិ(៣) តេនាហំ ឆាតិត តស្ស
កិត្តិនោ ឧ អត្តមនោ ហោមិ តាមន្តវិហារេន ។

---

๑. ម. តាមន្តវិហារេ ។ ๒ ឧ. សហេស្សតិ ។ ๓ ឧ. ម. ឯវិស្សតីតិ ។

ម្នាលនាគិតៈ មួយទៀត ភិក្ខុនីឯណោះ តថាគតឃើញពួកភិក្ខុ បរិភោគ
ដកបាលផ្អែតពេញពោះ ហើយខ្ជល់ខ្ជាយខាងសេចក្តីសុខនឹងដំណេក
សុខនឹងបង្អែក សុខនឹងការដេកលក់ ម្នាលនាគិតៈ តថាគតនោះ មាន
សេចក្តីត្រិះរិះយ៉ាងនេះថា លោកទាំងឡាយនេះ មុខជាមិនបានដូច
ប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិ-
វេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ
ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ
បានដោយស្រួល ដោយពិត ព្រោះថា លោកទាំងឡាយនេះ បរិភោគ
ដកបាលផ្អែតពេញពោះ ខ្ជល់ខ្ជាយខាងសេចក្តីសុខនឹងដំណេក សុខ
នឹងបង្អែក សុខនឹងការដេកលក់ ។ ម្នាលនាគិតៈ ភិក្ខុនីឯណោះ
តថាគតឃើញភិក្ខុមានចិត្តជំពប់នៅនឹង អង្គុយក្នុងវិហារដិតស្រុក តថាគត
នោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អាពាមិកជន ឬក៏សម-
ណព្រាហ្មណ៍ នឹងមកបម្រើលោកនេះ ឯការបម្រើនោះ នឹងញុំាងលោក
នេះ ឲ្យឃ្លាតចាកសមាធិនោះពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ
តថាគត មិនត្រេកអរនឹងភិក្ខុនោះ ដោយការនៅ ក្នុងទីដិតស្រុក ។

៨ បនាហំ ភាគិនេ កិញ្ចិ បស្សាមិ(๑) អញ្ញេ ច បលា-
យមានំ និសិន្នំ តស្ស មយ្ហំ ភាគិនេ ឯវំ ហោតិ ឥធាធិ
អយមាយស្មា ឥមំ និន្នាកិលមថំ បដិវិនោទេត្វា អញ្ញ-
ញាយេវ មនសិការំ សដ្ឋតិ ឯត្តកន្តិ(๒) តេនាហំ ភាគិនេ
តស្ស កិញ្ចនោ អត្តមនោ ហោមិ អញ្ញាវិហារេន ។ ៨
បនាហំ ភាគិនេ កិញ្ចិ បស្សាមិ អញ្ញេ អសមាហិតំ
និសិន្នំ តស្ស មយ្ហំ ភាគិនេ ឯវំ ហោតិ ឥធាធិ អយមា-
យស្មា អសមាហិតំ ឯ ចិត្តំ សមាធេហិស្សតិ សមាហិតំ
ឯ ចិត្តំ អនុរក្ខិស្សតីតិ តេនាហំ ភាគិនេ តស្ស កិញ្ចនោ
អត្តមនោ ហោមិ អញ្ញាវិហារេន ។ ៨ បនាហំ ភាគិនេ
កិញ្ចិ បស្សាមិ អញ្ញេកំ សមាហិតំ និសិន្នំ តស្ស មយ្ហំ
ភាគិនេ ឯវំ ហោតិ ឥធាធិ អយមាយស្មា អវិមុត្តំ ឯ ចិត្តំ
វិមុញ្ចិស្សតិ វិមុត្តំ ឯ ចិត្តំ អនុរក្ខិស្សតីតិ តេនាហំ ភាគិនេ
តស្ស កិញ្ចនោ អត្តមនោ ហោមិ អញ្ញាវិហារេន ។

---

๑ ឧ.ម. ឯត្តន្តរេ អញ្ញាកន្តិ អាទិ ជាហេ វិស្សជ្ជតិ ។ ๒. ឯកត្តន្តិ ។

ម្នាលនាគិត: មួយទៀត ភិក្ខុនីឯណោះ តថាគតឃើញកិក្ខុ វត់ចេញទៅ
អង្គុយនៅកន្លែងព្រៃ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះ
ថា ឥន្ទ្រិយនេះ លោកនេះ មុខជានឹងកំចាត់បង់នូវសេចក្តីងោកងក់ នឹង
សេចក្តីលំបាកនេះ ហើយនឹងធ្វើកុកកងចិត្តនូវអរញ្ញសញ្ញា ជាធម្មជាតមាន
ចិត្តមួលតែមួយពុំខាន ម្នាលនាគិត: ព្រោះហេតុនោះ តថាគតត្រេកអរ
នឹងកិក្ខុនោះ ដោយការនៅកន្លែងព្រៃ ។ ម្នាលនាគិត: មួយទៀត ភិក្ខុនី
ឯណោះ តថាគតឃើញកិក្ខុ មានចិត្តមិនខាន់ដម្កល់នៅនឹងទេ អង្គុយនៅ
កន្លែងព្រៃ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥន្ទ្រិ
នេះ លោកនេះ នឹងដម្កល់ចិត្តដែលមិនខាន់ដម្កល់ ឬនឹងរក្សាចិត្តដែលខ្លួន
បានដម្កល់ហើយពុំខាន ម្នាលនាគិត: ព្រោះហេតុនោះ តថាគត
មានចិត្តត្រេកអរនឹងកិក្ខុនោះ ដោយការនៅកន្លែងព្រៃ ។ ម្នាលនាគិត: មួយ
វិញទៀត ភិក្ខុនីឯណោះ តថាគតឃើញកិក្ខុមួយរូប អ្នកនៅកន្លែងព្រៃ មាន
ចិត្តដម្កល់នៅនឹង កំពុងអង្គុយ ម្នាលនាគិត: តថាគតនោះ មានសេចក្តី
ត្រិះរិះយ៉ាងនេះថា ឥន្ទ្រិយនេះ លោកនេះ នឹងធ្វើចិត្តដែលមិនខាន់រួចឲ្យរួច
ស្រឡះ ឬនឹងរក្សាចិត្តដែលរួចស្រឡះហើយពុំខាន ម្នាលនាគិត: ព្រោះ
ហេតុនោះ តថាគតមានចិត្តត្រេកអរនឹងកិក្ខុនោះ ដោយការនៅកន្លែងព្រៃ ។

យស្មាហំ ឆាតិត សមយេ អទ្ធានមគ្គប្បដិបន្នោ ឆ កតិញ្ចិ បស្សាមិ បុរតោ ឯ បច្ឆតោ ឯ ជាសុ មេ ឆាតិត តស្មឹ សមយេ ហោតិ អន្តមសោ ឧច្ចារប្បស្សាវ-កម្មស្សាតិ(๑) ។

[๑๐๔] អដ្ឋហិ កិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ និក្កុជ្ជេយ្យ។ កតមេហិ អដ្ឋហិ ។ កិក្ខនំ អលាភាយ បរិសក្កតិ កិក្ខនំ អនត្ថាយ បរិសក្កតិ កិក្ខនំ អនាឝាសាយ បរិសក្កតិ កិក្ខ(๒) អក្កោសតិ បរិភាសតិ កិក្ខ កិក្ខហិ វិភេទេតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ ឥមេហិ ខោ កិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ និក្កុជ្ជេយ្យ ។

---

๑ ម. ឧច្ចារប្បស្សាវកម្មាយាតិ។ ๒ ម. កិក្ខនំ ។

ម្នាលនាគិតៈ សម័យណា ដែលតថាគតដើរទៅកាន់ផ្លូវឆ្ងាយ មិនបានដួបប្រទះអ្វីតិចតួច ក្នុងខាងមុខក្តី ខាងក្រោយក្តី ម្នាលនាគិតៈ សម័យនោះ តថាគតមានតែសេចក្តីសប្បាយ ដោយហោចទៅ សូម្បីការធ្វើទុក្ខារៈឬបសប្បារៈកំស្រួល ។

[๑๐๔] ម្នាលភិក្ខុទាំងឡាយ ឧបាសក ប្រកបដោយអង្គ ๘ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។ អង្គ ๘ ប្រការ តើដូចម្តេចខ្លះ ។ គឺឧបាសកព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ๑ ព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ๑ ព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ ๑ ដេរប្រទេចភិក្ខុទាំងឡាយ ๑ បំបែកភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ๑ តិះដៀលព្រះពុទ្ធ ๑ តិះដៀលព្រះធម៌ ๑ តិះដៀលព្រះសង្ឃ ๑ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ๘ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។

(១០៥) អដ្ឋហិ កិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ ឧក្កុជ្ជេយ្យ។ កតមេហិ អដ្ឋហិ ។ ន កិក្ខុនំ អលាភាយ បរិសក្កតិ ន កិក្ខុនំ អនត្ថាយ បរិសក្កតិ ន កិក្ខុនំ អនាវាសាយ បរិសក្កតិ ន កិក្ខូ អក្កោសតិ បរិភាសតិ ន កិក្ខូ កិក្ខូហិ វិភេទេតិ ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ។ ឥមេហិ ខោ កិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ ឧក្កុជ្ជេយ្យាតិ ។

(១០៦) អដ្ឋហិ កិក្ខវេ ធម្មេហិ សមន្នាគតស្ស កិក្ខុនោ អាកង្ខមានា ឧបាសិកា អប្បសាទំ បវេ-ទេយ្យុំ ។ កតមេហិ អដ្ឋហិ ។ កិហីនំ អលាភាយ បរិសក្កតិ កិហីនំ អនត្ថាយ បរិសក្កតិ កិហី(១) អក្កោសតិ បរិភាសតិ កិហី កិហីហិ វិភេទេតិ

---

១ ម. កិហិំ ។ ម. កិហិ ។

(๑๐๕) ម្នាលភិក្ខុទាំងឡាយ ទុបាសកប្រកបដោយអង្គ ๘ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្សាយបាត្របាន ។ ដោយអង្គ ๘ ប្រការ តើដូចម្តេចខ្លះ ។ គឺទុបាសក មិនពាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ๑ មិនពាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ๑ មិនពាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានសុំនៅ ๑ មិនដេរប្រទេចភិក្ខុទាំងឡាយ ๑ មិនបំបែកភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ๑ ពោលសរសើរព្រះពុទ្ធ ๑ ពោលសរសើរព្រះធម៌ ๑ ពោលសរសើរព្រះសង្ឃ ๑ ។ ម្នាលភិក្ខុទាំងឡាយ ទុបាសកប្រកបដោយអង្គ ๘ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្សាយបាត្របាន ។

(๑๐๖) ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការ ពួកទុបាសកកាលប្រាថ្នា គប្បីសំដែងសេចក្តីមិនជ្រះថ្លាបាន ។ ប្រកបដោយធម៌ ๘ ប្រការ តើដូចម្តេចខ្លះ ។ គឺ ភិក្ខុពាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ๑ ពាយាមដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ๑ ដេរប្រទេចពួកគ្រហស្ថ ๑ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ๑

ពុទ្ធស្ស អាវណ្ណំ ភាសតិ ធម្មស្ស អាវណ្ណំ ភាសតិ សង្ឃស្ស អាវណ្ណំ ភាសតិ តតោ ច នេកាធំ(๑) បសវន្តិ ។ ឥមេហិ ខោ កិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស កិក្ខុនោ អាកង្ខមានា ឧបាសកា អប្បសាទំ បវេទេយ្យុំ ។

(๑๐๗) អដ្ឋហិ កិក្ខវេ ធម្មេហិ សមន្នាគតស្ស កិក្ខុនោ អាកង្ខមានា ឧបាសកា បសាទំ បវេទេយ្យុំ ។ កតមេហិ អដ្ឋហិ ។ ន កិហីធំ អលាភាយ បរិសក្កតិ ន កិហីធំ អនត្ថាយ បរិសក្កតិ ន កិហី អក្កោសតិ បរិភាសតិ ន កិហី កិហីហិ វិវេចេតិ ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ តតោ ច នេកា នំ បសវន្តិ ។ ឥមេហិ ខោ កិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស កិក្ខុនោ អាកង្ខមានា ឧបាសកា បសាទំ បវេទេយ្យុន្តិ ។

---

๑ ឧ. ម. អនោបរេ ច នំ ។ អដ្ឋកថាយំ អនោបរេតិបិ ទិស្សតិ ។

តិះដៀលព្រះពុទ្ធ ๑ តិះដៀលព្រះធម៌ ๑ តិះដៀលព្រះសង្ឃ ๑ ទាំងពួកទេវតា ក៏ឃើញនូវភិក្ខុនោះដោយហេតុនោះ ๑ ฯ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការនេះឯង ពួកឧបាសក កាលប្រាថ្នា គប្បីសំដែងសេចក្តីមិនជ្រះថ្លាបាន ฯ

[๑๐๗] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការ ពួកឧបាសក កាលប្រាថ្នា គប្បីសំដែងសេចក្តីជ្រះថ្លាបាន ฯ ប្រកបដោយធម៌ ๘ ប្រការ តើដូចម្តេចខ្លះ ฯ គឺភិក្ខុមិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ๑ មិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ๑ មិនដេរប្រទេចពួកគ្រហស្ថ ๑ មិនបំបែកពួកគ្រហស្ថ ๑ ឲ្យបែកចាកពួកគ្រហស្ថ ๑ ពោលសរសើរព្រះពុទ្ធ ๑ ពោលសរសើរព្រះធម៌ ๑ ពោលសរសើរព្រះសង្ឃ ๑ ពួកទេវតាឃើញភិក្ខុនោះ ដោយហេតុនោះ ๑ ฯ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការនេះឯង ពួកឧបាសក កាលប្រាថ្នា គប្បីសំដែងនូវសេចក្តីជ្រះថ្លាបាន ฯ

(๑๐๘) อฏฺฐหิ ภิกฺขเว ธมฺเมหิ สมนฺนาคตสฺส ภิกฺขุโน อาคจฺฉมาโน สงฺฆา ปฏิสารณียกมฺมํ กาเรยฺย ฯ กตเมหิ อฏฺฐหิ ฯ ภิยฺโยปิ อลาภาย ปริสกฺกติ ภิยฺโยปิ อนตฺถาย ปริสกฺกติ ภิยฺโยปิ อโผฏฺฐพฺพาย ปริสกฺกติ ภิยฺโยปิ ภิยฺโยปิ วิเหฐนาย ปุถุสฺส อาวฺหาย กาสติ ธมฺมสฺส อาวฺหาย กาสติ สงฺฆสฺส อาวฺหาย กาสติ ธมฺมิกญฺจ ภิยฺโยปฺปฏิสฺสวํ น สณฺฐาเปติ ฯ อิเมหิ โข ภิกฺขเว อฏฺฐหิ ธมฺเมหิ สมนฺนาคตสฺส ภิกฺขุโน อาคจฺฉมาโน สงฺฆา ปฏิสารณียกมฺมํ กาเรยฺย ฯ

(๑๐๙) อฏฺฐหิ ภิกฺขเว ธมฺเมหิ สมนฺนาคตสฺส ภิกฺขุโน อาคจฺฉมาโน สงฺฆา ปฏิสารณียกมฺมํ ปฏิปฺปสฺสมฺภิยฺย ฯ กตเมหิ อฏฺฐหิ ฯ น ภิยฺโยปิ อลาภาย ปริสกฺกติ น ภิยฺโยปิ อนตฺถาย ปริสกฺกติ น ภิยฺโยปิ อโผฏฺฐพฺพาย ปริสกฺกติ น ภิยฺโยปิ ภิยฺโยปิ วิเหฐนาย

[๑๐๘] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការ សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ๘ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុពាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ๑ ពាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ๑ ដេរប្រទេចពួកគ្រហស្ថ ๑ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ๑ តិះដៀលព្រះពុទ្ធ ๑ តិះដៀលព្រះធម៌ ๑ តិះដៀលព្រះសង្ឃ ๑ ញុំាងឱពាក្យនិមន្តរបស់គ្រហស្ថប្រកបដោយធម៌ឲ្យឃ្លៀងឃ្លាត ๑ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។

[๑๐๙] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ๘ ប្រការ សង្ឃកាលប្រាថ្នា គប្បីរម្ងាប់នូវបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ๘ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនពាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ๑ មិនពាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ๑ មិនដេរប្រទេចពួកគ្រហស្ថ ๑ មិនបំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ๑

ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ធម្មិកញ្ច កិរិយំ សព្ភាបេតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ បដិប្បស្សម្ភេយ្យាតិ ។

(๑๑๐) តស្ស ទាបិយសិ ភិក្ខវេ ភិក្ខុនា អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្ពំ ន ឧបសម្បាទេតព្ពំ ន និស្សយោ ទាតព្ពោ ន សាមណេរោ ឧបដ្ឋាបេតព្ពោ ន ភិក្ខុនោវាទកសម្មតិ(๑) សាទិតព្ពា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្ពា ន កាចិ សង្ឃសម្មតិ សាទិតព្ពា ន កិស្មិញ្ចិ បទេកច្ចានេ និយមេតព្ពោ(๒) ន ច តេន ម្ហលេន វុដ្ឋាបេតព្ពំ ។ តស្ស ទាបិយសិ ភិក្ខវេ ភិក្ខុនា ឥមេសុ អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្ពន្តិ ។

សតិវគ្គោ សមត្តោ ។

---

๑ ឧ.ម. ភិក្ខុនោវាទកសម្មតិ ។ ๒ ឧ.ម បរិយេតព្ពោ ។

ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរ
ព្រះសង្ឃ ១ ញុំាងពាក្យនិមន្តរបស់ពួកគ្រហស្ថ ប្រកបដោយធម៌ឲ្យ
ទៀងទាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ
នេះឯង សង្ឃកាលប្រាថ្នា គប្បីរមែបន្ទូរបដិសារណីយកម្មបាន ។

(១១០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើ តស្ស បាបិយ-
សិកាកម្មរួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ កុំធ្វើធម៌ ៨ ប្រការគឺ មិនត្រូវឲ្យឧប-
សម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើ ១ មិនត្រូវ
ត្រេកអរនឹងការសន្ទនាជាអ្នកឲ្យនូវឱវាទដល់ភិក្ខុនី ១ បើពុំជាសង្ឃសន្ទនា
ហើយ ក៏មិនត្រូវឲ្យនូវឱវាទពួកភិក្ខុនី ១ មិនត្រូវត្រេកអរនឹងសង្ឃសម្មតិ
ណាមួយ ១ មិនត្រូវនិយមខ្លួនកុំឲ្យជាអធិបតីណាមួយ ១ មិនត្រូវឲ្យ
(ភិក្ខុ) ចេញចាកអាបត្តិដោយមូលនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ
ភិក្ខុដែលសង្ឃធ្វើ តស្ស បាបិយសិកាកម្ម រួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ
កុំធ្វើធម៌ ៨ ប្រការនេះឯង ។

តត្រុទ្ទានំ

សតិ បុណ្ណិយមូលេន ចោរសមណេន បញ្ចមំ
យសោ បត្តាប្បសាទេន(១) បដិសារណីយញ្ច វត្តតីតិ។

---

១ ឧ.ម. បត្តប្បសាទេន ។

ទុទ្ទាន

ក្នុងសូត្រនោះគឺ

និយាយអំពីសតិសម្បជញ្ញៈ ១ អំពីរឿងបុណ្ណិយកិក្ខុ ១ អំពីធម៌ជាមូល ១ អំពីមហាចោរ ១ អំពីព្រះនាមព្រះតថាគតមានព្រះនាមថា សមណៈជាដើម ១ ត្រូវជា ៥ អំពីព្រះអង្គមិនចង់ជួបនឹងយសបរិវារ ១ អំពីការផ្គាប់ចិត្តនឹងផ្លូវចិត្ត ១ អំពីសេចក្តីជ្រះថ្លានឹងមិនជ្រះថ្លា ១ អំពីបដិសារណីយកម្ម ១ អំពីកិក្ខុប្រព្រឹត្តល្អ ១ ។

ពោជ្ឈា សិរិមា បទុមា សុធម្មា(๑) មណុជា ឧត្តរា មុត្តា ខេមា(๒) រុចី(๓) ពុទ្ធិ ពិម្ពី សុមនា មល្លិកា តិស្សមោតា សោណមោតា កោណមោតា(๔) ឧត្តរមោតា(๕) វិសាខា មិគារមោតា ឧដ្ឋត្តរា ឧថាសិកា សាមាវតី ឧថាសិកា សុប្បវាសា កោឞ្ឌិយធីតា សុប្បិយា ឧថាសិកា ឧកុលមោតា តមាលតាឯតំ ។

(๑๑๑) រាតស្ស តិក្ខត្តុំ អភិញ្ញាយ អដ្ឋ ធម្មា ភាវេតព្ពា ។ កតមេ អដ្ឋ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ រាតស្ស តិក្ខត្តុំ អភិញ្ញាយ ឥមេ អដ្ឋ ធម្មា ភាវេតព្ពា ។

(๑๑๒) រាតស្ស តិក្ខត្តុំ អភិញ្ញាយ អដ្ឋ ធម្មា ភាវេតព្ពា ។ កតមេ អដ្ឋ ។ អដ្ឋង្គិកំ រូបសញ្ញំ

---

๑ ម.សុធនា ។ ๒ ម. ឯត្តវតា សោមាតិ ទិស្សតិ ។ ๓ ម. រូបី ។ ๔ ម. តិស្សា តិស្សាយ មាតា សោណា សោណាយ មាតា កាណា កាណាយ មាតា ។ ๕ ម.ម. ឧត្តរា ឧត្តរមាតា ។

រឿងក្រៅពីនេះទៀត ដែលព្រះសម្មាសម្ពុទ្ធទ្រង់សំដែងទោសថកម្ម ប្រកបដោយអង្គ ៨ ប្រការ ដល់ពួកឧបាសិកាទាំងអម្បាលនេះ គឺពោជ្ឈ-ឧបាសិកា សិរិមាឧបាសិកា បទុមាឧបាសិកា សុធម្មាឧបាសិកា មណុជាឧបាសិកា ឧត្តរាឧបាសិកា មុត្តាឧបាសិកា ខេមាឧបាសិកា រុចីឧបាសិកា ចុន្ទីពាជកុមារី ពិម្ពីឧបាសិកា សុមនាពាជកុមារី មល្លិកាទេវី តិស្សមាតាឧបាសិកា សោណមាតាឧបាសិកា កាណមាតាឧបាសិកា ឧត្តរានន្ទមាតាឧបាសិកា វិសាខាមិគារមាតាឧបាសិកា ខុជ្ជុត្តរាឧបាសិកា សមាវតីឧបាសិកា សុប្បវាសាកោលិយធីតាឧបាសិកា សុប្បិយាឧបាសិកា នកុលមាតាគហបតានីឧបាសិកា ។

(១១១) ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវភព: ។ ធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្ប: ១ សម្មាវាចា ១ សម្មាកម្មន្ត: ១ សម្មាអាជីវ: ១ សម្មាវាយាម: ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវភព: ។

(១១២) ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់នូវភព: ។ ធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺបុគ្គលមានសេចក្តីសំគាល់ ក្នុងរូបខាងក្នុង (មានសត់ជាដើមរបស់ខ្លួន)

ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្ពណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្ពណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្ពណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្ពណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី ឯ ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ ។បេ។ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ ។បេ។ លោហិតកានិ

ឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមានសេចក្តីសំគាល់ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបប្រមាណមិនបាន មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្តីសំគាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្តីសំគាល់ ក្នុងរូបខាងក្នុង តែងឃើញរូបខាងក្រៅ ជារូបប្រមាណមិនបាន មានសម្បុរល្អ ឬ សម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គល មិនមានសេចក្តីសំគាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ផ្ទុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ ១ ។ បេ ។ ជារូបលឿង មានសម្បុរលឿង ផ្ទុះចេញនូវពណ៌លឿង មានពន្លឺលឿង ១ ។ បេ ។ ជារូបក្រហម មានសម្បុរក្រហម

លោហិតកាវណ្ណានំ លោហិតកានំ ឧស្សន្នានំ លោហិត-
កានំកាសានំ ។បេ។ ខុទ្ទានំ ខុទ្ទាវណ្ណានំ ខុទ្ទាក-
និទ្ធន្នានំ ខុទ្ទានំកាសានំ តានំ អភិភុយ្យ ជានាមិ
បស្សាមីតិ ឯវំសញ្ញី ហោតិ ។ ឥទស្ស តិក្ខវេ អភិញ្ញាយ
ឯមេ អដ្ឋ ធម្មា ភាវេតព្ពា ។

(១០៣) ឥទស្ស តិក្ខវេ អភិញ្ញាយ អដ្ឋ ធម្មា
ភាវេតព្ពា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ
អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ សុភន្តេ
អធិមុត្តោ ហោតិ ។ សព្ពសោ រូបសញ្ញានំ សមតិក្កមា
បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការ
អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ
វិហរតិ ។ សព្ពសោ អាកាសានញ្ចាយតនំ សមតិក្កម្ម
អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។

ធ្នុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម ១ ។ បេ ។ ជារបស មានសម្បុរស ធ្នុះចេញនូវពណ៌ស មានពន្លឺស កំគ្រប់សង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសំគាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវពិចារណា ដើម្បីដឹងច្បាស់នូវរាគៈ ។

(១១៣) ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចំរើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ បុគ្គលមានរូបជ្ឈាន តែងឃើញរូប គឺកសិណទាំងឡាយ មានន័លកសិណជាដើម មិនមានសេចក្តីសំគាល់ក្នុងរូបខាងក្នុង (មានសក់ជាដើមរបស់ខ្លួន) តែងឃើញរូបខាងក្រៅ គឺកសិណ មានន័លកសិណជាដើម ជាអ្នកមានចិត្តប្តេជ្ញាថា វណ្ណកសិណបរិសុទ្ធ ១ ។ ព្រោះកន្លងបង់នូវរូបសញ្ញាដោយប្រការទាំងពួង រំងាសញ្ញានៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្ត ថា អាកាសមិនមានទីបំផុត ១ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្ត ថា វិញ្ញាណមិនមានទីបំផុត ១ ។

សព្ពសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សព្ពសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សព្ពសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ ឥមស្ស តិក្ខត្តុំ អភិញ្ញាយ ឥមេ អដ្ឋ ធម្មា ភាវេតព្ពា ។

(១១៤) ឥមស្ស តិក្ខត្តុំ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ អដ្ឋ ធម្មា ភាវេតព្ពាតិ ។ នោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ អដ្ឋ ធម្មា ភាវេតព្ពាតិ ។

អដ្ឋកនិបាតោ សមត្តោ ។

ព្រោះកន្ទងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង កំចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ១ ។ ព្រោះកន្ទងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង កំចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។ ព្រោះកន្ទងនូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង កំចូលកាន់ សញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់នូវភគៈ ។

(១១៤) ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចំរើន ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវភគៈ ។ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចំរើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

ចប់ អដ្ឋកនិបាត ។

វិរុទ្ធាវិរុទ្ធបត្តំ

វិរុទ្ធបាឋៈ	អវិរុទ្ធបាឋៈ	អង្កៃ	វង្គ្លេខាយំ
លាភោបិ	លាភោ បិ	១៣	១៩
កឹនានាករណំ	កឹ នានាករណំ	១៩	១៣
អប្បគព្ភោ	អបគព្ភោ	៤៧	៣
”	”	”	៩
”	”	”	៨
”	”	”	១៣
”	”	៦០	១៦
អប្បគព្ភតាយ	អបគព្ភតាយ	”	១៣
អប្បគព្ភោ	អបគព្ភោ	៦៤	១០
អប្បគព្ភតាយ	អបគព្ភតាយ	”	១១
អប្បគព្ភោ	អបគព្ភោ	”	១៤
”	”	៦៩	៤
អប្បគព្ភតាយ	អបគព្ភតាយ	”	៩
បភាមិ	បក្ខាមិ	៧៦	៦
បិតិតោបិ	បិតិតោ បិ	”	១១

វិទ្ធាវិទ្ធបត្តំ

វិទ្ធបាឋោ	អវិទ្ធបាឋោ	អង្កោ	វជ្ជិលេខាយំ
សោ វតោ	សោវតោ	๗๒	๑๖
”	”	๗๔	๖
អារទ្ធវិរិយោ	អារទ្ធវិរិយោ	”	๑๖
ទស្សាថេតិ	ទស្សាទេតិ	๘๙	๒
អច្ចរិយំ	អនច្ចរិយំ	๑๒๑	๓
កច្ចិត្ត	កច្ចិត្ត	๑๒๔	๕
អរិច្ច—	អច្ចរិ—	๑๒๘	๑๐
ខណាតិច្ចោ លោកោតិ	ខណាតិច្ចោ លោកោ		
	ខណាតិច្ចោ លោកោតិ	๑๓๘	๑๒
សនន្ទសច្ឆាយំ	សនន្ទសច្ឆាយំ	๑๔๕	๒
អារទ្ធវិរិយសច្ឆាយំ	អារទ្ធវិរិយសច្ឆាយំ	๑๔๖	๘
សង្គហិតបរិជនោ	សង្គហិតបរិជនោ	๒๒๖	๕
សារ	សារ	๒๓๗	๑๐
បដិគ្គណ្ហា	បដិគ្គណ្ហាមិ	,,	๑๖

វិរុទ្ធវិរុទ្ធបត្តំ

វិរុទ្ធបាឋៈ	អវិរុទ្ធបាឋៈ	អង្កៈ	រជ្ជុលេខាយំ
(៦៧)	(៦៨)	៤៧៤	១២
មនសិកវេយ្យ	មនសិកវេយ្យំ	៣១៤	៧
កិក្ខិ	កិក្ខិ កតវតោ	៣៩២	១៣
តនិនា	តនិនា	៣៩៨	៤
”	”	”	៨
ន ហនូនវេ	ន ហនូនមេ	៣៩៩	១៣

សន្ទីកប្រាប់ពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ផ្តាច់ផ្តល	ផ្តាច់ផ្តិល	៤៦	១៤
ចាប់ធ	ចាប់	៥១	៨
អសុត្តន្ត	សុត្តន្ត	៥៨	១
បរយោយ	បរិយោយ	៦៥	៧
ទិដ្ឋិ	ទិដ្ឋ១	៧៤	១៤
ព្រះសារីបុត្រ	សារីបុត្រ	៨៥	២
ដាយ	ដោយ	៨២	១៦
ប្រទក្សណ	ប្រទក្សិណ	១២៨	៨
ទីណា	ទីណា–	១៣៨	៨
សុណ្ណ	សុវណ្ណ	២០៨	៨
ម្ដុំមុគ	ម្ដុំមុត	២២៤	១០
រេសស់កាម	រេសស់កាម ។	២៦០	២
តំណ្ឌាយ	តាំងណ្ឌាយ	២៧៤	៥
មិគ្ឃ	មិនគ្ឃ	២៧៥	១៨

សន្លឹកប្រៀបពាក្យខុស-ត្រូវ

ពាក្យខុស	ពាក្យត្រូវ	ទំព័រ	បន្ទាត់
ចំរើ	ចំរើន	២៧៩	១៧
ឡៃយ	ឡើយ	២៩២	១៦
បណ្ណាសាក្តីហិត	បណ្ណាសាសង្គ្រហិត	៣១៣	១
នឹន	នឹង	៣២៦	១៥
ធម៌ាំង់ឡាយ	ាំង់ឡាយ	៣៣៨	៥

សុត្តន្តបិដកេ

អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

តតិយោ ភាគោ

មាតិកា	អង្គុ

បណ្ណាសកោ

បណ្ណាសកេ	មេត្តាវគ្គោ បឋមោ	១
	មហាវគ្គោ ទុតិយោ	៤១
	គហបតិវគ្គោ តតិយោ	១០៨
	ទានវគ្គោ ចតុត្ថោ	១៦០
	ទុច្ចរិតវគ្គោ បញ្ចមោ	១៨៣

បណ្ណាសកាសង្គហិតា វគ្គា

បណ្ណាសកាសង្គហិតវគ្គេសុ	សន្ថានវគ្គោ បឋមោ	២២៩
	ចាលវគ្គោ ទុតិយោ	២៦៦
	យមកវគ្គោ តតិយោ	៣០៥
	សតិវគ្គោ ចតុត្ថោ	៣៤៨
	វគ្គោ បញ្ចមោ	៣៦៩

សុត្តន្តបិដក

អង្គុត្តរនិកាយ អដ្ឋកនិបាត

នវមភាគ

មាតិកា		លេខទំព័រ
បណ្ណាសក		
បណ្ណាសក	មេត្តាវគ្គ ទី១	....១
	មហាវគ្គ ទី ២	....៤១
	គហបតិវគ្គ ទី៣	....១០៨
	ទានវគ្គ ទី ៤	....១៦០
	ឧបោសថវគ្គ ទី ៥	.... ១៨៣
បណ្ណាសកាសង្គហិតវគ្គ		
បណ្ណាសកាសង្គហិតវគ្គ	សន្ថានវគ្គ ទី ១	....២២៩
	ចាលវគ្គ ទី ២	.... ២៦៦
	យមកវគ្គ ទី ៣	.... ៣០៥
	សតិវគ្គ ទី ៤	....៣៤៨
	វគ្គ ទី ៥	....៣៦៩


INSTITUT BOUDDHIQUE